ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរកការពិត



◆ អនុស្សរណៈនៃការយោគយល់គ្នារវាងមជ្ឈមណ្ឌលឯកសារកម្ពុជា និងក្រសួងអប់រំ

◆ រូបថតជនបរទេសនៅមន្ទីរស-២១

ចែកជូនដោយឥតគិតថ្លៃដល់មន្ទីរស្រុកនិងឃុំទូទាំងព្រះរាជាណាចក្រកម្ពុជា

លេខ១៥៤ ខែតុលា ឆ្នាំ២០១២

# ស្វែងរកការពិត

លេខ១៥៤ ខែតុលា ឆ្នាំ២០១២


## ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

## មាតិកា


◆អនុស្សរណៈនៃការយោគយល់គ្នារវាងមជ្ឈមណ្ឌលឯកសារកម្ពុជា............១

◆នៅពេលដែលយុត្តិធម៌នៃរបបប្រល័យពូជសាសន៍ ...............................៤

◆រូបថតជនបរទេសនៅមន្ទីរស-២១ ស្គាល់ ..................................៦

**ផ្នែកឯកសារ**

◆ចម្លើយសារភាពរបស់ គ្រីស្តូហ្វើ អេដវីដ ឌីឡេនស៍ នៅមន្ទីរ .....................៧

◆ចម្លើយសារភាពរបស់ ហេង ពេជ្រ ហៅ ឆន យុទ្ធជនមន្ទីរប-១ ............១១

**ផ្នែកប្រវត្តិសាស្ត្រនិងការស្រាវជ្រាវ**

◆ស្លាកស្នាមបន្សល់ទុកពីរបបខ្មែរក្រហម ..........................................២១

◆“រដូវបុណ្យភ្ជុំ ខ្ញុំខិទ្ទិសជូនប្តី” ........................................................២៤

◆មេរៀនសម្រាប់ជីវិត...............................................................២៧

◆យ៉ែម ហ៊ុន អតីតមេក្រុមវរសេនាតូចទី១ កងពល៩២០ .....................៣០

**ផ្នែកច្បាប់**

◆ដកស្រង់ពីសក្ខីកម្មរបស់សាក្សី ភី ភួន ៖ ការព្រួយបារម្ភចំពោះ ..............៣៦

◆សេចក្តីសម្រេចដោះលែងជនជាប់ចោទ អៀង ធីរិទ្ធ.........................៣៩

**◆វេទិកាពិភាក្សាសាធារណៈ**

◆ហេតុអ្វីបានជាកម្ពុជាត្រូវសម្លឹងមើលឲ្យហួសពីអង្គជំនុំជម្រះ .................៤២

**ទំព័រស្រាវជ្រាវរកក្រួសារ**

◆លោកឪពុកខ្ញុំនៅក្នុងរបបខ្មែរក្រហម ................................................៤៨

◆ស្វែងរកឪពុកអស់ជិត៤០ឆ្នាំ .......................................................៥០

◆ដំណើរឆ្លងកាត់របបខ្មែរក្រហម .....................................................៥៦






## រក្សាសិទ្ធិ

មជ្ឈមណ្ឌលឯកសារកម្ពុជា

អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ
ក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា
ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មាន
លេខ០២៩១ពម/៩៩
ចុះថ្ងៃទី២ខែសីហាឆ្នាំ១៩៩៩

រូបថតឯកសារៈមជ្ឈមណ្ឌលឯកសារកម្ពុជា
និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង



***ស្នេរលេខនេះ ៖*** *ម៉ម សុវណ្ណ, សូត សុខហេង, អាន ហាញូឌល, អេនច្រេ អ៊ីង, ស៊ីវ ធួន* ***អ្នកនិពន្ធនិងស្រាវជ្រាវ ៖*** *ទាវ សារៈមុនិន្ទ និង ស៊ិន សុធីតា* ***អ្នកបកប្រែ ៖*** *នូ ស្រស់លក្ខិណា, នង ច័ន្ទមល្លិកា, ភួង ចាន់ប្រានិត* ***និពន្ធនាយក ៖*** *ឆាំង យុ និង ញាណ សុជាតិ* ***ជំនួយការនិពន្ធនាយក ៖*** *សោម ប៊ុនថន* ***ក្រាហ្វិកកុំព្យូទ័រ ៖*** *សោម ប៊ុនថន* ***គ្រប់គ្រងការចែកផ្សាយ ៖*** *ឆេង វើង* Email: dccam@online.com.kh, Homepage: www.dccam.org

# អនុស្សរណៈនៃការយោគយល់គ្នារវាងមជ្ឈមណ្ឌលឯកសារកម្ពុជា និងក្រសួងអប់រំ យុវជន និងកីឡា

កាលពីថ្ងៃទី១០ ខែតុលា ឆ្នាំ២០១២នេះ ក្រសួងអប់រំ យុវជន និងកីឡា និង មជ្ឈមណ្ឌលឯកសារកម្ពុជាបានចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នាមួយ នៅឯទីស្តីការក្រសួងអប់រំ ។ អនុលោមទៅតាមអនុស្សរណៈនៃការយោគយល់គ្នានេះ ក្រសួងអប់រំ យុវជននិងកីឡា នឹងប្រគល់ដីមួយកន្លែង (ដែលមានផ្ទៃក្រឡា ៤.៧៨៥.៦១ម៉ែត្រការ៉េ) ដែលនៅលើទីតាំងដីនោះ មជ្ឈមណ្ឌលអចិន្ត្រៃយ៍មួយដែលមានឈ្មោះថា វិទ្យាស្ថានស្លឹករឹត នឹងត្រូវបានសាងសង់ឡើង ។ ដីដែលត្រូវបានព្រមព្រៀងគ្នានេះមានទីតាំងនៅក្បែរសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រនិងវិទ្យាសាស្ត្រសេដ្ឋកិច្ច ។

វិទ្យាស្ថានស្លឹករឹត នឹងប្រែក្លាយទៅជាមជ្ឈមណ្ឌលនាំមុខគេមួយសម្រាប់ការសិក្សាពីអំពើប្រល័យពូជសាសន៍នៅតំបន់អាស៊ី ។ វិទ្យាស្ថាននឹងរួមមានសសរស្តម្ភចំនួនបីគឺ សារមន្ទីរ មជ្ឈមណ្ឌលស្រាវជ្រាវ និងសាលារៀន ។ សារមន្ទីរនឹងបម្រើជាបណ្ណសារសាធារណៈមួយនៃប្រវត្តិសាស្ត្រកម្ពុជា ដែលនៅទីនោះ ប្រជាពលរដ្ឋកម្ពុជា និងភ្ញៀវទេសចរណ៍បរទេសដែលចូលមកទស្សនា មិនមែនត្រឹមតែដើម្បីសិក្សាអំពីប្រវត្តិសាស្ត្រខ្មែរក្រហមប៉ុណ្ណោះទេ ប៉ុន្តែក៏ដើម្បីរីករាយជាមួយនឹងទីកន្លែងស្ងប់ស្ងាត់មួយដើម្បីត្រិះរិះពិចារណា និងព្យាបាលជំងឺផ្លូវចិត្ត ។ មជ្ឈមណ្ឌលស្រាវជ្រាវនឹងអនុញ្ញាតឲ្យមជ្ឈមណ្ឌលឯកសារកម្ពុជា បន្តកិច្ចការរបស់ខ្លួនក្នុងការបងក្រង វិភាគ និងថែរក្សាព័ត៌មានអំពីរបប ប៉ុល ពត ។ មជ្ឈមណ្ឌលស្រាវជ្រាវនេះ ក៏នឹងស្វាគមន៍អ្នកស្រាវជ្រាវមកពី




ពិធីចុះហត្ថលេខារវាងលោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា និងឯកឧត្តម អ៊ឹម សិទ្ធី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា លើអនុស្សរណៈស្តីពីការប្រគល់ដីមួយកន្លែងក្នុងបរិវេណវិទ្យាល័យបឹងត្របែកដល់មជ្ឈមណ្ឌលឯកសារកម្ពុជា



ជុំវិញពិភពលោក ដែលមានចំណាប់អារម្មណ៍ក្នុងការសិក្សាពីអំពើឧក្រិដ្ឋកម្មលើសិទ្ធិមនុស្សនៅក្នុងប្រទេសកម្ពុជា និងនៅទីកន្លែងផ្សេងទៀត ។ សាលារៀននឹងបណ្តុះបណ្តាលនិស្សិតកម្ពុជាដែលនាំមុខគេអំពីប្រវត្តិសាស្ត្រកម្ពុជា ក៏ដូចជាគោលការណ៍ជាក់លាក់នៃច្បាប់ និងសិទ្ធិមនុស្ស នៅក្នុងកិច្ចខិតខំប្រឹងប្រែងដើម្បីកសាងអនាគតប្រកបដោយសុទិដ្ឋិនិយមមួយ ។

មជ្ឈមណ្ឌលឯកសារកម្ពុជាមានបំណងចង់សាងសង់មជ្ឈមណ្ឌលនេះមានលក្ខណៈជាតិផង និងអន្តរជាតិផងប្រកបដោយវិសាលភាពធំធេង ។ លោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជាបានមានប្រសាសន៍ថា «ខ្ញុំមានបំណងចង់ឲ្យការសាងសង់នេះមានលក្ខណៈជាខ្មែរនិងឆ្លុះបញ្ចាំងអំពីវប្បធម៌របស់ប្រទេសកម្ពុជា ទន្ទឹមនោះដែរ ខ្ញុំចង់ឲ្យអគារនេះក្លាយជាកន្លែងចងចាំពិសេសមួយសម្រាប់ប្រទេសកម្ពុជានិងសាកលលោកទាំងមូល» ។

នាពេលបច្ចុប្បន្ននេះ មជ្ឈមណ្ឌលឯកសារកម្ពុជាកំពុងធ្វើការជាមួយក្រុមហ៊ុនស្ថាបត្យកម្មល្បីល្បាញពិភពលោកជាច្រើនដើម្បីរចនាលម្អមជ្ឈមណ្ឌលអចិន្ត្រៃយ៍ ។ ក្រុមហ៊ុនស្ថាបត្យកម្មទាំងនេះជាក្រុមហ៊ុនល្បីល្បាញពិភពលោកដែលអាចរួមចំណែកក្នុងការនាំយកអរិយធម៌ និងស្នាដៃស្ថាបត្យកម្មកម្ពុជាចូលទៅក្នុងសកលភាវូបនីយកម្មពិភពលោកបានទៀតផង ។ ក្នុងរយៈពេលកន្លងមកនេះ មជ្ឈមណ្ឌលឯកសារកម្ពុជា បានធ្វើការសហការយ៉ាងជិតស្និទជុំវិញបញ្ហាប្រវត្តិសាស្ត្រ និងវប្បធម៌ ជាមួយក្រសួងរដ្ឋាភិបាលចំនួនបួនគឺ ក្រសួងព័ត៌មាន ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ និងក្រសួងទេសចរណ៍ ។ ទន្ទឹមនឹងនោះដែរ មជ្ឈមណ្ឌលឯកសារកម្ពុជានិងបន្តកិច្ចសហការជាលក្ខណៈអន្តរជាតិជាមួយប្រទេសចំនួន២១ និងសាកលវិទ្យាល័យធំៗចំនួន២២នៅសហរដ្ឋអាមេរិក និងអឺរ៉ុប និងសាកលវិទ្យាល័យចំនួនបួនទៀត នៅអាស៊ី ។ ការទប់ស្កាត់អំពើប្រល័យពូជសាសន៍គឺជាកិច្ចការជាតិផងនិងសម្រាប់មនុស្សជាតិជាទូទៅផង ។

ប្រតិបត្តិការរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាត្រូវបាន




ផ្តល់ថវិកាដោយសប្បុរសពីម្ចាស់ជំនួយជាច្រើន ។ រដ្ឋាភិបាលសហរដ្ឋអាមេរិក តាមរយៈទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍន៍អន្តរជាតិ *(USAID)* និងការិយាល័យកម្មវិធីសាកលសម្រាប់លទ្ធិប្រជាធិបតេយ្យ សិទ្ធិមនុស្ស និងការងារ (DRL) នៃក្រសួងការបរទេសសហរដ្ឋអាមេរិក បានផ្តល់ថវិកាចំនួន៥,៣៥ លានដុល្លា ដល់មជ្ឈមណ្ឌលឯកសារកម្ពុជា នៅក្នុងការបន្តការគាំទ្រដល់កិច្ចការរបស់មជ្ឈមណ្ឌល ក្នុងការរៀបចំចងក្រងឯកសារស្តីពីអំពើឧក្រិដ្ឋកម្មរបស់របបខ្មែរក្រហម ។ នៅក្នុងចំនួនថវិកា៥,៣៥ លាននេះ ថវិកាចំនួន៤លានដុល្លា ត្រូវបានបែងចែកសម្រាប់ទេយ្យទានរបស់មជ្ឈមណ្ឌល ។ ថវិកាដែលនៅសល់ចំនួន១,៣៥ លាន គឺសម្រាប់ទ្រទ្រង់ដល់ប្រតិបត្តិការរបស់មជ្ឈមណ្ឌល ។ កិច្ចការទាំងនេះរួមមាន ការបន្តប្រមូលព័ត៌មានដើម្បីគាំទ្រកិច្ចការរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ការបំលែងឯកសារខ្មែរក្រហមជាងមួយលានឯកសារឲ្យទៅជាឯកសារឌីជីថល *(digitization)* ការបោះពុម្ពសៀវភៅស្វែងរកគ្រួសារមួយដែលរួមមានឈ្មោះជាងមួយលាន និងគម្រោងស្តីពីការបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ។ គម្រោងស្តីពីការបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ បានបណ្តុះបណ្តាល និងផ្តល់ឲ្យគ្រូមធ្យមសិក្សាចំនួនបីពាន់នាក់នូវប្រភពធនធានដែលចាំបាច់ និងវិធីសាស្ត្របង្រៀន ដើម្បីបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ទៅកាន់សិស្សមធ្យមសិក្សាជាងមួយលាននាក់ ។

អនុស្សរណៈនៃការយោគយល់គ្នានេះ មានសុពលភាពសម្រាប់រយៈពេល៥០ឆ្នាំ ដោយរាប់ចាប់តាំងពីថ្ងៃ ដែលភាគីទាំងពីរចុះហត្ថលេខានេះតទៅ ។ បន្ទាប់ពីរយៈពេល៥០ឆ្នាំដំបូងនៃកិច្ចព្រមព្រៀងនេះ មជ្ឈមណ្ឌលឯកសារកម្ពុជានឹងត្រូវបានអនុញ្ញាតឲ្យស្នើសុំការពន្យាពេលសម្រាប់រយៈពេល១០ឆ្នាំម្តង ។ អនុស្សរណៈនៃការយោគយល់គ្នានេះមិនអាចត្រូវបានលុបចោលទេ លុះត្រាណាមានការយល់ព្រមពីភាគីទាំងពីរ ។

**មជ្ឈមណ្ឌលឯកសារកម្ពុជា**

# នៅពេលដែលយុត្តិធម៌នៃរបបប្រល័យពូជសាសន៍ ប្រឈមនឹងភាពអយុត្តិធម៌

នាពេលថ្មីៗកន្លងទៅនេះ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានជូនដំណឹងថា ជនជាប់ចោទ អៀង ធីរិទ្ធ ក្នុងករណី០០២មិនមានសម្បទាគ្រប់គ្រាន់ក្នុងការចូលរួមកិច្ចដំណើរការតុលាការបានទេ ដោយសារតែជនជាប់ចោទរូបនេះមានជំងឺវង្វេងវង្វាន់ស្មារតីក្នុងកម្រិតមួយដ៏ធ្ងន់ធ្ងរ ។ នៅថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១២នេះ ប្រធានអង្គជំនុំជម្រះតុលាការកំពូលនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានសម្រេចថា អៀង ធីរិទ្ធ ត្រូវដោះលែងជាមួយលក្ខខណ្ឌបណ្តោះអាសន្នមួយចំនួនដូចជា ១)ជនជាប់ចោទត្រូវជូនដំណឹងដល់អង្គជំនុំជម្រះអំពីអាសយដ្ឋានដែលខ្លួនត្រូវបានស្នាក់នៅ ហើយមិនត្រូវផ្លាស់ប្តូរទីលំនៅដោយមិនមានការអនុញ្ញាតពីអង្គជំនុំជម្រះឡើយ ២)ជនជាប់ចោទត្រូវប្រគល់លិខិតឆ្លងដែននិងឯកសារធ្វើដំណើរពាក់ព័ន្ធដទៃទៀត ហើយមិនត្រូវចេញក្រៅព្រំប្រទល់ដែនដីនៃព្រះរាជាណាចក្រកម្ពុជាឡើយ និង ៣)ជនជាប់ចោទត្រូវគោរពតាមដីកាកោះដែលចេញដោយតុលាការ ។ ទោះបីជាមានការរំពឹងទុកបែបនេះជាយូរមកហើយយ៉ាងណាក៏ដោយ ដំណឹងអំពីការមិនមានសម្បទាគ្រប់គ្រាន់របស់ជនជាប់ចោទនិងការដោះលែងបែបនេះនៅតែជាថតភាពមួយដែលជនរងគ្រោះនៃរបបខ្មែរក្រហមពិបាកនឹងទទួលយក ។

នេះគឺជាការពិតនៅពេលដែលតួនាទីជាពិសេសរបស់ អៀង ធីរិទ្ធ នៅក្នុងចលនាខ្មែរក្រហមត្រូវបានលើកមកនិយាយ ។ អៀង ធីរិទ្ធ ត្រូវបានដាក់ឈ្មោះជារឿយៗនៅក្នុងសារព័ត៌មានបរទេសថាជា "ស្ត្រីទីមួយ" ។ ការឲ្យឈ្មោះជា "ស្ត្រីទីមួយ" បែបនេះ គឺឋានៈមួយមិនត្រឹមត្រូវទាល់តែសោះ ហើយធ្វើឲ្យមានការយល់ខុស ។ អៀង ធីរិទ្ធ មិនមែនជាបុគ្គលមួយរូបដែលបានចូលរួមពាក់ព័ន្ធក្នុងរបបខ្មែរក្រហមដោយសារតែឋានៈរបស់ខ្លួនជាប្រពន្ធរបស់ អៀង សារី និងជាប្អូនថ្លៃរបស់ ប៉ុល ពត នោះទេ ប៉ុន្តែ អៀង ធីរិទ្ធ គឺជាសមាជិកបក្សកុម្មុយនីស្តកម្ពុជាដ៏មានឥទ្ធិពលមួយរូបដែលមានអំណាចទូទាំងប្រទេសក្នុងនាមជារដ្ឋមន្ត្រីក្រសួងសង្គមកិច្ចនៃរបបកម្ពុជាប្រជាធិបតេយ្យ ។ នៅក្នុងតួនាទីបែបនេះ អៀង ធីរិទ្ធ បានធ្វើកិច្ចការដោយខ្លួនឯងនិងចូលរួមពាក់ព័ន្ធដោយផ្ទាល់ក្នុងការបដិសេធផ្តល់ការព្យាបាលសុខភាពជាមូលដ្ឋានដល់ប្រជាជនកម្ពុជាគ្រប់រូបក្នុងអំឡុងពេល


អៀង ធីរិទ្ធ នៅក្នុងបន្ទប់សវនាការ រូបថត : អ.វ.ត.ក

ដែលខ្លួនកំពុងមានអំណាចនៅក្នុងរបបខ្មែរក្រហម ។ ហេតុដូច្នេះ សម្រាប់ជនរងគ្រោះ ការដែល អៀង ធីរិទ្ធ មានលទ្ធភាពទទួលបានការថែទាំសុខភាពលំដាប់ថ្នាក់ពិភពលោក និងទទួលបាននូវការព្យាបាលពីវេជ្ជបណ្ឌិតជំនាញជាច្រើនរូបបែបនេះ គឺជាការផ្ទុយគ្នាស្រឡះទៅនឹងអ្វីដែល អៀង ធីរិទ្ធ ធ្លាប់បានធ្វើ និងអ្វីដែលខ្លួនធ្លាប់ហៅថា "ការថែទាំសុខភាពប្រជាជន" នៅក្នុងរបបខ្មែរក្រហម ។

បន្ថែមទៅនឹងសេវាសុខភាពយ៉ាងវិសេសវិសាលដែល អៀង ធីរិទ្ធ បានទទួល វាជាការលំបាកមួយសម្រាប់ជនរងគ្រោះ និងប្រជាជនកម្ពុជាទាំងអស់ក្នុងការទទួលយកនូវការលើកកម្ពស់សិទ្ធិរបស់ អៀង ធីរិទ្ធ ដែលកើតឡើងនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ សិទ្ធិការពារខ្លួនជាមូលដ្ឋាននៅតែជាទស្សនៈមួយពិបាកយល់នៅក្នុងតុលាការកម្ពុជា ។ ដូច្នេះ សេចក្ដីប្រកាសរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាអំពីសិទ្ធិទទួលបានយុត្តិធម៌ និងសិទ្ធិរបស់ជនជាប់ចោទគឺនៅតែជារឿងចម្លែក ហើយដែលជាទស្សនៈរបស់បរទេសដែលបានបញ្ចូលក្នុងសង្គមប្រជាជនកម្ពុជាជាទូទៅ ។ ជាថ្មីម្ដងទៀត ភាពទន់ខ្សោយនៃប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌរបស់កម្ពុជាគឺជាកេរដំណែលនៃរបបខ្មែរក្រហមដែលបានបំផ្លិចបំផ្លាញស្ថាប័នសំខាន់ៗ និងស្ថាប័នសង្គមស៊ីវិលរបស់កម្ពុជាដែលបង្កឲ្យមានភាពអយុត្តិធម៌ដ៏ជាក់ច្បាស់នៅក្នុងស្មារតីនៃភាពអយុត្តិធម៌សម្រាប់ជនរងគ្រោះ ដែលមើលឃើញថា អៀង ធីរិទ្ធ បានទទួលនូវកម្រិតយុត្តិធម៌ដ៏ត្រឹមត្រូវខាងផ្លូវច្បាប់ ដែលមិនមានជនជាប់ចោទកម្ពុជាណាម្នាក់អាចរំពឹងថានឹងទទួលបានដូច្នេះទេនៅពេលប្រជាជនកម្ពុជាត្រូវបានកាត់ទោស នៅក្នុងតុលាការកម្ពុជា សូម្បីតែបទឧក្រិដ្ឋដ៏តូចតាចក៏ដោយ ។

ប្រសិនបើ អៀង ធីរិទ្ធ នៅទីបំផុតអាចប្រណាំងឈ្នះនឹងពេលវេលានិងឈ្នះក្ដីដែលការទទួលខុសត្រូវរបស់ខ្លួននៅក្នុងរបបខ្មែរក្រហមមិនដែលទទួលបាននូវការកាត់ទោស ហេតុការណ៍ជាអកុសលបែបនេះអាចនឹងប្រើប្រាស់ជាផ្នែកមួយនៃដំណើរការយុត្តិធម៌អន្តរកាលដែលបានកើតឡើងនៅក្នុងប្រទេសកម្ពុជា ។

ទីមួយ ការមិនមានសម្បទាគ្រប់គ្រាន់និងការដោះលែងរបស់ អៀង ធីរិទ្ធ មិនបង្កជាឧបសគ្គខ្លាំងដល់ដំណើរការស្វែងរកយុត្តិធម៌អន្តរកាលក្នុងកម្រិតទូលំទូលាយធំដែលកំពុងតែដំណើរការក្នុងករណី០០២នៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានោះទេ ហើយសង្ឃឹមថានឹងបង្កើនសេចក្ដីចង់បានបន្ថែមទៀតដល់តុលាការក្នុងការជំរុញកិច្ចដំណើរការទៅមុខជាបន្ទាន់ក្នុងករណីប្រឆាំងនឹងមេដឹកនាំខ្មែរក្រហមដទៃទៀត ។

សេវាថែទាំសុខភាពផ្លូវចិត្តដែល អៀង ធីរិទ្ធ បានទទួលគឺជាសញ្ញាណមួយនៃសេចក្ដីករុណា ប្រសិនបើប្រៀបធៀបទៅនឹងកង្វះខាតទាំងស្រុងនៃសេចក្ដីករុណាបែបនេះក្នុងរបបខ្មែរក្រហម ។ ភាពពេញចិត្តមួយចំនួនអាចនឹងទទួលបានពីជនរងគ្រោះដែលត្រូវបានដកហូតឱកាសក្នុងការដាក់ អៀង ធីរិទ្ធ ឲ្យទទួលខុសត្រូវតាមច្បាប់តុលាការដោយជំទាស់មិនទទួលយកបទដ្ឋានតុលាការយុត្តិធម៌ជាមូលដ្ឋានមួយ សូម្បីតែនៅចំពោះមុខឧក្រិដ្ឋកម្មដ៏ព្រៃផ្សៃដែល អៀង ធីរិទ្ធ ត្រូវបានចោទប្រកាន់ក៏ដោយ ។ លើសពីនេះទៅទៀត បញ្ហាសុខភាពផ្លូវចិត្តដ៏ស្មុគស្មាញដែលកើតមាននៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាអាចនឹងត្រូវបានយកមកប្រើប្រាស់ដើម្បីពង្រីកវិស័យសុខភាពផ្លូវចិត្ត នៅប្រទេសកម្ពុជាដែលជាកេរដំណែលនៃរបបខ្មែរក្រហម ។

ក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ខ្មែរក្រហមបានប្រើអំពើហិង្សាប្រឆាំងនឹងអារម្មណ៍ ព្រមទាំងមនោសញ្ចេតនាជាមូលដ្ឋានរបស់មនុស្ស ហើយខ្មែរក្រហមបានចាត់ទុកអាការនៃរោគសញ្ញាសាមញ្ញដូចជា ឈឺក្បាលថាជាភាពទន់ខ្សោយនិងថាជាជំងឺរបស់ចក្រពត្តិនិយម ។ អ្នកដែលមានបញ្ហាផ្លូវចិត្តធ្ងន់ធ្ងរដូចអ្វីដែល អៀង ធីរិទ្ធ កំពុងទទួលរងសព្វថ្ងៃ នឹងត្រូវបានកម្ចាត់ចោលភ្លាមដោយរបបខ្មែរក្រហមដែលបានចាត់ទុកថាជាសញ្ញាណនៃភាពទន់ខ្សោយនៃសង្គមដែលត្រូវតែចាត់វិធានការ ។ នៅពេលនេះ អៀង ធីរិទ្ធ ត្រូវបានផ្ដល់នូវក្ដីមេត្តាករុណា ដែលក្ដីមេត្តាករុណានេះខ្លួនបានធ្វើការយ៉ាងសកម្មដើម្បីបំបាត់ចោលក្នុងនាមជារដ្ឋមន្ត្រីខ្មែរក្រហមមួយរូប ។ ខណៈពេលដែលការធ្វើបែបនេះគឺជាទង្វើដ៏ឈឺចាប់មួយសម្រាប់ជនរងគ្រោះ ស្របពេលជាមួយគ្នានោះដែរ យើងក៏មានក្ដីសង្ឃឹមយ៉ាងមុតមាំក្នុងផ្លូវដ៏វែងឆ្ងាយ ទៅមុខថា ទង្វើនេះនឹងត្រូវបានមើលឃើញថាជាភាពជោគជ័យដ៏តូចមួយសម្រាប់ភាពយុត្តិធម៌ និងភាពថ្លៃថ្នូររបស់មនុស្សជាតិ ។ **ឆាំង យុ**

# រូបថតជនបស្ចិមប្រទេសនៅស-២១ ស្គាល់អត្តសញ្ញាណ

*កាលពីចុងខែសីហាកន្លងទៅ កាំង ហ្កេកអ៊ាវ ហៅ ឌុច ត្រូវបានប្រគល់ជូននូវរូបថតជនបស្ចិមប្រទេសចំនួនពីរសន្លឹកដែលត្រូវបានរំពឹងថាជារូបអ្នកទោសនៅមន្ទីរស-២១ កាលពីអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ។*

*រូបថតពីរសន្លឹកនេះ គឺជារូបនៅក្នុងចំណោមរូបថតទាំង ១.៨៧២សន្លឹក ដែលមជ្ឈមណ្ឌលឯកសារកម្ពុជាទទួលបានកាលពីដើមខែសីហាកន្លងទៅ ។ ជាអតីតប្រធានមន្ទីរស-២១ ឌុច ត្រូវបានរំពឹងថានឹងអាចកំណត់អត្តសញ្ញាណអ្នកទាំងពីរនេះបាន ព្រោះក្នុងចំណោមអ្នកទោសប្រមាណជា១៤.០០០នាក់ ដែលជាប់នៅក្នុងមន្ទីរស-២១ មិនមានជនបរទេសមកពីបស្ចិមប្រទេសច្រើនទេ ។ ប៉ុន្តែការរំពឹងទុកបែរជាទទួលបាននូវការខកបំណងទៅវិញ ។*

*ឌុច បានបដិសេធគ្រាន់តែឃើញរូបថតទាំងពីរនេះភ្លាមដោយនិយាយថា គាត់មិនដែលស្គាល់ជនបរទេសមកពីបស្ចិមប្រទេសទាំងពីរនាក់នេះទេ ហើយថាជនបរទេសទាំងពីរនាក់នេះក៏មិនមែនជាអ្នកទោសនៅស-២១ ដែរ ដោយហេតុថា រាល់អ្នកទោសជនបស្ចិមប្រទេសទាំងអស់សុទ្ធតែមានស្លាកលេខនៅលើអាវ តែអ្នកទោសទាំងពីរនេះមិនមានស្លាកលេខទេ ។ ឌុច បានបញ្ជាក់ទៀតថា មិនមានបន្សល់ភ័ស្តុតាងស្តីអំពីអ្នកទោសមកពីបស្ចិមប្រទេសទេ ព្រោះឯកសារដែលពាក់ព័ន្ធទៅនឹងអ្នកទោសមកពីបស្ចិមប្រទេសទាំងអស់ត្រូវបានដុតបំផ្លាញចោលអស់ហើយក្រោមបទបញ្ជារបស់ នួនជា ។*

*ឌុច បានបន្តទៀតថា ខ្លួនគាត់ផ្ទាល់មិនបានធ្វើតាមបញ្ជារបស់ នួនជា ទាំងស្រុងទេ ។ គាត់បានលាក់រូបថតជនបរទេសមកពីបស្ចិមប្រទេសមួយសន្លឹកនៅក្នុងបន្ទប់គេងក្នុងផ្ទះរបស់គាត់ដែលមានទីតាំងនៅជិតមន្ទីរស-២១ ដែលរូបថតនោះគឺជារូបជនបស្ចិមប្រទេសម្នាក់កំពុងអង្គុយទាំងជើងកំពុងជាប់ខ្នោះ ។ ឌុច បានបន្ថែមទៀតថា ពេលដែលគាត់គេចខ្លួនមុនពេលកងទ័ពវៀតណាមចូលមកដល់ គាត់មិនបានយករូបថតនោះទៅជាមួយទេ ។*

*អត្តសញ្ញាណរបស់ជនបស្ចិមប្រទេសទាំងពីរនាក់នៅតែជាអាថ៌កំបាំង ។ ស្របពេលជាមួយគ្នានោះដែរ លោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា បានផ្ញើរូបថតពីរសន្លឹកនេះទៅសាស្ត្រាចារ្យ ភីធើ ម៉ាគា នៃសាកលវិទ្យាល័យកូឡុំបៀ ដើម្បីឲ្យគាត់ទាក់ទងទៅសាច់ញាតិ និងមិត្តភក្តិរបស់ជនជាតិអាមេរិកាំងដែលបានជាប់ឃុំឃាំង និងស្លាប់នៅមន្ទីរស-២១ ។*

*ទើបមកដល់ដើមខែកញ្ញានេះ ពលរដ្ឋអាមេរិកាំងម្នាក់បានជូនដំណឹងទៅសាស្ត្រាចារ្យ ភីធើ ម៉ាគា ថា រូបមួយក្នុងចំណោមរូបទាំងពីរនោះ គឺអតីតអ្នកជិះទូកក្តោងសញ្ជាតិអាមេរិកម្នាក់ឈ្មោះ គ្រីស្តូហ្វើ ឌីឡេនស៍ ដែលជាអតីតមិត្តរបស់គាត់កាលពីនៅក្រុងឡុងប៊ិច សហរដ្ឋអាមេរិក ។*

*នេះគឺជាការរកឃើញដែលមិននឹកស្មានដល់ ។ សាច់ញាតិនិងមិត្តភក្តិរបស់ គ្រីស្តូហ្វើ ឌីឡេនស៍ បានខិតខំស្វែងរករូបថតគាត់តាំងពីរបបខ្មែរក្រហមដួលរលំមកម្ល៉េះ ។ ការរកឃើញនេះដែរសបញ្ជាក់ឲ្យឃើញដែរថា ឌុច មិនបានបំផ្លាញភ័ស្តុតាងដែលទាក់ទងទៅនឹងជនបស្ចិមប្រទេសឲ្យសូន្យសុងនោះទេ ។ ចម្លើយសារភាពរបស់ គ្រីស្តូហ្វើ ឌីឡេនស៍ ក៏ត្រូវបានរកឃើញនៅមន្ទីរស-២១ ដែរ ។*

*តាមចម្លើយសារភាពនៅមន្ទីរស-២១ បានបញ្ជាក់ថា គ្រីស្តូហ្វើ ត្រូវបានចាប់ខ្លួនកាលពីពាក់កណ្តាលឆ្នាំ១៩៧៨ ជាមួយជនជាតិអាមេរិកាំងបីនាក់ទៀតគឺ ជែមស៍ ក្លាក, ម៉ៃឃើល ឌីដ និង ឡេនស៍ មេក ណាម៉ារ៉ា ។ ចម្លើយសារភាពរបស់ ជែមស៍ ក្លាក អាចរកបាននៅក្នុងទស្សនាវដ្តីស្វែងរកការពិតលេខ១៥០ ខែមករា ឆ្នាំ២០១២ ។*

*គ្រីស្តូហ្វើឌីឡេនស៍ដូចគ្នាទៅនឹងអ្នកទោសជនជាតិអាមេរិកផ្សេងទៀតដែរ ត្រូវបានបង្ខំឲ្យឆ្លើយថាជាអ្នកស៊ើបការរបស់ទីភ្នាក់ងារស៊ើបការសម្ងាត់អាមេរិក សេ.អ៊ី.អា ។*

**ញាណ សុជាតិ**

# ចម្លើយសារភាពរបស់ គ្រីស្តូហ្វើ អេដវ័ដ ឌីឡេនស៍ នៅមន្ទីរស-២១

ដកស្រង់ចេញពីចម្លើយសារភាព ឯកសារD៧១៥០



អ្នកបើកទូកក្តោងសញ្ជាតិអាមេរិកាំងម្នាក់ឈ្មោះ គ្រីស្តូហ្វើ អេដវ៉ដ ឌីឡេនស៍ ត្រូវបានចាប់ដោយយោធាខ្មែរក្រហមនៅក្នុងឈូងសមុទ្រកម្ពុជាកាលចុងឆ្នាំ១៩៧៨ ។ គ្រីស្តូហ្វើ អេដវ៉ដ ឌីឡេនស៍ ដែលកាលនោះមានអាយុ២៩ឆ្នាំ ត្រូវបានចាប់ខ្លួនជាមួយនិងមិត្តភក្តិជនជាតិអាមេរិកបីនាក់ផ្សេងទៀត ហើយត្រូវបានបញ្ជូនទៅមន្ទីរស-២១ដើម្បីសួរចម្លើយ និងក្រោយមកសម្លាប់ដោយចោទថាជាភ្នាក់ងារសម្ងាត់សេ.អ៊ី.អា ។ បើតាម កាំង ហ្កេកអ៊ាវ ហៅ ឌុច ជនជាតិអាមេរិកាំងទាំងបួននាក់ត្រូវបានសួរចម្លើយជាភាសាខ្មែរ ហើយត្រូវបានបកប្រែទៅជាភាសាអង់គ្លេស និងប្រែមកភាសាខ្មែរវិញដោយអ្នកទោសជនជាតិខ្មែរឈ្មោះ ឃិន វ៉ាន់ឆន ដែលជាកូនរបស់អ្នកទោស សារិន ឆាក អតីតអគ្គរដ្ឋទូតកម្ពុជាប្រជាធិបតេយ្យប្រចាំនៅប្រទេសអេហ្ស៊ីប យូហ្គោស្លាវី និងអាល់បានី។ ខាងក្រោមនេះគឺជាខ្លឹមសារដកស្រង់ចេញពីចម្លើយសារភាពដែលត្រូវបានបកប្រែជាភាសាខ្មែរដោយ ឃិន វ៉ាន់ឆន ។ គ្រីស្តូហ្វើ អេដវ៉ដ ឌីឡេនស៍ និងជនជាតិអាមេរិកាំងទាំងបីនាក់ទៀត ត្រូវបានបង្ខំឲ្យឆ្លើយអំពីគោលនយោបាយរបស់អាមេរិកចំពោះប្រទេសផ្សេងទៀត ។ ខាងក្រោមនេះនះគឺជាអ្វីដែល គ្រីស្តូហ្វើ អេដវ៉ដ ឌីឡេនស៍ បានរៀបរាប់ ។

## នយោបាយក្រៅប្រទេសនៃសហរដ្ឋអាមេរិកចំពោះចិនប្រជាមានិត តៃវ៉ាន់ និង ហុងកុង

នយោបាយរបស់អាមេរិកចំពោះតៃវ៉ាន់ យោងទៅតាមភោគសម្បត្តិសេដ្ឋកិច្ចរបស់អាមេរិកនៅក្នុងកោះនោះ ។ អាមេរិកដាក់ទុនរកស៊ីក្នុងកោះតៃវ៉ាន់នៅច្រើនផ្នែកតាំងពីសំណង់នាវារហូតដល់ខស្សរាហកម្មតម្បាញ និងកាត់ដេរខោអាវ ។ ជាការធម្មតាទេ ដែលអាមេរិកចង់រក្សាកោះតៃវ៉ាន់ ។ ខ្ញុំដឹងយ៉ាងច្បាស់អំពីរឿងសំណង់នាវាដោយខ្លួនខ្ញុំផ្ទាល់យកចិត្តទុកដាក់ណាស់ចំពោះបញ្ហានេះ ។

ក្នុងរយៈ៤-៥ឆ្នាំកន្លងមកនេះ តាមការសង្កេតតាមដានរបស់ខ្លួនខ្ញុំផ្ទាល់ឃើញថា អាមេរិកកាន់តែទាក់ទងបានល្អឡើងៗជាមួយចិន ។ ក្រោយពីទស្សនកិច្ចរបស់ និចសុន នៅប៉េកាំងមក

មានការបន្ធូរបន្ថយបរិយាកាសតឹងតែងជាមួយនឹងចិន ហើយការបញ្ជាក់ថាប្រទេសទាំងពីរចង់ដោះស្រាយបញ្ហាផ្សេងៗដោយសន្តិវិធី ។ ការពិភាក្សាជាមួយនឹងភ្នាក់ងារដ៏ទៃទៀតនៅសាលាមុខងារពិសេសរបស់សេ.អ៊ី.អា (ក្នុងទីក្រុងឡូសអាន់ជឺឡេស) ក្នុងឆ្នាំ១៩៧៥ គេបាននិយាយប្រាប់ខ្ញុំថា សហរដ្ឋអាមេរិកមើលមកចិនដូចជាសម្ព័ន្ធមិត្តមួយក្នុងការវាយប្រឆាំងនឹងសហភាពសូវៀត ។

ចំពោះសហរដ្ឋអាមេរិក សហភាពសូវៀតជាប្រទេសកុម្មុយនីស្តខ្លាំងជាងគេ ហើយនឹងឈ្លានពានគេខ្លាំងបំផុតនៅក្នុងសកលលោក ។ ដូច្នោះ បើអាមេរិកចូលរួមកម្លាំងជាមួយនឹងចិនដែលខ្សោយជាងសូវៀត ប្រទេសទាំងពីរនឹងចំណេញទាំងអស់គ្នា ។ ប្រទេសទាំងពីរអាចទប់ទល់បានល្អ កុំឲ្យសូវៀតចូលទៅឈ្លានពាននៅកន្លែងណាមួយបាន ។

ខែឧសភា ឆ្នាំ១៩៧៨នេះ ខ្ញុំបានបំពេញទស្សនកិច្ចនៅហុងកុង ។

ចំពោះហុងកុង អាមេរិកនាំឥវ៉ាន់ហុងកុងចូលប្រទេសគេពីព្រោះតម្លៃវាថោកជាងនៅសហរដ្ឋអាមេរិក ។ ម្យ៉ាងទៀត ចំពោះអ្នកដាក់ទុនរកស៊ីនៅហុងកុងគេអាចឲ្យប្រាក់ខែកម្មករតិចបាន ។ ហើយកម្មករនោះផលិតឥវ៉ាន់បានល្អទៀត ។

## នយោបាយក្រៅប្រទេសនៃសហរដ្ឋអាមេរិកចំពោះជប៉ុន

ក្នុងរយៈពេល៤-៥ឆ្នាំកន្លងមក ខ្ញុំបានដឹងព័ត៌មានដោយផ្ទាល់ខ្លួនដូចតទៅ ៖ ចំពោះជប៉ុន សហរដ្ឋអាមេរិកប្រកាន់នយោបាយនិងគោលជំហរមិត្តភាពយ៉ាងជិតស្និទ្ធ ហើយនិងដោះស្រាយបញ្ហាផ្សេងៗដោយសន្តិវិធី ។ ខាងផ្នែកសេដ្ឋកិច្ច សហរដ្ឋអាមេរិកជាផ្សារមួយធំណាស់ចំពោះទំនិញជប៉ុន ហើយជប៉ុនក៏បានផលិតឧស្សាហកម្មភាគច្រើនសម្រាប់តែផ្សារនេះដែរ ។ បើនិយាយជាជាក់ស្តែង ផ្សារអាមេរិកបានជំរុញឲ្យសេដ្ឋកិច្ចជប៉ុនរីកលូតលាស់ល្អមែនទែន ។ ផ្សារអាមេរិកវាចាំបាច់ណាស់ចំពោះជប៉ុនយ៉ាងដូច្នេះ ហើយជប៉ុននឹងខិតខំការពារវាដាច់ខាតហើយនឹងរក្សាចំណងមិត្តភាពជាមួយនឹងអាមេរិកឲ្យបានល្អទៅទៀតទៅអនាគត ។

ម្យ៉ាងទៀត អាមេរិកក៏ត្រូវការផលិតកម្មជប៉ុនដែរ ដូចគ្នានឹងជប៉ុនត្រូវការលក់វា ។ ឧស្សាហកម្មជប៉ុនអាចផលិតរបស់របរបានយ៉ាងថោក ព្រមទាំងចេញជាគុណភាពល្អថែមទៀត ដូចជានាឡិកា ទូរទស្សន៍ ប្រដាប់ថតរូប វិទ្យុ គ្រឿងដាំស្ល ល្បែងកូនក្មេង គ្រឿងក្លែង រថយន្ត ម៉ូតូ គ្រឿងគិតលេខ ឧបករណ៍ម៉ាស៊ីន ប្រដាប់ថតសំឡេង សម្ភារកីឡា ។ល។ របស់ទាំងអស់នេះ ប្រជាជនអាមេរិកត្រូវការប្រើវាជារៀងរាល់ថ្ងៃ ។ បើគ្មានការដោះដូរពាណិជ្ជកម្មជាមួយជប៉ុនទេ អាមេរិកត្រូវចំណាយលុយទិញវាយ៉ាងថ្លៃពីអឺរ៉ុប ឬពីអាមេរិកផ្ទាល់ហើយវាគ្មានគុណភាពល្អដូចផលិតផលជប៉ុនទេ ។

ព្រមជាមួយគ្នានេះដែរ សហរដ្ឋអាមេរិកលក់គ្រឿងដែកចាស់ៗទៅឲ្យជប៉ុនដែលយកវាទៅផលិតចេញជាទំនិញផ្សេងៗ ។

ទេសចរណ៍អាមេរិកជាច្រើននាក់ទៅលេងប្រទេសជប៉ុន ហើយទេសចរណ៍ជប៉ុនជាច្រើននាក់ក៏មកលេងអាមេរិក និងហាវ៉ៃ វិញដែរ ។ ដូច្នេះ មានរបររកស៊ីច្រើនណាស់នៅជុំវិញរឿងទស្សនកិច្ចផ្សេងៗ ។

សព្វថ្ងៃនេះ ជប៉ុនដាក់ទុនរកស៊ីជាច្រើននៅក្នុងប្រទេសអាមេរិកខាងផ្នែកឧស្សាហកម្ម ហើយនឹងសំណង់ផ្ទះ ។ បើគិតតែរដ្ឋហាវ៉ៃ មួយ ជប៉ុនដាក់ទុនរកស៊ីច្រើនមែនទែនខាងផ្នែកសំណង់ផ្ទះ ។ ជប៉ុន សង់សណ្ឋាគារពាសពេញ ហើយទាក់ទងខ្លាំងណាស់ជាមួយនឹងឧស្សាហកម្មដឹកនាំទេសចរណ៍ដើរលេង ។

ជប៉ុនទិញយន្តហោះពីអាមេរិកជាច្រើនគ្រឿង ដើម្បីផ្ទុកអ្នកដំណើរនិងទេសចរណ៍ជប៉ុន ។ ដូច្នេះ វាផ្តល់លុយជាច្រើនដល់ក្រុមហ៊ុនធ្វើយន្តហោះនៅអាមេរិក ។ ឯឧស្សាហកម្មជប៉ុន ខាងធ្វើនាវាវិញ វាមានសារសំខាន់ខ្លាំងណាស់ចំពោះសហរដ្ឋអាមេរិក ។ ពីព្រោះអាមេរិកត្រូវការទិញនាវាផ្ទុកប្រេងកាត ដែលជប៉ុនផលិតបានយ៉ាងថោក ។ ដូច្នេះហើយ ឧស្សាហកម្មខាងធ្វើនាវាវាសំខាន់ណាស់ចំពោះប្រទេសជប៉ុន ។

អាមេរិកទិញម្ហូបអាហារមួយចំនួនពីជប៉ុន ហើយជប៉ុនក៏ទិញសាច់គោពីអាមេរិក ។ ដោយមានការទាក់ទងរកស៊ីដោះដូរគ្នាយ៉ាងច្រើនដូចនេះ ប្រទេសទាំងពីរនឹងខិតខំថែរក្សាចំណងមិត្តភាពទៅអនាគតរវាងគ្នាទៅវិញទៅមកថែមទៀតពីព្រោះវាចំណេញដល់ប្រទេសទាំងពីរ ។

ម្យ៉ាងទៀត ជប៉ុនក៏ពឹងផ្អែកទៅលើអាមេរិកដែរ ។ បើសិនជាមានការវាយលុកឈ្លានពានពីប្រទេសកុម្មុយនីស្តណាមួយ ។

ជប៉ុន ជាសម្ព័ន្ធមិត្តមួយធំចំពោះសហរដ្ឋអាមេរិក ពីព្រោះសេដ្ឋកិច្ចប្រទេសទាំងពីរទាក់ទងគ្នាល្អណាស់ ។ ម្យ៉ាងទៀត ប្រទេសលោកសេរីទាំងអស់ត្រូវតែជួយគ្នាទៅវិញទៅមក ដើម្បីទប់ទល់បានល្អនិងកុម្មុយនីស្ត ។

អាមេរិកមិនអាចរស់នៅតែម្នាក់ឯងបានទេ ។ សេដ្ឋកិច្ចអាមេរិកមិនអាចឯកោពីសេដ្ឋកិច្ចសកលលោកបានទេ ។ ដូច្នេះហើយ អាមេរិកត្រូវតែជួយការពារប្រទេសលោកសេរីដទៃទៀត ដើម្បីផលប្រយោជន៍របស់អាមេរិកផ្ទាល់ ជាពិសេស ដើម្បីរក្សាការពារផ្គត់ផ្គង់ប្រេងកាតដល់សហរដ្ឋអាមេរិក ។

## នយោបាយក្រៅប្រទេសនៃសហរដ្ឋអាមេរិកចំពោះសូវៀត

ចំពោះសហភាពសូវៀត អាមេរិកប្រុងប្រយ័ត្នបំផុត ពីព្រោះសូវៀតជាសត្រូវធំបំផុតរបស់អាមេរិក ។ អាមេរិករៀបចំធ្វើយុទ្ធសាស្ត្រអាវុធរបស់ខ្លួនផ្ទាល់ដោយយោងទៅតាមសមត្ថភាពរបស់សូវៀតនឹងធ្វើគ្រឿងអាវុធបរមាណូដែរ ។ សហរដ្ឋអាមេរិកចង់រក្សាកម្លាំងយោធាឲ្យបានស្មើនឹងសូវៀតសម្រាប់ការពារខ្លួនកាលណាមានសង្គ្រាមឬមួយដើម្បីកំញើញកុំឲ្យសូវៀតឈ្លានពានអាមេរិក ហើយសម្ព័ន្ធមិត្តរបស់គេ ។

ថ្មីៗនេះ សហភាពសូវៀត ហើយនិងសហរដ្ឋអាមេរិកបានយល់ឃើញថាប្រទេសទាំងពីរគួរតែឈប់ប្រកួតប្រជែងគ្នាដើម្បីធ្វើគ្រឿងអាវុធបរមាណូទំនើបៗទៀត ។ ពីព្រោះប្រទេសទាំងពីរមានលទ្ធភាពគ្រប់គ្រាន់នឹងកម្ទេចគ្នាទៅវិញទៅមកហើយ មិនចាំបាច់ចំណាយលុយកាក់នឹងកម្លាំងធ្វើអ្វីទៀតទេ ។

ព័ត៌មានផ្សេងៗទៀតដែលខ្ញុំដឹងចំពោះទ្វីបអាស៊ី គឺវាទាក់ទងនឹងទស្សនកិច្ចទេសចរណ៍អាមេរិក នៅប្រទេសចិន និងសូវៀត ។ ទេសចរណ៍អាមេរិកអាចទៅដើរលេងមើលសហភាពសូវៀតនៅកន្លែងខ្លះៗ ហើយនិងក្នុងរយៈពេលដែលកំណត់យ៉ាងជាក់លាក់ មិនឲ្យលើសថ្ងៃទេ ។ ម្យ៉ាងទៀត មិនត្រូវធ្វើសកម្មភាពអ្វីល្មើសច្បាប់ដាច់ខាត ។

តាមព័ត៌មានចេញពីទេសចរណ៍ថា ប្រជាជនសូវៀតចង់បានប្រើរបស់របរមកពីលោកខាងលិចណាស់ ។ អ្វីៗដែលមកពីលោកខាងលិចដូចជាមានតម្លៃរកអ្វីប្រៀបពុំបានចំពោះសូវៀត ។ ជាឧទាហរណ៍ បើសិនទេសចរណ៍អាមេរិកបោះកញ្ចប់បារីដែលអស់ បារីដក់ចោល ពួកសូវៀតនឹងប្រញាប់ប្រញាល់គ្នាដណ្តើមកញ្ចប់នោះមកប្រើដាក់បារីសូវៀតជក់ ។ យ៉ាងដូច្នេះ គេអាចនឹងបញ្ឆោតប្រាប់ញាតិមិត្តគេថា គេមានបារីអាមេរិកដែរ ។

កាលណាជនជាតិអាមេរិកណាមួយចូលទៅបំពេញទស្សនកិច្ចនៅសហភាពសូវៀត ជននោះត្រូវបំពេញសំបុត្រស្នាមជាមួយយ៉ាងហ្មត់ចត់ និយាយឲ្យជាក់លាក់ថាមានអ្វីខ្លះជាប់នឹងខ្លួន ហើយដល់ពេលចាកចេញពីសហភាពសូវៀតវិញ ត្រូវមានរបស់នោះដដែលជាប់នឹងខ្លួន ។ ពីព្រោះ ប្រជាជនសូវៀតចង់ទិញលួចលាក់ទំនិញមកពីអាមេរិកណាស់ ។ គ្រាន់តែចំពោះខោចាស់មួយ ពួកសូវៀតហ៊ានបង់លុយឲ្យដល់ទៅ៥០ដុល្លារនោះ ។

តាមខ្ញុំដឹង ប្រទេសចិនក៏បើកឲ្យទេសចរណ៍អាមេរិកចូលទៅធ្វើទស្សនកិច្ចនៅកន្លែងខ្លះៗដែរ ។

ព័ត៌មានអស់នេះ ខ្ញុំបានដឹងតាមទស្សនាវដ្តីអាមេរិក ហើយនិងការពិភាក្សាជាមួយមិត្តភក្តិខ្លះៗ ។

ចំណុចសំខាន់ទៀត គឺសហរដ្ឋអាមេរិកលក់ស្រូវអង្ករឲ្យសូវៀតជាច្រើនឆ្នាំមកហើយ ។ នេះវាបង្ហាញឲ្យឃើញថាមានការទាក់ទងល្អជាងមុនឆ្ងាយណាស់បើប្រៀបធៀបទៅមុំឆ្នាំ១៩៦០ ។

បើយោងទៅតាមសកម្មភាពអស់នេះ ព្រមទាំងការពិភាក្សាគ្នា រវាងអាមេរិក និងសូវៀត ដើម្បីកំណត់ចំនួនសាស្ត្រាវុធបរមាណូ ឃើញថា ការទាក់ទងគ្នារវាងអាមេរិកនឹងសូវៀតកាន់តែរីកល្អឡើងៗ គឺថាឈានទៅរកសភាពការល្អប្រសើរ ។

## នយោបាយក្រៅប្រទេសនៃសហរដ្ឋអាមេរិកចំពោះគុយបា

ចំពោះនយោបាយអាមេរិកជាមួយគុយបា វាកាន់តែរីកចម្រើនល្អខាងផ្លូវទូត ។ ប្រទេសទាំងពីរចង់ធ្វើការទាក់ទងគ្នាល្អឡើងវិញ ។ គុយបា អាចនឹងបើកដៃមួយអនុញ្ញាតនាំទំនិញចូលពីអាមេរិកផង ។ គុយបា បានអនុញ្ញាតឲ្យអ្នកបើកបរទូកក្តោងជនជាតិអាមេរិក ចូលមកធ្វើទស្សនកិច្ចនៅក្នុងដែគុយបាមួយបាន ។ ប៉ុន្តែពួកអ្នកទាំងនោះមិនធ្វើសកម្មភាពអ្វីបានច្រើនទេ ។ នេះជាជំហានមួយទៅមុខយ៉ាងប្រសើរ ។ បើសិនជាមានការទាក់ទងពាណិជ្ជកម្មឡើងវិញ អាមេរិកអាចនឹងដោះដូរស្រូវអាមេរិកជាមួយស្ករគុយបា ។ សព្វថ្ងៃនេះ ស្ករថ្លៃណាស់នៅសហរដ្ឋអាមេរិកឯស្រូវវិញអាមេរិកមានច្រើនមែនទែន ។ សព្វថ្ងៃនេះ សូវៀត

លក់ស្រូវយ៉ាងថោកឲ្យទៅគុយបា ហើយនឹងទិញស្ករយ៉ាងថ្លៃមកវិញ ដើម្បីនឹងគាំទ្រសេដ្ឋកិច្ចគុយបា ។ បើសិនជាគុយបា អាចទាក់ទងពាណិជ្ជកម្មជាមួយនឹងសហរដ្ឋអាមេរិកបាន គុយបា ច្បាស់ជាឯករាជ្យម្ចាស់ការជាងមុន ។ អាមេរិកសង្ឃឹមថា គុយបា នឹងងាកទៅរករបបមូលធនវិញផង ។

ក្រុមហ៊ុនថ្នាំជក់នៃសហរដ្ឋអាមេរិក វាយតម្លៃយ៉ាងខ្ពស់ដល់ថ្នាំរបស់ គុយបា ។ បើសិនជា គុយបា អនុញ្ញាតឲ្យជនជាតិអាមេរិកដាំថ្នាំជក់ ឬកញ្ឆានៅគុយបាបាន ប្រទេសទាំងពីរ គុយបា និង អាមេរិក ច្បាស់ជាចំណេញទាំងអស់គ្នា ។

### នយោបាយក្រៅប្រទេសនៃសហរដ្ឋអាមេរិកចំពោះអឺរ៉ុប

អាមេរិកយកចិត្តទុកដាក់បំផុតចំពោះអឺរ៉ុប ពីព្រោះភាគីទាំងពីររកស៊ីដោះដូរគ្នាច្រើនណាស់ ។ អឺរ៉ុបជាផ្សារមួយសំខាន់ចំពោះទំនិញអាមេរិក ដូច្នេះហើយសេដ្ឋកិច្ចអាមេរិកក៏ពឹងផ្អែកជាច្រើនទៅលើអឺរ៉ុបដែរ ។ ម្យ៉ាងទៀត ទេសចរណ៍ជនជាតិអឺរ៉ុបដែលទៅធ្វើទស្សនកិច្ចនៅអាមេរិក ក៏នាំចូលរូបិយប័ណ្ណជាច្រើនឲ្យអាមេរិកដែរ ។

ខាងផ្នែកយោធា អាមេរិកតែងតែផ្តល់ជំនួយឲ្យអឺរ៉ុបជានិច្ចការពារកុំឲ្យមានការឈ្លានពានមកពីក្រៅបាន ។ អាមេរិក នៅតែបន្តការពារប្រទេសលោកសេរីពីកុម្មុយនីស្តដដែល ហើយនិងការពារភោគសម្បត្តិរបស់អាមេរិកនៅអឺរ៉ុបថែមទៀត ។

អាមេរិក មានមូលដ្ឋានសឹកជាច្រើននៅអឺរ៉ុប ហើយមូលដ្ឋាននោះនៅជាប់ជិតនឹងសហភាពសូវៀតណាស់ ។ មូលដ្ឋានសឹកអាមេរិកមិនគ្រាន់តែគំរាមកំញើញដល់កុម្មុយនីស្ត កុំឲ្យចូលឈ្លានពានទេ គឺថាវាអាចទប់ទល់នឹងការឈ្លានពានអ្វីទាំងអស់ដែលអាចកើតមាននៅក្នុងតំបន់នោះ ។

អាមេរិក វាយតម្លៃសេដ្ឋកិច្ច ហើយនិងយោធាយ៉ាងខ្លាំងដល់ច្រកសមុទ្រស៊ីប្រាល់តា ។ ច្រកសមុទ្រនេះស្ថិតនៅចន្លោះប្រទេសម៉ារ៉ុក និងអេស្ប៉ាញ ។ គឺជាផ្លូវទឹកមួយសំខាន់រវាងមជ្ឈិមបូព៌ា អឺរ៉ុបខាងកើត អាហ្វ្រិកខាងជើង ហើយនិងប្រទេសដ៏ទៃទៀតក្នុងសកលលោក ។

បើសិនជាច្រកសមុទ្រនេះត្រូវបិទ វានឹងប្រទេសដទៃទៀតក្នុងសកលលោក ។ បើសិនជាច្រកសមុទ្រនេះត្រូវបិទ វានឹងរារាំងដល់ការទាក់ទងពាណិជ្ជកម្មក្នុងសកលលោក នាំឲ្យខូចខាតដល់សេដ្ឋកិច្ចនៃប្រទេសជាច្រើន ។

ព្រែកជីក ស៊ុយអេ ជាផ្លូវទឹកមួយទៀត ចេញពីសមុទ្រម៉េឌីទែរ៉ាណេ ។ ប៉ុន្តែនៅក្នុងតំបន់នោះ មានការជ្រួលច្របល់ពេក ដូច្នេះផ្លូវទឹក ស៊ុយអេ មិនងាយបើកបរជាអចិន្ត្រៃយ៍ទេ ។

ខាងផ្នែកសេដ្ឋកិច្ច ហើយយោធា មានតែអឺរ៉ុបទេដែលជាមហាអំណាចមានកម្លាំង ព្រមទាំងគោលបំណងទប់ទល់កុម្មុយនីស្ត ។ ដូច្នេះអឺរ៉ុបជាសម្ព័ន្ធមិត្តធំបំផុតនៃសហរដ្ឋអាមេរិក ។ បើសិនជាអឺរ៉ុបធ្លាក់ទៅក្នុងកណ្តាប់ដៃកុម្មុយនីស្ត សហរដ្ឋអាមេរិកនៅឯកោតែម្នាក់ឯងហើយ ។ ដូច្នេះពិបាកទប់ទល់នឹងកុម្មុយនីស្តណាស់ ពីព្រោះវាអស់មានការដោះដូរពាណិជ្ជកម្ម ប្រេងកាត មូលដ្ឋានសឹក ។ល ។

ព័ត៌មានទាំងនេះ ខ្ញុំបានវាពីកាសែត ពីការពិភាក្សាជាមួយគេឯង ហើយនិងភ្នាក់ងារដទៃទៀតនៅសាលា សេ.អុី.អា ក្នុងរយៈពេលប្រាំបីឆ្នាំកន្លងមកនេះ ។

### នយោបាយក្រៅប្រទេសនៃសហរដ្ឋអាមេរិកចំពោះមជ្ឈិមបូព៌ា និងប្រទេសតតិយលោក

ចំពោះប្រទេសតតិយលោក នយោបាយទូទៅរបស់អាមេរិកគឺត្រូវផ្តល់ជំនួយខាងសេដ្ឋកិច្ច និងបច្ចេកទេសដល់ប្រទេសអស់នោះ ឲ្យសេដ្ឋកិច្ចហើយនិងរដ្ឋាភិបាលគេបានរឹងមាំ ។ ជាធម្មតាទេ គោលការរបស់អាមេរិកគឺធ្វើយ៉ាងណាឲ្យប្រទេសអស់នោះនៅក្នុងរបបមូលធននិយម ហើយអាចការពារខ្លួនពីកុម្មុយនីស្តបាន ។

ផែនការនេះធំណាស់ ហើយទាមទារឲ្យចំណាយប្រាក់កាក់អស់រាប់លានដុល្លារមួយឆ្នាំៗ ។ សហរដ្ឋអាមេរិកសង្ឃឹមថាអាចនឹងជួយពង្រឹងសេដ្ឋកិច្ចនៃប្រទេសអស់នោះបាន ហើយណែនាំឲ្យគេប្រកាន់ជំហរនយោបាយប្រឆាំងនឹងកុម្មុយនីស្តទៀត ។

សហរដ្ឋអាមេរិកប្រើកងទ័ពហើយអាវុធនៅក្នុងតំបន់ណាដែលមានប្រយុទ្ធក្តៅដើម្បីផ្តល់ជំនួយជាទីប្រឹក្សាហើយនិងអាវុធដល់ប្រទេសតតិយលោកដែលចង់ទប់ទល់នឹងការបះបោរកុម្មុយនីស្ត ។

ចំពោះព័ត៌មាននេះ អ្នកណាក៏អាចដឹងដែរ បើគេយកចិត្តទុកដាក់មើលទូរទស្សន៍និងទស្សនាវដ្តីអាមេរិក អាមេរិកតាមខ្ញុំដឹងនេះ ហើយជានយោបាយមូលដ្ឋាននៃសហរដ្ឋអាមេរិក ។

# ចម្លើយសារភាពរបស់ ហេង ពេជ ហៅ ឆន

## យុទ្ធជននៅមន្ទីរ ប-១ និងជាអតីតអនុរដ្ឋលេខាធិការ ក្រសួងសម្ភារសឹកនៃរណសិរ្សរួបរួមជាតិកម្ពុជា

**ដកស្រង់ចេញពីចម្លើយសារភាព ឯកសារJ០០១៨១**

ហេង ពេជ ហៅ ឆន អតីតជានិស្សិតនៅអតីតសហភាពសូវៀត ។ ឆន បានចូលរួមជាមួយរណសិរ្សរួបរួមជាតិកម្ពុជា ។ ក្រោយមក គាត់ចូលបម្រើការនៅក្នុងខុទ្ទកាល័យសម្តេចព្រះនរោត្តម សីហនុ នៅទីក្រុងប៉េកាំង និងជាអនុរដ្ឋលេខាធិការក្រសួងសម្ភារសឹក ។ នៅពេលយោធាខ្មែរក្រហមទទួលជ័យជម្នះ ឆន បានចូលបម្រើការនៅក្រសួងការបរទេសនៃរបបកម្ពុជាប្រជាធិបតេយ្យដោយមាននាទីជាយុទ្ធជន ហើយក្រោយមកគាត់ត្រូវបានចាប់ខ្លួនមកមន្ទីរស-២១ ។

ចម្លើយសារភាពរបស់ ហេង ពេជ ហៅ ឆន ដែលមានកម្រាស់៣៧ទំព័រ បានរៀបរាប់យ៉ាងច្រើនទាក់ទងទៅនឹងប្រវត្តិរូបសកម្មភាពដែលគាត់បានធ្វើ និងឈ្មោះអ្នកដែលគាត់ធ្លាប់ទាក់ទងដូចជា ស៊ាង ហ៊ីឡុង, ហាក់ ស៊ាងឡាយនី, ជា សាន, ដួន ប្រាសិទ្ធ, គ្រិន លាន, ប៉ុច ម៉ាក់បុរី និងមនុស្សមួយចំនួនទៀត ។ ឈ្មោះដែលបានរៀបរាប់នេះត្រូវបានចាប់ខ្លួន លើកលែងតែ ដួន ប្រាសិទ្ធ ម្នាក់ប៉ុណ្ណោះ ទោះបីមានចម្លើយសារភាពជាច្រើនបានឆ្លើយដាក់គាត់ក៏ដោយ ។ បើយោងតាមសាឡុត បាន ក្មួយបង្កើតរបស់ ប៉ុល ពត និងជាអគ្គលេខាធិការក្រសួងការបរទេសនៃរបបកម្ពុជាប្រជាធិបតេយ្យឆ្លើយបញ្ជាក់នៅក្នុងអង្គសវនាការកាត់ទោសមេដឹកនាំខ្មែរក្រហមថា អៀង សារី បាននិយាយផ្ទាល់ជាមួយ ប៉ុល ពត ថា ប្រសិនបើចាប់ខ្លួន ដួន ប្រាសិទ្ធ នោះក្រសួងការបរទេសនឹងត្រូវបិទទ្វារតែម្តង ។

នៅលើទំព័រចុងក្រោយនៃឯកសារចម្លើយសារភាព ហេង ពេជ ហៅ ឆន ត្រូវបានចុះហត្ថលេខាទទួលស្គាល់ដោយសាមីខ្លួនផ្ទាល់ រួមជាមួយនឹងអ្នកសួរចម្លើយឈ្មោះ ណុប នៅថ្ងៃ ទី១០ ខែមករា ឆ្នាំ១៩៧៧ ។ ឯកសារនេះវាយអង្គុលីលេខចប់ ដោយឈ្មោះ លាង ហួយ នៅថ្ងៃទី១៥ ខែមករា ឆ្នាំ១៩៧៧ ។

នៅក្នុងឯកសារចម្លើយសារភាពនេះដែរ ក៏មានការដកស្រង់ខ្លឹមសារពី ឌុច ដើម្បីបញ្ជូនបន្តទៅថ្នាក់លើចុះថ្ងៃទី១៦



ជៀ សាន ឬ ជា សាន



ប៉ុច ម៉ាក់បូរី

ខែមករា ឆ្នាំ១៩៧៧ ។ ជាការឆ្លើយតបវិញ ក៏មានចំណារលើក្រុបមុខនៃឯកសារនេះថា សម្ងាត់និងមានពាក្យសម្គាល់ៈ

១) ឯកសារនេះនាំឲ្យយល់ពីផែនការ បង្កប់ ស៊ើបការកសាងកម្លាំងក្បត់របស់ពួកសេរី ។

២) យល់ខ្សែចាត់តាំងវាមួយចំនួនក្នុងនោះ ចាប់អារម្មណ៍ពីសភាពការណ៍ សមមិត្ត ប្រាសិទ្ធ ។ សមមិត្ត ប្រាសិទ្ធ នេះលើកមុនមានចម្លើយថា គាត់បានណែនាំឲ្យអាពួក កា.ហ្វេ.បេ ធ្វើសកម្មភាពតទៀត ។ តាមពិតខ្ញុំ គួរចាប់អារម្មណ៍ដែរ ហើយគួរឲ្យគាត់ធ្វើការអីដែលមិនទាក់ទងបរទេស ។

៣) វាថា វាពង្រីកបានម្នាក់ ឈ្មោះ ស៊ាង ហ៊ីឡុង អតីតវិស្វករសេដ្ឋកិច្ចនៅប្រទេសអាល្លឺម៉ង់ខាងកើត សព្វថ្ងៃនៅខាងផ្នែកបច្ចេកទេសអាកាសចរស៊ីវិល ។

៤) ហាក់ សៀងឡាយនី ជាមេធំ ដឹងកិច្ចការទាំងអស់ ។ ថ្ងៃ១៩ ខែមករា ឆ្នាំ១៩៧៧ ។

ទោះបីយ៉ាងណា យើងមិនដឹងថាតាមរយៈចំណារ និងតាមរយៈការឆ្លើយរៀបរាប់ទាំងអស់របស់ ហេង ពេជ ហៅ ឆន ពិតឬយ៉ាងណានោះទេ ។ ខាងក្រោមនេះ ជាការដកស្រង់ខ្លឹមសារសង្ខេបចេញពីចម្លើយសារភាពរបស់ ឆន ផ្ទាល់ៈ

ខ្ញុំមានឈ្មោះដើម ហេង ពេជ ហៅ ឆន អាយុ៣៣ឆ្នាំ ។ ខ្ញុំមានស្រុកកំណើតនៅភូមិសំរោង ឃុំធ្លក ស្រុកទ្រាំង ខេត្តតាកែវ ។ ខ្ញុំមានឪពុកឈ្មោះ លាង ស៊ិន (ស្លាប់) មានស្រុកកំណើតនៅភូមិតាសេក ឃុំអង្គាញ់ ស្រុកទ្រាំង ខេត្តតាកែវ និងម្តាយឈ្មោះ ទូច គីម អាយុ៥៦ឆ្នាំ មានស្រុកកំណើតនៅភូមិសំរោង ឃុំធ្លក ស្រុកទ្រាំង ខេត្តតាកែវ ។

ក្រោយឆ្នាំ១៩៦០ ឪពុកម្តាយខ្ញុំទៅរស់នៅភូមិត្រពាំងកែស ឃុំញ៉ែងញ៉ង ស្រុកត្រាំកក់វិញដោយប្រកបរបរធ្វើស្រែ ។

ចំណែកឪពុកក្មេកខ្ញុំឈ្មោះ វ៉ា អាយុ៦៣ឆ្នាំ និងម្តាយក្មេកឈ្មោះ ហ៊ិន អាយុ៦០ឆ្នាំ ។ គាត់ទាំងពីរនាក់រស់នៅភូមិស្រះធុល ឃុំដើងរាស់ ស្រុកខត្តុគ តំបន់៣២ ប្រកបរបរធ្វើស្រែ ។ ឥឡូវគាត់ទាំងពីរនៅក្នុងសហករណ៍ ។

ខ្ញុំមានបងប្អូនបង្កើតប្រាំបីនាក់ ប្រុសបីនាក់ ស្រីប្រាំនាក់ ។ បងប្រុសបង្អស់ឈ្មោះ ហេង សុន្ទរ៉ា ជាអ្នកបច្ចេកទេសរងនៃ



អៀង សារី (រូបស្តាំ) អំឡុងពេលទទួលគណៈប្រតិភូបរទេស ។ រូបកណ្តាលគឺ ជួន ប្រាសិទ្ធ ដែលជាអ្នកបកប្រែភាសាអង់គ្លេស

អាកាសចរណ៍ស៊ីវិលពោធិចិនតុង និងប្អូនស្រីឈ្មោះ រី មានប្តីឈ្មោះផាន ធ្វើគ្រូបង្រៀន។ សព្វថ្ងៃមិនដឹងធ្វើអ្វីនិងនៅឯណាទេ។

ពីឆ្នាំ១៩៤៣-១៩៥៤ ខ្ញុំនៅផ្ទះជាមួយឪពុកម្តាយ និងនៅវត្ត។

ពីឆ្នាំ១៩៥៥-១៩៥៩ ខ្ញុំរៀននៅសាលាបឋមសិក្សាបំពេញវិជ្ជាព្រៃស្វណ្តែក ទីរួមស្រុកទ្រាំង ខេត្តតាកែវ។

ពីឆ្នាំ១៩៥៩ ខ្ញុំប្រឡងជាប់សញ្ញាបត្របឋមសិក្សា។

ពីឆ្នាំ១៩៥៩-១៩៦៤ ខ្ញុំរៀននៅវិទ្យាល័យព្រះឧទ័យ ខេត្តតាកែវ ហើយបានប្រឡងជាប់មធ្យមសិក្សាបត្រភាគទីមួយ។

ពីឆ្នាំ១៩៦៤-១៩៦៥ ខ្ញុំរៀនថ្នាក់បញ្ចប់ខាងគណិតសាស្ត្រ នៅវិទ្យាល័យស៊ីសុវត្ថិ ក្រុងភ្នំពេញ។

ពីឆ្នាំ១៩៦៥ ខ្ញុំប្រឡងជាប់មធ្យមសិក្សាបត្រភាគទីពីរខាងគណិតសាស្ត្រនៅវិទ្យាល័យគរុកោសល្យ។

នៅខែតុលា ឆ្នាំ១៩៦៥ ក្រសួងសិក្សាធិការជាតិជ្រើសរើសខ្ញុំឲ្យចេញទៅរៀនខាងផ្នែកសំណង់នៅសហភាពសូវៀត។ នៅខែវិច្ឆិកា ឆ្នាំ១៩៦៥ ហាក់ សៀងឡាយនី ហៅ ឡុន នាំខ្ញុំចូល «សហភាពខេមរនិស្សិត» ជាអង្គការនិស្សិតចំរើននៅសហភាពសូវៀត។ សហភាពខេមរនិស្សិតនេះបង្កើតឡើងនៅឆ្នាំ១៩៦២ និងជាអង្គការដែលមានរដ្ឋាភិបាលភ្នំពេញទទួលស្គាល់។

ក្រោយឆ្នាំ១៩៦៦ ដោយសារនិស្សិតចំរើនភាគច្រើនក្តាប់គណៈដឹកនាំនៃអង្គការនេះ ទើបរដ្ឋាភិបាលនៅភ្នំពេញបញ្ជាឲ្យទូតនៅទីក្រុងមូស្គូឈ្មោះ ហ៊ុយ កន្ធុល បង្កើតសមាគមថ្មីមួយទៀតឈ្មោះថា «សមាគមទូទៅនៃនិស្សិត និងអាណិកជនខ្មែរ» ហើយចោទ «សហភាពខេមរនិស្សិត» ថា «ខ្មែរក្រហម»។

ខ្ញុំរៀនភាសារុស្ស៊ីនៅសាលា «ស្ពានថ្មល់» ក្រុងមូស្គូរយៈពេលជិតមួយឆ្នាំ ក៏ចេះអាន និងសរសេរបាន។

នៅខែកក្កដា ឆ្នាំ១៩៦៦ ដោយមានការណែនាំពី ឡាយនី ខ្ញុំក៏ចូលរៀនសាលាសំណង់ក្រុងមូស្គូ ថ្នាក់ឆ្នាំទី១។ ម្យ៉ាងទៀតស្របនឹងបំណងខ្ញុំដែលគិតថា ដល់ពេលរៀនចប់ ខ្ញុំទៅធ្វើសាស្ត្រាចារ្យនៅវិទ្យាស្ថានបច្ចេកទេសខ្មែរ-សូវៀត នៅភ្នំពេញ។

ពេលនោះ ឡាយនី សាកល្បងឲ្យខ្ញុំរៀនទ្រឹស្តី ម៉ាក្ស ឡេនីនជាឯកសារសូវៀត និងឲ្យធ្វើសកម្មភាពផ្សេងៗដើម្បីប្រឆាំង



ហាក់ សៀងឡាយនី (រូបស្តាំបំផុត) និងគណៈប្រតិភូកម្ពុជាផ្សេងទៀតក្នុងអំឡុងពេលដំណើរទស្សនកិច្ចនៅប្រទេសអាល់បានី

រដ្ឋាភិបាលនៅភ្នំពេញ ។ នៅទីនោះ សាលាឲ្យខ្ញុំនៅបន្ទប់ជាមួយនិស្សិតរុស្ស៊ីពីរនាក់ទៀត ដែលមានអាយុប្រហែលពី២៥ ទៅ ៣០ឆ្នាំ ។ និស្សិតទាំងពីរនាក់នោះ តែងតែជួយខ្ញុំនៅពេលខ្ញុំមានការលំបាកខាងភាសាម្តងៗ ហើយអ្នកទាំងពីរបានពន្យល់រហូតធ្វើឲ្យខ្ញុំជឿស៊ប់ទៅលើសហភាពសូវៀត ។ ខ្ញុំយល់ថា អ្នកធ្វើបដិវត្តន៍ទាំងអស់នៅលើសកលលោកត្រូវតែពឹងផ្អែកលើសហភាពសូវៀត ហើយមានតែសូវៀតទេដែលអាចស្រោចស្រង់បដិវត្តន៍សកលលោកបាន ។

ខ្ញុំជឿស៊ប់លើ ឡេនីន ដែរ រហូតដល់ខ្ញុំហ៊ានលះបង់អ្វីៗទាំងអស់ដើម្បីបដិវត្តន៍សកលលោក និងដើម្បីកុម្មុយនីស្តអន្តរជាតិ ។ ជាញឹកញាប់ ឡាយនី សួរខ្ញុំថា លួមចូលអង្គការបដិវត្តន៍អន្តរជាតិមួយទៀតបានហើយឬនៅ? ទីបំផុត ខ្ញុំក៏យល់ស្របតាម ។

នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៦៦ ឡាយនី បាននាំខ្ញុំទៅចូល «កា.ហេ្ង.បេ» ។ ដំបូងខ្ញុំទៅជួបជាមួយអ្នកគ្រូបង្រៀនភាសារុស្ស៊ីរបស់គាត់ឈ្មោះ នីនណា អាឡិចសង់ដ្រូវណា ។ អ្នកគ្រូនោះក៏នាំខ្ញុំ និង ឡាយនី ទៅជួប គីសជាសកូវស្គី នៅក្នុងការិយាល័យទាក់ទងការងារជាមួយបរទេសរបស់គាត់ ដែលរូបភាពខាងក្រៅគាត់ជាប្រធានការិយាល័យទាក់ទងការងារជាមួយបរទេស តែរូបភាពសម្ងាត់គាត់ជា «កា.ហេ្ង.បេ» ។ ចំណែកការិយាល័យនេះជាចំហ គឺសម្រាប់ជំនួយការងាររៀនសូត្រដល់និស្សិតបរទេស ទាំងផ្នែកបច្ចេកទេស ក៏ដូចខាងនយោបាយ ហើយការិយាល័យនេះក៏ជួយសម្រួលជីវភាពនិស្សិតបរទេសដែរ ។

ពេលនោះ គីសជាសកូវស្គី ជាអ្នកទទួលស្គាល់ខ្ញុំ ។ ចំណែក នីនណា អាឡិចសង់ដ្រូវណា ជាសាក្សី ខ្ញុំក៏បានចូលកា.ហេ្ង.បេ ចាប់តាំងពីពេលនោះមក ។ នៅពេលលាគ្នា គីសជាសកូវស្គី ចាប់ដៃខ្ញុំយ៉ាងណែន ។ គាត់ជូនពរឲ្យខ្ញុំទទួលបានជ័យជម្នះលើគ្រប់ភារកិច្ច ។ គាត់ផ្តាំថា បើខ្ញុំមានបញ្ហាអ្វី សូមទាក់ទង និងទទួលបញ្ជាពី ឡាយនី ហើយរាយការណ៍ឲ្យ ឡាយនី ។

ចាប់តាំងពីដើមឆ្នាំ១៩៦៧មក ឡាយនី បានតម្រង់ទិសរបស់ខ្ញុំឲ្យបង្កើនការយល់ដឹងទ្វេដង អំពីបញ្ហារបស់ប្រទេសសង្គមនិយម ប្រទេសកំពុងលូតលាស់ ដែលត្រូវពឹងផ្អែកលើសហភាពសូវៀត ។ ប្រសិនបើប្រទេសនោះចង់ធ្វើអ្វីមួយ ត្រូវសួរមតិសូវៀតសិន បើសូវៀតយល់ព្រមទើបអាចធ្វើបាន ។

ទិសដៅមួយទៀតគឺ ឡាយនី ឲ្យខ្ញុំខំរៀនបច្ចេកទេស និងស្រាវជ្រាវផ្នែកសំណង់ ។ ឡាយនី ប្រគល់ភារកិច្ចឲ្យខ្ញុំថា នៅពេលរៀនចប់គាត់ឲ្យខ្ញុំមកក្តាប់ «វិទ្យាស្ថានបច្ចេកទេសមិត្តភាពខ្មែរសូវៀត» នៅភ្នំពេញ ព្រោះវិទ្យាស្ថាននេះជារបស់សហភាពសូវៀត ។ គាត់បានណែនាំវិធីគ្រប់គ្រងវិទ្យាស្ថាននេះដូចតទៅៈ

ទី១) លើកអត្តភាពសូវៀត តាមការយល់ដឹង និងអនុវត្តបច្ចេកទេស វិទ្យាសាស្ត្រសូវៀត ។ ឲ្យឃើញបច្ចេកទេសសូវៀតខ្ពស់ ហើយជ្រៅ ។ សូវៀតជាមហាអំណាចធំជាងគេលើសកលលោកខាងបច្ចេកទេស ។

ទី២) យកបច្ចេកទេសសូវៀតទៅអនុវត្តតាមរោងចក្រសហគ្រាស ការដ្ឋានសំណង់ផ្សេងៗ ដែលធ្វើឲ្យឥទ្ធិពលសូវៀតកាន់តែខ្លាំង ហើយយូរអង្វែងទៅមុខ ។ សូវៀតនឹងឈានទៅក្តាប់ប្រទេសកម្ពុជាទាំងមូល ។

នៅចុងឆ្នាំ១៩៦៧ ឡាយនី ឲ្យខ្ញុំចេញពី «សហភាពខេមរនិស្សិត» ដើម្បីរៀបចំខ្លួនចូលមកប្រទេស ព្រោះបើខ្ញុំនៅជាខ្មែរក្រហមតទៅទៀត ខ្ញុំមិនអាចចូលប្រទេសបានទេ ។

ខ្ញុំក៏ដាក់ពាក្យចេញពី «ខេមរនិស្សិត» ។ ឡាយនី ឲ្យខ្ញុំសម្រួលការទាក់ទងជាមួយទូតឡើងវិញ ។ ជាបណ្តើរៗ ខ្ញុំបានធ្វើតាមការណែនាំរបស់គាត់ ។ ទូតកាន់តែរាប់រកខ្ញុំវិញ ព្រោះជាភារកិច្ចរបស់ទូតដែរ ដើម្បីអូសទាញនិស្សិត «ក្រហម» ឲ្យចុះចូលមកស្ថានទូតវិញ ។

នៅដើមឆ្នាំ១៩៦៩ មានគណៈប្រតិភូមួយក្រុមដឹកនាំដោយ ឡុង បូរ៉េត ទៅបញ្ចាំងកុននៅពិធីបុណ្យមួយនៅក្រុងមូស្គូ ។ ខ្ញុំក៏ទៅប្រាប់ ឡាយនី ថាខ្ញុំធ្លាប់ស្គាល់ ឡុង បូរ៉េត កាលពីខ្ញុំនៅតូចព្រោះខ្ញុំនៅវត្តជាមួយលោកគ្រូសូត្រ ហ៊ូ ដែលត្រូវជាបងប្អូនគាត់ ។

ប៉ុន្មានថ្ងៃក្រោយមក ស្ថានទូតកម្ពុជាប្រចាំប្រទេសសូវៀតអញ្ជើញគណៈប្រតិភូ ឡុង បូរ៉េត និងនិស្សិតខ្មែរនៅខាងរដ្ឋាភិបាលទៅហូបបាយនៅស្ថានទូត ។ ជា សាន ក៏ខ្ទេសពីសភាពការណ៍និស្សិតខ្មែរនៅសហភាពសូវៀត ។ គាត់បង្ហាញ ឡុង បូរ៉េត ថាមកដល់សព្វថ្ងៃនេះមានខ្មែរក្រហមចុះចូលខ្លះហើយ ដូចជាខ្ញុំជាដើម ។ ខ្ញុំក៏និយាយប្រាប់ ឡុង បូរ៉េត ថា «ខ្ញុំធ្លាប់ឃើញលោក

កាលខ្ញុំនៅវត្តព្រៃមៀន ជាមួយគេជគុណ ហ៊ូ ត្រូវជាបងប្អូនលោក ។ ឡុងបូរ៉េតក៏និយាយថា "ល្អហើយបើមករកទូតវិញ" ។

នៅខែមិថុនា ឆ្នាំ១៩៦៩ ជា សាន ហៅខ្ញុំឲ្យចូលជាមួយអគ្គការរដ្ឋាភិបាលពីរគឺសង្គមរាស្ត្រនិយម និងសមាគមទូទៅនៃនិស្សិត និងអណិកជនខ្មែរនៅសហភាពសូវៀត ដើម្បីរាយការណ៍ទៅរដ្ឋាភិបាលភ្នំពេញដើម្បីឲ្យខ្ញុំបានរួចខ្លួន ។ នៅខែកក្កដា ឆ្នាំ១៩៦៩ ឡាយនី ចាត់តាំងខ្ញុំឲ្យចូលមកប្រទេសដើម្បីក្តាប់សភាពការណ៍នៅសាលាបច្ចេកទេសមិត្តភាពខ្មែរ-សូវៀត ។

ឡាយនី បញ្ជាក់ថា ភារកិច្ច និងការទាក់ទង គឺត្រូវជួបជាមួយសាស្ត្រាចារ្យសូវៀតម្នាក់ឈ្មោះ គូឌីស៊ីន នៅក្នុងសាលាបច្ចេកទេសនេះស្រាប់ ។ គូឌីស៊ីន ធ្លាប់បង្រៀនខ្ញុំនៅសាលាសំណង់ក្រុងម៉ូស្គូ អំពី "ភាពជាប់នៃវត្ថុធាតុ" ។

ទទួលភារកិច្ចពី ឡាយនី រួចហើយ ខ្ញុំបានប្រាប់ ជា សាន ឲ្យធ្វើលិខិតឆ្លងដែនឲ្យខ្ញុំ ថាទៅមើលឪពុកឈឺធ្ងន់ ។ ជា សាន ធ្វើលិខិតឆ្លងដែនឲ្យខ្ញុំ ហើយប្រគល់កូនសំបុត្រមួយតូចឲ្យខ្ញុំសម្រាប់ធានា ។ ខ្ញុំមិនអស់ចិត្តនឹងសំបុត្រធានា ក៏ខ្ចីលុយ ជា សាន ១០០ដុល្លារថែមទៀត ដើម្បីឲ្យកក់ក្តៅ ។

ប្រហែលពាក់កណ្តាលខែកក្កដា ឆ្នាំ១៩៦៩ ខ្ញុំចេញដំណើរពីម៉ូស្គូមកភ្នំពេញ ។ ពេលចេញដំណើរ ឡាយនី ប្រគល់កាំភ្លើងខ្លីមួយដើមឲ្យខ្ញុំទុកសម្រាប់ការពារខ្លួន ។

មកដល់វាលយន្តហោះពោធិចិនតុង គិញឃាត់ខ្ញុំ ។ ខ្ញុំក៏ប្រគល់កាំភ្លើងខ្លីឲ្យ បន្ទាប់មកគិញក៏យកខ្ញុំទៅដាក់នៅស្នងការដ្ឋានប៉ូលិសពិសេស ។ យប់ជ្រៅ គិញឲ្យបងខ្ញុំឈ្មោះ ហេង សុន្ទរ៉ា អ្នកបច្ចេកទេសរងនៅអាកាសចរណ៍ស៊ីវិលពោធិចិនតុងមកធានាខ្ញុំឲ្យនៅក្រៅឃុំ ។

ស្អែកឡើង គិញឲ្យបងខ្ញុំនាំខ្ញុំទៅការដ្ឋានប៉ូលិសដដែលដើម្បីសួរនាំ ។ គិញបានចោទខ្ញុំថាជាខ្មែរក្រហម និងបានសួរពីប្រវត្តិរូបខ្ញុំ និងពីបញ្ហានិស្សិតនៅម៉ូស្គូ ។ ខ្ញុំប្រាប់ថា ពីមុនខ្ញុំជាខ្មែរក្រហម ឥឡូវខ្ញុំចុះចូលជាមួយទូតហើយ ។ គិញថាមិនទាន់ឃើញសេចក្តីរាយការណ៍ពីស្ថានទូតនៅទីក្រុងម៉ូស្គូមកដល់ទេ ប៉ុន្តែគិញឲ្យខ្ញុំនៅក្រៅឃុំសិន ។

ដូច្នេះ ដើម្បីបង្វែងដានគិញ ខ្ញុំក៏ទៅសួរឪពុកនៅស្រុកបានពីរបីថ្ងៃ ក៏ត្រឡប់មករកជួបធ្វើការជាមួយ គូឌីស៊ីន វិញ ។ ខ្ញុំប្រាប់ គូឌីស៊ីន តាមភារកិច្ចដែល ឡាយនី ប្រគល់ឲ្យខ្ញុំកាលពេលនៅម៉ូស្គូ ។ គូឌីស៊ីន ពន្យល់ខ្ញុំយ៉ាងយូរនៅក្នុងមន្ទីរស្រាវជ្រាវផ្នែកសំណង់នៅសាលាបច្ចេកទេសមិត្តភាពខ្មែរ-សូវៀត អំពីគ្រោះថ្នាក់ដល់សូវៀតទៅអនាគត ដែលចង់យកសាលានេះធ្វើជាមជ្ឈមណ្ឌលដើម្បីបម្រើនយោបាយសូវៀត ។

ចំណែកបញ្ហាបច្ចេកទេស គូឌីស៊ីន ពន្យល់ខ្ញុំអំពីសំណង់ត្រូវស្រាវជ្រាវ និងប្លង់អគារ រោងចក្រ ។ បញ្ហារ៉ែ ដែលសូវៀតមានផែនការចង់រុករក និងបញ្ហាថាមពលប្រេងកាតនៅបាតសមុទ្រ ដែលសូវៀតចង់ជួយខ្វងយក ។

គូឌីស៊ីន ឲ្យខ្ញុំស្រាវជ្រាវ ដើម្បីពេលខ្ញុំត្រឡប់មកវិញចូលក្តាប់មន្ទីរស្រាវជ្រាវខាងផ្នែកសំណង់ ដែលទៅថ្ងៃមុខបញ្ជាក់ឲ្យឃើញថាបច្ចេកទេសសូវៀតសម្បើម ។

នៅខែសីហា ខ្ញុំទៅធ្វើលិខិតឆ្លងដែនចេញទៅសូវៀតវិញ ។ គិញទាររកសំបុត្រពី ជា សាន ។ ខ្ញុំបង្ហាញសំបុត្រធានារបស់ ជា សាន ដែលក្នុងនោះដាក់ថា "មកសួរឪពុកឈឺធ្ងន់" ។ គិញក៏សម្អុតខ្ញុំថា បើនៅតែធ្វើជាខ្មែរក្រហមទៀត មកលើកក្រោយគេនឹងសម្លាប់ចោល ។ គិញក៏ឲ្យលិខិតឆ្លងដែនមកខ្ញុំ ព្រោះគេទើបនឹងឃើញសេចក្តីរាយការណ៍របស់ទូតមកដល់ ។

ខ្ញុំត្រឡប់ទៅដល់ម៉ូស្គូវិញ នៅខែសីហា ឆ្នាំ១៩៦៩ ។ ខ្ញុំរាយការណ៍ឲ្យ ឡាយនី ពីហេតុការណ៍ដែលបានកើតឡើង ។

នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ មានរដ្ឋប្រហារនៅភ្នំពេញ ហើយនៅថ្ងៃទី១៩ ខែមីនា ឆ្នាំ១៩៧០ សម្តេច សីហនុ ចេញពីម៉ូស្គូ ទៅប៉េកាំង ។

នៅថ្ងៃទី២៣ ខែមីនា ឆ្នាំ១៩៧០ មានសេចក្តីថ្លែងការណ៍ "៥ ខ" ប្រកាសបង្កើតរណសិរ្សរួបរួមជាតិកម្ពុជា និងមានការអំពាវនាវឲ្យនិស្សិតនៅក្រៅប្រទេសទាំងអស់ចូលក្នុងរណសិរ្សនៅប៉េកាំង ដើម្បីតែងតាំងរដ្ឋាភិបាលស្របច្បាប់មួយតស៊ូប្រឆាំងនឹងរដ្ឋប្រហារ ។

នៅចុងខែមីនា ឆ្នាំ១៩៧០ ឡាយនី ចាត់តាំងខ្ញុំឲ្យមកបង្កប់នៅប៉េកាំង ។ ចំណែកការទាក់ទង ឡាយនី ប្រាប់ថាគាត់មកតាមក្រោយឆាប់ៗ ។

បន្ទាប់មក ខ្ញុំបានទៅទាក់ទង ជា សាន អំពីដំណើរមកប៉េកាំង ។ ជា សាន ឲ្យខ្ញុំសរសេរសេចក្តីគាំទ្រមួយច្បាប់ដល់សេចក្តីថ្លែងការណ៍២៣ ខែមីនា របស់សម្តេច សីហនុ ។

ថ្ងៃទី១១ ខែមេសា ឆ្នាំ១៩៧០ ខ្ញុំមកដល់ប៉េកាំង ។ ចិនយកខ្ញុំទៅនៅ "សណ្ឋាគារមិត្តភាព" ។ ថ្ងៃទី១២ ខែមេសា ឆ្នាំ១៩៧០ ចិននាំខ្ញុំទៅជួបសម្តេច សីហនុ នៅឯវិមានទទួលភ្ញៀវរដ្ឋ ។ នៅទីនោះ ខ្ញុំធ្វើសេចក្តីថ្លែងការណ៍មួយច្បាប់ ចាក់ផ្សាយផ្ទាល់តាមវិទ្យុប៉េកាំងជាភាសាខ្មែរគាំទ្រសេចក្តីថ្លែងការណ៍ថ្ងៃទី២៣ ខែមីនា ឆ្នាំ១៩៧០ ហើយខ្ញុំបានអំពាវនាវឲ្យយុវជនទាំងនៅក្នុងប្រទេស ទាំងនៅក្រៅប្រទេសឲ្យក្រោកឡើងតស៊ូ ។ សម្តេច សីហនុ ប្រាប់គេឲ្យចាំខ្ញុំ ដើម្បីទៅធ្វើការក្នុងខុទ្ទកាល័យរបស់ព្រះអង្គជាមួយអ្នកហែហមព្រះអង្គ៥ - ៦នាក់ទៀត ។

មួយអាទិត្យក្រោយមក ឡាយនី ក៏ទៅដល់ប៉េកាំង ។ ខ្ញុំរាយការណ៍ឲ្យគាត់ពី សម្តេច សីហនុ ដែលព្រះអង្គមានសិទ្ធិសេរីភាពធ្វើនយោបាយពេញលេញ ។ សេចក្តីថ្លែងការណ៍របស់ព្រះអង្គ ទើបនឹងបានទទួលការគាំទ្រពីបង១បីនាក់ នៅក្នុងប្រទេសចាក់ផ្សាយតាមវិទ្យុប៉េកាំង ប៉ុន្មានថ្ងៃមុន ។ ឡាយនី ប្រគល់ភារកិច្ចបន្ថែមឲ្យខ្ញុំទៀត គឺដំបូងបង្អស់ឲ្យសម្តេច សីហនុ ធ្វើដូចតទៅនេះ ៖

◆ ត្រូវធ្វើកម្មវិធីនយោបាយមួយនៅប៉េកាំង

◆ ត្រូវចាត់តាំងគណៈកម្មាធិការកណ្តាលរណសិរ្សរួបរួមជាតិកម្ពុជាមួយនៅប៉េកាំង

◆ត្រូវចាត់តាំងការិយាល័យនយោបាយរបស់គណៈកម្មាធិការកណ្តាលនេះ ដើម្បីងាយស្រួល ដំណើរការការងារជាអចិន្ត្រៃយ៍ ។ ចាត់តាំងអង្គការរណសិរ្សនេះរួចហើយ ទើបយកគណៈកម្មាធិការកណ្តាលរណសិរ្សរួបរួមជាតិកម្ពុជា ជំនួសឲ្យរដ្ឋសភា ដើម្បីតែងតាំងរដ្ឋាភិបាលឲ្យស្របទៅតាមសេចក្តីថ្លែងការណ៍ថ្ងៃ២៣ មីនា ឆ្នាំ១៩៧០ របស់សម្តេច សីហនុ ។

ទន្ទឹមនឹងនេះ ឡាយនី ប្រាប់ថា ត្រូវធ្វើម៉េចឲ្យខ្ញុំ និងគាត់បានចូលក្នុងអង្គការខាងលើនេះ ទាំងរណសិរ្ស ក៏ដូចជារដ្ឋាភិបាល ។ ទទួលការណែនាំនេះហើយ ខ្ញុំយកទៅនិយាយនឹងសម្តេច សីហនុ និងបំផុសក្នុងខុទ្ទកាល័យរបស់ព្រះអង្គ ។ ក្រោយមកសម្តេច សីហនុ ក៏បញ្ជាឲ្យគេធ្វើតាមចំណុចខាងលើ ។

នៅចុងខែមេសា ឆ្នាំ១៩៧០ អង្គការចាត់តាំងរបស់រណសិរ្ស ក៏ធ្វើចប់ដោយ

◆ សម្តេច សីហនុ ទទួលដំណែងជាប្រមុខរដ្ឋដដែល តែបន្ថែមព្រះអង្គជាប្រធានរណសិរ្សរួបរួមជាតិកម្ពុជា

◆ ប៉ែន នុត ទទួលតំណែងជាប្រធានការិយាល័យនយោបាយនៃគណៈកម្មាធិការកណ្តាលរណសិរ្សរួបរួមជាតិកម្ពុជា ។

ឯ ឡាយនី និងខ្ញុំ ក៏បានចូលជាសមាជិកគណៈកម្មាធិការកណ្តាលរណសិរ្សរួបរួមជាតិកម្ពុជាដែរ ។

ក្រោយពីចាត់តាំងអង្គការរណសិរ្សរួចហើយ នៅថ្ងៃទី១ ខែ៥ ឆ្នាំ១៩៧០ ប្រធាន ម៉ៅ សេទុង ទទួលសម្តេច សីហនុ និងខ្មែរទាំងអស់ដែលទៅធ្វើរណសិរ្សនៅប៉េកាំង ។

នៅថ្ងៃទី៥ ខែឧសភា ឆ្នាំ១៩៧០ សម្តេច សីហនុ ប្រកាសចំពោះអ្នកកាសែត នៅវិមានប្រជាជននាក្រុងប៉េកាំង នូវការតែងតាំងរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជាដែលមានសម្តេច ប៉ែន នុត ជារដ្ឋមន្ត្រីទីមួយ ។

នៅថ្ងៃទី២០ ខែឧសភា ឆ្នាំ១៩៧០ លោកប្រធាន ម៉ៅ សេទុង ចេញសេចក្តីថ្លែងការណ៍អំពាវនាវឲ្យប្រជាជនសកលលោកក្រោកឡើងវាយចក្រពត្តិអាមេរិក និងបរិវារឲ្យបរាជ័យ ក្នុងនោះមានចែងថា ខ្ញុំគាំទ្រស្មារតីតស៊ូរបស់សម្តេច សីហនុ ។

នៅខែកក្កដា ឆ្នាំ១៩៧០ ប៉ែន នុត តែងតាំងខ្ញុំជាអនុរដ្ឋលេខាធិការក្រសួងសម្ភារសឹក ដោយក្រសួងនេះមានភារកិច្ចទទួលជំនួយសឹកពីចិន និងកូរ៉េ ។ ចំណែក ឡាយនី ជាអនុរដ្ឋលេខាធិការក្រសួងការបរទេស ។

នៅចុងខែកក្កដា ឆ្នាំ១៩៧០ ឡាយនី ទៅមូស្គូ ហើយនៅខែ៨ ឆ្នាំ១៩៧០ គាត់ក៏ត្រឡប់មកប៉េកាំង វិញ ។ គាត់ប្រាប់ខ្ញុំថា រដ្ឋាភិបាលសូវៀតមិនទាន់ទទួលស្គាល់រដ្ឋាភិបាលរួបរួមជាតិកម្ពុជាទេ ។ បើចង់ឲ្យរដ្ឋាភិបាលសូវៀតទទួលស្គាល់រដ្ឋាភិបាលរួមរួមជាតិកម្ពុជា ទាល់តែមានអ្នកដឹកនាំពីក្នុងប្រទេស ទៅជួបគេឯក្រុងមូស្គូសិន ។ ខណៈនោះ ឡាយនី ក៏បានបង្ហាញសញ្ញាបត្ររបស់គាត់ឲ្យខ្ញុំមើល ៖ សញ្ញាបត្រវិស្វករថាមពលវារីអគ្គិសនី និងសញ្ញាបត្រច្បាប់ ។ គាត់ថាយកសញ្ញាបត្រទៅបង្ហាញសម្តេច សីហនុ និង ប៉ែន

នុត ព្រោះសម្តេចទាំងពីរនៅនិយមអ្នកមានសញ្ញាបត្រណាស់ ។ ប៉ុន្តែសំខាន់គាត់ចង់បង្ហាញសញ្ញាបត្រច្បាប់ឲ្យ ប៉ែន នុត ស្គាល់គាត់ថាជាអ្នកច្បាប់ និងឲ្យ ប៉ែន នុត ចាត់តាំងគាត់ឲ្យចេញទៅធ្វើសន្និសីទអន្តរជាតិ ។

ចំណែកខ្ញុំ ក្រៅពីដំណែងជាសមាជិកគណៈកម្មាធិការកណ្តាលរណសិរ្សរួបរួមជាតិកម្ពុជា និងជាអនុរដ្ឋលេខាធិការក្រសួងសម្ភារសឹក ។ ខ្ញុំមាននាទីពីរទៀត ដែលជាការងារប្រចាំថ្ងៃគឺ ១) ជាសមាជិកគណជីវភាពនៅសណ្ឋាគារមិត្តភាព ផ្នែកខាងខ្មែរ និង ២) យុវជននៃការិយាល័យឃោសនាការនៃរណសិរ្សរួបរួមជាតិកម្ពុជានៅប៉េកាំង ។

ការិយាល័យនេះផ្សាយឯកសារផ្សេងៗចេញពីការិយាល័យនយោបាយនៃគណៈកម្មាធិការកណ្តាលរណសិរ្សរួបរួមជាតិកម្ពុជា ផ្សាយអត្ថបទវិទ្យុផ្សាយសំឡេងរណសិរ្សរួបរួមជាតិកម្ពុជា និង អា.កា.អ៊ី ជាភាសាបារាំង ។

ពេលនោះ ជួន ប្រាសិទ្ធ ជាសមាជិកបម្រុងនៃការិយាល័យនយោបាយនៃរណសិរ្សរួបរួមជាតិកម្ពុជាជាអ្នកទទួលខុសត្រូវការិយាល័យឃោសនាការនេះ ។ ប្រាសិទ្ធ សព្វថ្ងៃធ្វើការនៅផ្នែកនយោបាយនៃក្រសួងការបរទេសកម្ពុជាប្រជាធិបតេយ្យ ។ ប្រាសិទ្ធ ណែនាំខ្ញុំឲ្យបំពេញភារកិច្ច ។

ជួន ប្រាសិទ្ធ ជាអ្នកក្តាប់បញ្ហាសន្និសីទអន្តរជាតិ ។ ប្រហែលឆ្នាំ១៩៥០ ជួន ប្រាសិទ្ធ ទៅរៀននៅស្រុកបារាំង ហើយការតស៊ូរបស់គាត់ជាប់នឹងបក្សកុម្មុយនីស្តបារាំង ។ បក្សកុម្មុយនីស្តបារាំង ជាបក្សសេរី ដែលរណបបក្សកុម្មុយនីស្តសូវៀត ។ ក្រោយពេលដេញអាណានិគមនិយមបារាំងចេញពីប្រទេសកម្ពុជា ជួន ប្រាសិទ្ធ ក៏ត្រឡប់មកប្រទេសវិញ ។ គាត់បាននាំប្រពន្ធបារាំងមកជាមួយ ហើយគាត់ធ្វើការនៅរទេះភ្លើងភ្នំពេញ ។

នៅឆ្នាំ១៩៦៣ ជួន ប្រាសិទ្ធ ក៏រត់ទៅនៅប្រទេសបារាំងវិញ ដោយសារគាត់ត្រូវបានចោទថា ជាអ្នកបំបះបំបោរកម្មកររទេះភ្លើង ។ នៅចុងឆ្នាំ១៩៧០ ជួន ប្រាសិទ្ធ មកធ្វើការក្នុងរណសិរ្សរួបរួមជាតិកម្ពុជាឯទីក្រុងប៉េកាំង ដោយគាត់មាននាទីជាសមាជិកបម្រុងនៃការិយាល័យនយោបាយនៃគណៈកម្មាធិការកណ្តាលរណសិរ្សរួបរួមជាតិកម្ពុជា ។ ក្រោយមក គាត់មាននាទីដូចជាៈ

- ជារដ្ឋមន្ត្រីក្រសួងសម្របសម្រួលនៃការតស៊ូប្រជាជននៃរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា នៅប៉េកាំង ដើម្បីទាក់ទងជាមួយអ្នកក្នុងប្រទេស ។
- ជាអ្នកក្តាប់បញ្ហាសន្និសីទអន្តរជាតិ ដែលជាសន្និសីទអង្គការមហាជនផ្សេងៗនៅលើសកលលោក គាំទ្រការតស៊ូរបស់ប្រជាជនកម្ពុជាប្រឆាំងនឹងចក្រពត្តិអាមេរិក និងបរិវារ ។

នៅឆ្នាំ១៩៧១ អង្គការក្នុងប្រទេសបានទៅដល់ក្រុងប៉េកាំង ។ ឡាយនី ឲ្យខ្ញុំទៅស្នើអង្គការចូលមកក្នុងប្រទេស ។ ខ្ញុំបានស្នើអង្គការ ហើយអង្គការក៏ឲ្យខ្ញុំត្រៀមការងារមួយចំនួនដូចជា ៖ ១) អប់រំរៀនសូត្រ និង២) លត់ដំពលកម្ម ។ ពេលនោះ ឡាយនី ក៏បានប្រាប់ខ្ញុំឲ្យបន្ថយការទាក់ទងជាមួយសម្តេច សីហនុ និង ប៉ែន នុត ។

នៅឆ្នាំ១៩៧២ ខ្ញុំត្រៀមខ្លួនចូលប្រទេសវិញ ។ ខ្ញុំបំពេញលក្ខណៈសម្បត្តិជ្រើសរើសរបស់អង្គការ មានដូចជាៈ

- ត្រូវសកម្មគ្រប់ការងារទាំងអស់ ទាំងការងារស្នូលប្រចាំថ្ងៃ ទាំងការលត់ដំពលកម្មត្រៀមចូលប្រទេស ។
- ត្រូវដាច់ខាតព្រោះលទ្ធភាពស្លាប់តាមផ្លូវ៥០ភាគរយ ។

នៅខែឧសភា ឆ្នាំ១៩៧៣ អង្គការសម្រេចឲ្យខ្ញុំចូលមកក្នុងប្រទេស ។ ជួន ប្រាសិទ្ធ ហៅខ្ញុំទៅជួបក្នុងបន្ទប់របស់គាត់អស់ជាងកន្លះម៉ោង ។ គាត់ឲ្យខ្ញុំទទួលភារកិច្ចជាក់ស្តែងរបស់កា.ហ្វេ.បេ ពីឡាយនី ។

ពេលរៀបចេញដំណើរ ឡាយនី ប្រគល់ភារកិច្ច៣ខឲ្យខ្ញុំដូចជា ៖ ១) បង្កប់ខ្លួន លត់ដំយ៉ាងតិចបីឆ្នាំនៅក្នុងប្រទេស ២) ក្តាប់សភាពការណ៍ជាក់ស្តែងនៅតាមកន្លែងមួយៗ ៣) កសាងកម្លាំង កា.ហ្វេ.បេ ។

ចំណែកការទាក់ទងពេលទៅដល់ប្រទេស ឡាយនី ប្រាប់ថា បើមិនជួប គ្រិនលាន ហៅ សំ អតីតវិស្វករអគ្គិសនី ក្រុងមូស្គូ ធ្វើការនៅសាលាបច្ចេកទេស ឬក៏ជួប ប៉ុច ម៉ាក់បូរី ហៅ សោ អតីតវិស្វកររ៉ែ ក្រុងមូស្គូ ធ្វើការនៅក្រុមរ៉ែដែរ ។ បើជួបឲ្យអនុវត្តតាមភារកិច្ច៣ខាងលើ បើមិនជួបឲ្យចាំពេលគាត់ទៅដល់ ។

មុននឹងបែកគ្នា ឡាយនី ប្រាប់ខ្ញុំឲ្យជឿទុកចិត្តលើ ជួន

ប្រាសិទ្ធ ហើយចាប់ពីពេលនោះហើយ ដែលខ្ញុំដឹងថា ដួន ប្រាសិទ្ធ ជាមេខ្ញុំ ។

នៅចុងខែឧសភា ឆ្នាំ១៩៧៣ ខ្ញុំចេញដំណើរពីប៉េកាំងចូលមកប្រទេស ។ មកដល់ហាណូយ អង្គការឲ្យខ្ញុំធ្វើការនៅក្រសួងវិទ្យុមួយរយៈសិនព្រោះខ្វះមនុស្ស ។ នៅក្រសួងវិទ្យុ ខ្ញុំជួបនឹង ប៉ុច ម៉ាក់ប៉ូវី ហៅ សៅ ។ ខ្ញុំប្រាប់គាត់ពីភារកិច្ចដែល ឡាយនី ណែនាំ ។

នៅទីនោះ អង្គការឲ្យខ្ញុំធ្វើការនៅផ្នែកបកប្រែភាសារ៉ូម៉ាំងមកភាសាខ្មែរ ដែល សៅ ជាអ្នកទទួលខុសត្រូវ ។ សៅ ឲ្យខ្ញុំបកប្រែដោយធ្វើយ៉ាងណាបំផ្លើស ឬបង្វែរមាគ៌ា ជាពាក្យមួយម៉ាត់ពីរម៉ាត់ ឬជាឃ្លាខ្លះៗ ជាពិសេសកន្លែងណាដែលទូពុម្ពចាប់អក្សរមិនបានច្បាស់ ដើម្បីកុំឲ្យអង្គការចាប់ថ្នាក់បាន ។ ខ្ញុំធ្វើការនេះជាមួយ សៅ អស់រយៈពេលជិតមួយឆ្នាំ ។

នៅខែឧសភា ឆ្នាំ១៩៧៤ ឡាយនី ទៅដល់ក្រសួងវិទ្យុ ។ ខ្ញុំបានរាយការណ៍ឲ្យ ឡាយនី អំពីភារកិច្ចដែលខ្ញុំបានបំពេញជាមួយ សៅ ។

បន្ទាប់ពីឡាយនីបានទៅដល់បន្តិច អង្គការសម្រេចឲ្យខ្ញុំចូលមកក្នុងប្រទេស ។ ពេលខ្ញុំរៀបចេញដំណើរ ឡាយនី ផ្ដាំឲ្យខ្ញុំប្រយ័ត្នប្រយែងជាទីបំផុត គឺត្រូវធ្វើអ្វីកុំឲ្យប្លែកគេ ព្រោះខ្ញុំមិនបានរស់នៅក្នុងប្រទេសជិត៩ឆ្នាំហើយ ។ ឡាយនី ប្រាប់ខ្ញុំឲ្យទៅជួប គ្រិនលាន ហៅ សំ នៅក្នុងប្រទេស ហើយឲ្យប្រាប់គាត់អំពីភារកិច្ច "ពាខ" ដដែល ។

នៅខែមិថុនា ឆ្នាំ១៩៧៤ ខ្ញុំចេញដំណើរពីហាណូយ ចូលមកក្នុងប្រទេសកម្ពុជា ។ ពេលនោះ ខ្ញុំជូនដំណើរអង្គការតាមភារកិច្ច ជាអ្នកជំនួយការ និងការពារ ។

នៅថ្ងៃទី២៤ ខែមិថុនា ឆ្នាំ១៩៧៤ ខ្ញុំចូលមកដល់ក្នុងប្រទេស ។ អង្គការឲ្យខ្ញុំនៅប-១៦ ដែលជាមន្ទីរនិរសាររបស់អង្គការនៅតំបន់កំពង់ចាម ភូមិភាគឧត្តរ ។ ភារកិច្ចរបស់ខ្ញុំដែលមន្ទីរចាត់តាំងគឺបង្កបង្កើនផល ។ ខ្ញុំស្ថិតនៅក្នុងសភាពចល័តពីមន្ទីរមួយទៅមន្ទីរមួយទៀតដោយត្រូវទៅរៀនសូត្រ និងធ្វើបដាសន្និសីទ ។

នៅខែវិច្ឆិកា ឆ្នាំ១៩៧៤ ខ្ញុំបានជួប គ្រិនលាន ហៅ សំ នៅមន្ទីរប-២០ ពេលទៅរៀនសូត្រ ។ ខ្ញុំប្រាប់ គ្រិនលាន អំពីភារកិច្ចដែល ឡាយនី ប្រគល់ឲ្យខាងលើ ។ ពេលនោះ គ្រិនលាន ហៅ សំ នៅមន្ទីរប-១៥ ដែលជាមន្ទីរបង្កបង្កើនផលរបស់អង្គការស្ថិតនៅតំបន់កំពង់ចាម ភូមិភាគឧត្តរ ។

គ្រិនលាន បាននិយាយប្រាប់ខ្ញុំអំពីរយៈពេលមួយឆ្នាំ ដែលកន្លងទៅនៅតំបន់រំដោះ ។ គាត់ថា ចំណុចអំណោយផលដល់ កា.ហ្វេ.បេ មានច្រើន ដូចជាមនុស្សសុទ្ធតែមិនចេះអក្សរ ។ មន្ទីរខ្វះសព្វខ្វះគ្រប់ តាំងពីហូបចុករហូតដល់ថ្នាំពេទ្យ ។

ខ្ញុំបានឯកភាពជាមួយ សំ ។ ខ្ញុំនិង សំ បានពិភាក្សាគ្នាហើយពេលត្រឡប់ទៅតាមមន្ទីរវិញ ខ្ញុំបានបំផុសពាក្យថា ប្រទេសសង្គមនិយមចង់ឲ្យជំនួយច្រើនណាស់តែកម្ពុជាមិនយក ។ ខ្ញុំបានទិញទឹកចិត្តបងប្អូន ដោយឲ្យថ្នាំពេទ្យ ថ្មដែកកេះតាមបុគ្គល ។ រឿងឲ្យនេះដឹងដល់ប្រធានមន្ទីរ រហូតដល់អង្គការហៅខ្ញុំយកទៅកសាង ។

ខ្ញុំបានបំផុសបញ្ហាសីលធម៌ក្នុងសង្គ្រាម តាមរូបភាពចំហស្របច្បាប់ ខ្ញុំសួរទៅនារីថា តើវាងអ្នកពិការ ខ្វាក់ភ្នែក និងកំបុតដៃជើង មិត្តសុខចិត្តគាំទ្រយកមួយណា? សំណួរនេះនាំឲ្យផ្អើលឆោឡោក្នុងសាលា រហូតដល់បងគណអប់រំឲ្យបញ្ចប់ ដោយបញ្ជាក់ថា កុំបំផុសបញ្ហាសីលធម៌ក្នុងសង្គ្រាម ព្រោះផ្ទុយនឹងមាគ៌ារបស់អង្គការ ។

នៅមុនឆ្នាំ១៩៧៤ ឡាយនី ចូលមកក្នុងប្រទេស ។ គាត់ទៅនៅមន្ទីរប-១៥ ដែលជាមន្ទីរបង្កបង្កើនផលរបស់អង្គការ ។ ពេលនោះ អង្គការចាត់តាំងខ្ញុំឲ្យទៅធ្វើបដានៅមន្ទីរប-១៥ ដើម្បីធ្វើសន្និបាតស-៧១ប្រចាំឆ្នាំ១៩៧៥ ។ ស៧១ ជាអង្គភាពរួមនៃមន្ទីរទាំងអស់របស់អង្គការ ។

រូបភាពក្រៅខ្ញុំធ្វើបដា តែសម្ងាត់ ខ្ញុំរាយការណ៍ឲ្យ ឡាយនី ហៅ ឡន ថាខ្ញុំទើបនឹងជួប គ្រិនលាន ហៅ សំ កាលពីខែវិច្ឆិកាកន្លងទៅនេះ រួចហើយខ្ញុំបានរាយការណ៍អំពីសកម្មភាពរបស់ខ្ញុំ ។ ឡាយនី ប្រាប់ខ្ញុំឲ្យបន្តភារកិច្ចពាខទៀត រីឯការទាក់ទងគាត់នឹងទាក់ទងដូចពេលមុនៗ ។

នៅខែមករា ឆ្នាំ១៩៧៥ ខ្ញុំបែកពី ឡាយនី ព្រោះអង្គការហៅខ្ញុំទៅរៀនសូត្រ នៅមន្ទីរប-១៦វិញ ។

នៅខែ២ ឆ្នាំ១៩៧៥ អង្គការឲ្យខ្ញុំទៅលត់ដំ រៀនសូត្រពី

សហករណ៍ នៅព្រះវិហារ ។ ខ្ញុំទៅនៅក្នុងសហគមន៍មួយក្នុងភូមិឈ្នួន ស្រុករវៀង ។ ខ្ញុំសង្កេតឃើញកម្រិតយល់ដឹងនយោបាយរបស់ប្រជាជននៅក្នុងសហគមន៍ទាបជាងនៅមន្ទីរ ។ ប្រជាជនខ្វះស្បៀក ពាក់ ខ្វះអំបិល ពិសេសខ្វះថ្នាំពេទ្យ ។

ខ្ញុំបានទិញទឹកចិត្តប្រជាជន ដោយឲ្យថ្នាំពេទ្យតាមបុគ្គល ។ ដំណឹងនេះដឹងដល់ប្រធានសមាគម ។ គាត់ហៅខ្ញុំទៅកសាង ហើយហាមដាច់ខាតកុំឲ្យខ្ញុំឲ្យសម្ភារអ្វីទៅប្រជាជនតាមបុគ្គល បើចង់ឲ្យត្រូវប្រគល់ជូនមកអង្គការ ។

នៅចុងខែមេសា ឆ្នាំ១៩៧៥ អង្គការហៅខ្ញុំឲ្យត្រឡប់មកធ្វើការនៅក្រសួងការបរទេស ផ្នែកខាងបម្រើភ្ញៀវចិន ។ ក្រោយមក ខ្ញុំទៅនៅក្រុមរៀបចំផ្ទះទទួលភ្ញៀវនៃមន្ទីរប-១ ។ ខែកញ្ញា ឆ្នាំ១៩៧៥ ឡាយនី មកធ្វើការនៅក្រសួងការបរទេស ។ ខ្ញុំបានរាយការណ៍ឲ្យគាត់ពីសកម្មភាពដែលខ្ញុំបានធ្វើនៅព្រះវិហារ ។ ចំណែកនៅក្រុមរៀបចំផ្ទះ ខ្ញុំបានរាយការណ៍ពីការអនុវត្តពាក្យស្លោក «កសាងសង្គមនិយមត្រូវមានសប្បាយខ្លះ» ។ ខ្ញុំបានបន្ធូរបន្ថយឲ្យបងប្អូនស៊ីដឹក ហូបសេរី ស្បៀកពាក់ប្រណីតៗតាមចិត្ត ។

ឡាយនី ប្រគល់ភារកិច្ចថ្មីឲ្យខ្ញុំ ៖ ១) បង្វែរមាគ៌ាដោយបង្អាច់បំដើស ឬបំភ្លៃ តាមការអនុវត្តជាក់ស្តែង ២) គ្រប់ភារកិច្ចត្រូវយកបញ្ហាបច្ចេកទេសជាធំ ៣) ត្រូវបន្តលត់ដំតទៅទៀតធ្វើយ៉ាងម៉េច ឲ្យបានចូលបក្ស ។ ឯការទាក់ទង ឡាយនី ប្រាប់ខ្ញុំថាត្រូវរាយការណ៍ឲ្យគាត់ ព្រោះសព្វថ្ងៃនេះគាត់ធ្វើការនឹងន៏ នៅក្រសួងការបរទេសហើយ ។ ទទួលភារកិច្ចហើយ ខ្ញុំយកទៅអនុវត្តជាក់ស្តែងនៅក្រុមរៀបចំផ្ទះទទួលភ្ញៀវ ។

ពេលនោះ ខ្ញុំមាននាទីជាអ្នកទទួលខុសត្រូវខាងបច្ចេកទេស ។ ឯអ្នកទទួលខុសត្រូវខាងសតិអារម្មណ៍នយោបាយឈ្មោះ ម៉ម អតីតជាគ្រូបង្រៀន ។ ដោយខ្ញុំក្តាប់ចំណុចខ្សោយរបស់ ម៉ម បានថា ជាអ្នកចូលចិត្តរស់នៅធូរធារ ខ្ញុំក៏និយាយឲ្យគាត់បន្ធូរបន្ថយឲ្យបងប្អូនក្រុមរៀបចំផ្ទះ បានហូបចុកសម្បូរ ស្បៀកពាក់ហូហៀរ សុទ្ធតែក្រណាត់ប្រណីតៗ ។

រាល់ថ្ងៃខ្ញុំតែងនិយាយជាប្រចាំពីបញ្ហាបច្ចេកទេស ដើម្បីឲ្យបងប្អូនស្រឡាញ់បច្ចេកទេស ឃើញបច្ចេកទេសសម្បើម ។ ប៉ុន្តែត្រូវពឹងផ្អែកលើបច្ចេកទេសគេ ដើម្បីកសាងប្រទេសយើងឲ្យលឿន ជាពិសេស ពឹងផ្អែកបច្ចេកទេសសង្គមនិយម ។ នៅខែ៣ ឆ្នាំ១៩៧៦ អង្គការក៏ដក ម៉ម ចេញ ដោយសារគាត់អាជ្ញាដាក់មហាជន ហើយបន្ធូរបន្ថយខ្លួនឯង ។

ខ្ញុំបន្តអនុវត្តផែនការដូចមុនជាមួយអ្នកទទួលខុសត្រូវថ្មី ដោយបង្វែរមាគ៌ាអង្គការ ។ ខ្ញុំបានធ្វើតាមរូបភាពស្របច្បាប់នៅពេលរៀនសូត្រទូទាំងក្រសួង ដោយលើកពាក្យអង្គការថា សព្វថ្ងៃនេះ កំពុងកសាង យើងមិនលំបាកដូចនៅសង្គ្រាមទេ ពេលសង្គ្រាមលំបាកជាងសព្វថ្ងៃ ។ ផ្ទុយទៅវិញ ខ្ញុំក៏លើកមតិប្រឆាំងនឹងអង្គការថា «ឡេនីន និយាយថា ពេលសង្គ្រាម គឺពេលដណ្តើមអំណាច យកអំណាចមិនលំបាកដូចពេលក្តាប់អំណាចសព្វថ្ងៃនេះទេ» ។ ជាក់ស្តែង អង្គការឲ្យធ្វើកន្លែងវាយសីពីរកន្លែងសម្រាប់ភ្ញៀវទូតលេងកម្សាន្ត ។ ខ្ញុំបានសួរ ឡាយនី គាត់ប្រាប់ថាឲ្យខ្ញុំធ្វើមួយកន្លែងបានហើយ ។ ខ្ញុំរាយការណ៍ឲ្យអង្គការថា ធ្វើមួយបានហើយព្រោះកន្លែងចង្អៀត ។ អង្គការបញ្ជាក់ថា ធ្វើមួយកន្លែង គឺឯកជនត្រូវធ្វើពីរកន្លែង ។ បញ្ហានេះខ្ញុំបានបំផុសមតិប្រឆាំងអង្គការថាមួយទើបត្រូវព្រោះកន្លែងចង្អៀត ។ ទីបំផុត អង្គការឲ្យខ្ញុំធ្វើពីរកន្លែងទាល់តែបាន ។

នៅពេលរៀបចំផ្ទះទទួលទូតកូរ៉េ ខ្ញុំរៀបចំឲ្យខ្វះកែវ ខ្វះពែង ពេលភ្ញៀវមកដល់ដើម្បីបញ្ចុះឥទ្ធិពលអង្គការ ។ ដោយឡែក ពេលរៀបចំស្ថានទូត អាល់បានី ពេលមិត្តយើងកំពុងធ្វើការ ខ្ញុំបណ្តោយឲ្យបុគ្គលិកទូតអាល់បានី ដើរមើល ចង្អុលលិច ចង្អុលកើត ត្រួតត្រាមិត្តយើង ។ រហូតដល់មហាជនផ្ទុះកំហឹងឡើងថា «យើងបណ្តេញបរទេសជិះជាន់អស់ហើយ ម្តេចឡើយនៅឲ្យបរទេសមកត្រួតត្រាយើងទៀត» ។ រឿងនេះដឹងដល់អង្គការ រហូតអង្គការមានមតិថា «ប្រយ័ត្នខ្ញុំគេទៀត» ។

នៅខែមិថុនា ឆ្នាំ១៩៧៦ ខ្ញុំរាយការណ៍ពីសកម្មភាពរបស់ខ្ញុំទាំងអស់ឲ្យ ឡាយនី ។ ស្របពេលនោះ យើងបានបញ្ចូលសមាជិកថ្មីម្នាក់ឈ្មោះ ស៊ាង ហ៊ីឡុង ហៅ ដាត ទៅក្នុងអង្គការ កា.ហ្សេ.បេ ទៀត ដោយមាន ឡាយ នី ជាអ្នកទទួលស្គាល់ ។

ស៊ាង ហ៊ីឡុង ហៅ ដាត អតីតនិស្សិតសេដ្ឋកិច្ចនៅប្រទេសអាល្លឺម៉ង់ខាងកើត សព្វថ្ងៃធ្វើការនៅក្រសួងការបរទេស ផ្នែកអាកាសចរណ៍ នាទីជាអ្នកទទួលខុសត្រូវខាងបច្ចេកទេស ។ គាត់

មានភារកិច្ចទាក់ទងជាមួយ ឡាយនី ទទួលបញ្ជាពី ឡាយនី ហើយរាយការណ៍ឲ្យ ឡាយនី ។

នៅខែមិថុនា ឆ្នាំ១៩៧៦ ខ្ញុំទទួលភារកិច្ចថ្មីពី ឡាយនី គឺ៖

**១) ត្រូវបង្វែរមាគ៌ា មានដូចជា ៖**

◆ មាគ៌ាការបរទេស ត្រូវធ្វើយ៉ាងណាឲ្យមានការទាក់ទងជាមួយសូវៀតនិងប្រទេសសង្គមនិយមនៅអឺរ៉ុបខាងកើតឡើងវិញ ។

◆ បញ្ហាមិនចាយលុយ ធ្វើយ៉ាងម៉េចឲ្យឃើញថា ការមិនចាយលុយវាស្មើគ្នាពេក ។

◆ ធ្វើម៉េចឲ្យឃើញសមូហភាព តឹងរ៉ឹងពេក

◆ ធ្វើម៉េចឲ្យឃើញបច្ចេកទេសជាធំ មិនមែនសតិអារម្មណ៍នយោបាយទេ ។

**២) ខិតខំកសាងកម្លាំងទាំងជម្រៅ ទាំងសន្ទឹង**

**៣) តើចិនមានសកម្មភាពអ្វីខ្លះ មានអ្នកបច្ចេកទេសប៉ុន្មាននាក់?**

ពេលនោះ ខ្ញុំបានបំផុសដូចលើកឡើងថា កាលណាមានសូវៀតមកដាក់ទូតនៅភ្នំពេញវិញ ។ ពេលកសាងប្រទេស យើងត្រូវការជំនួយពីប្រទេសសង្គមនិយមទាំងអស់ មិនមែនផ្ដាច់មុខតែចិនមួយទេ ។

ខ្ញុំលើកបញ្ហាសួរគ្នាថា ៖ បើចាយលុយ យើងមានប្រាក់ខែខុសៗគ្នា ច្រើនតិចទៅតាមសមត្ថភាពការងារ និងបច្ចេកទេស ។ បើមិនចាយលុយ អ្នកធ្វើច្រើនក៏ដូចអ្នកធ្វើតិច ហូបតែមួយឆ្អែត ។ ខ្ញុំវែកញែកថា បើចាយលុយ និងមានផ្សារ យើងចង់បានឥវ៉ាន់ ឬហូបចុកបាន ។

ខ្ញុំបំផុសដូចជា ៖ សព្វថ្ងៃកាន់តែតឹងរ៉ឹងទៅៗ តាំងពីធ្វើការងារ ការរស់នៅដើរហើរទៅណាបន្តិចក៏លំបាក ។ ខ្ញុំបាននិយាយជារឿយៗថា "អង្គការដូចជាមិនសូវគិតគូរអ្នកបច្ចេកទេសសោះ" ។ ក្នុងការកសាងប្រទេស យើងត្រូវការអ្នកបច្ចេកទេសច្រើនណាស់ ដើម្បីឲ្យប្រទេសជឿនលឿនទៅមុខ មិនតែប៉ុណ្ណោះយើងត្រូវការជំនួយបច្ចេកទេសពីប្រទេសសង្គមនិយម ទៀត ។

ទន្ទឹមនឹងការបំផុសនេះ ខ្ញុំបានលើកបញ្ហានៅក្នុងអង្គប្រជុំធំៗ ដើម្បីវាយប្រហារកម្មាភិបាលដឹកនាំក្នុងមន្ទីរដូចជា "មហាជនទិតៀន កម្មាភិបាលត្រូវតែយកទៅពិចារណា ព្រោះតែកម្មាភិបាលមានការខ្វះខាតអ្វីហើយ ទើបមហាជនលើក ។ ខ្ញុំលើកឡើងថា "មានបញ្ហាអ្វី គិតតែដោះស្រាយតាមការចាត់តាំង មិនគិតដោះស្រាយសតិអារម្មណ៍សោះ" ។

បញ្ហាសំខាន់មួយទៀត គឺត្រូវធ្វើយ៉ាងម៉េចឲ្យបានចូលធ្វើការខាងផ្នែកនយោបាយនៃក្រសួងការបរទេស ដើម្បីងាយស្រួលបង្វែរមាគ៌ានយោបាយការបរទេសរបស់អង្គការឲ្យងាកទៅទាក់ទងជាមួយសហភាពសូវៀត និងប្រទេសសង្គមនិយមនៅអឺរ៉ុបខាងកើតឡើងវិញ ។

នៅចុងខែវិច្ឆិកា ឆ្នាំ១៩៧៦ អង្គការបើកវគ្គអប់រំ ខទ្ទុសនាមថា សហការបន្តធ្វើបដិវត្តន៍សង្គមនិយម និងកសាងសង្គមនិយមនៅកម្ពុជាវិវត្តទៅមុខល្អ ។

នៅខែធ្នូ ឆ្នាំ១៩៧៦ ខ្ញុំយកលេសថា ម្ដាយក្មេក ឈឺធ្ងន់ ខ្ញុំបានស្នើអង្គការទៅមើល អង្គការក៏សម្រេចឲ្យទៅស្រុកកំណើតគ្រួសារនៅភូមិស្រះធុល ឃុំដើងរាស់ ស្រុកខត្តុង តំបន់៣២ ភូមិភាគបស្ចិម ។ ខ្ញុំទៅនៅក្នុងសហករណ៍ភូមិឃុំខាងលើ ខ្ញុំក៏បានទៅមើលសហករណ៍នៅទីនោះ ។ ត្រឡប់មកវិញខ្ញុំបានរាយការណ៍ឲ្យ ឡាយនី បន្ថែមពីលើការរាយការណ៍ពីមុនអំពី៖ អ្នកដែលទទួលខុសត្រូវចិនធំជាងគេនៅកម្ពុជា ដែលមិនមែនជាទូត ស៊ុន ហោ ប៉ុន្តែគឺសេនាធិការទ័ពឲ្យយោធា តឹង យុនសាន ។

៦ អ្នកបច្ចេកទេសចិនស្ថិតនៅក្រោមការគ្រប់គ្រងនៃក្រសួងការបរទេសកម្ពុជាប្រជាធិបតេយ្យ ដែលមានច្រើនក្រុម ហើយចល័តជាប់ដូចជា៖

◆ ក្រុមវិទ្យុផ្សាយសំឡេង ៖ ជួសជុលនិងតម្លើងស្ថានីយវិទ្យុស្ទឹងមានជ័យ

◆ ក្រុមទូរពុម្ព ៖ ធ្វើការនៅក្រសួងឃោសនាការ

◆ ក្រុមពេទ្យ ៖ ធ្វើការនៅពេទ្យព-១៧

◆ ក្រុមស្នប់ថ្នាំពេទ្យ ៖ ធ្វើការនៅក្រសួងសង្គមកិច្ច

◆ ក្រុមគូរប្លង់សំណង់រោងចក្រ និងអគារ ជិតស្ថានទូតចិន

◆ ក្រុមរោងចក្រកែវ ៖ ធ្វើនៅរោងចក្រកែវ ជិតស្ទឹងមានជ័យ មានទាំងអស់ជាង៣០០នាក់ ។

រហូតដល់ថ្ងៃទី១៨ ខែធ្នូ ឆ្នាំ១៩៧៦ អង្គការចាប់ខ្ញុំនៅមន្ទីរប-១ តែម្ដង ។ **សោម ប៊ុនថន**

# ស្លាកស្នាមបន្សល់ទុកពីរបបខ្មែរក្រហម

គុំ សំអាត ជាគ្រូបង្រៀនផ្នែកប្រវត្តិវិទ្យាកម្រិតមធ្យមសិក្សាបឋមភូមិ ។ បច្ចុប្បន្ន សំអាត ជាគរុនិស្សិត នៅវិទ្យាស្ថានជាតិអប់រំ ។


គុំ សំអាត

សំអាត បានរៀបរាប់ថា នៅក្នុងរបបខ្មែរក្រហម ខ្ញុំមានអាយុបីឆ្នាំ ប៉ុន្តែ អ្វីដែលធ្វើឲ្យខ្ញុំចងចាំ និងឈឺចាប់ និងអាក់អន់ចិត្តមកដល់សព្វថ្ងៃគឺ «ពេលដែលខ្មែរក្រហមយកខ្ញុំទៅដាក់នៅក្នុងកងកុមារឲ្យយាយៗមើល ប៉ុន្តែបែរជាបណ្ដាលឲ្យបាក់ខ្នង់ប្រមុះ និងបន្សល់ស្លាកស្នាមរហូតមកដល់សព្វថ្ងៃ» ។

សំអាត បន្តថា សម្រាប់ជនរងគ្រោះនៅក្នុងរបបខ្មែរក្រហម ត្រូវតែរៀបរាប់រឿងរ៉ាវដែលបានកើតឡើង បើមិនដូច្នេះទេ រឿងទាំងនោះនឹងកប់បាត់ និងមិនមាននរណាដឹងឮនោះទេ ។

សំអាត មានស្រុកកំណើតនៅភូមិបាម ឃុំគោកព្រិច ស្រុកគិរីវង្ស ខេត្តតាកែវ ។ សំអាត មានបងប្អូនប្រាំមួយនាក់ ហើយគាត់ជាកូនច្បងក្នុងគ្រួសារ ។ សំអាត នៅចងចាំតាមរយៈម្ដាយគាត់រៀបរាប់ប្រាប់ថា កាលពីមុនរបបខ្មែរក្រហម ឪពុកម្ដាយគាត់រស់នៅភ្នំពេញដោយឪពុកគាត់ធ្វើជាទាហាន លន់ នល់ ។

នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ គ្រួសារ សំអាត បានត្រឡប់ទៅនៅស្រុកកំណើតវិញ ដោយពេលនោះខ្មែរក្រហមបានចាត់ទុកគ្រួសារគាត់ថាជាប្រជាជន ១៧ មេសា (ព្រោះឪពុកម្ដាយធ្លាប់រស់នៅទីក្រុងភ្នំពេញ) ។

ក្លាមនោះ ខ្មែរក្រហមបានប្រកាសរកអ្នកធ្វើការនៅក្នុងរបបចាស់ឲ្យទៅចុះឈ្មោះដើម្បីចូលរួមប្រជុំ ។ ពូរបស់ សំអាត ម្នាក់ដែលជាអតីតមន្ត្រីរាជការ និងជាគិញក្នុងរបប លន់ នល់ ដែលត្រូវបានជម្លៀសទៅស្រុកជាមួយគ្រួសារ សំអាត ដែរ បានស្ម័គ្រចិត្តទៅចុះឈ្មោះ ដោយគាត់បាននិយាយថា "មិនមានរបបណាយកមនុស្សចេះដឹងទៅវាយសម្លាប់ចោលទេ» ទោះបីពេលនោះ មានការហាមឃាត់ពីឪពុកម្ដាយនិងបងប្អូនក៏ដោយ ។ ក្រោយមក មានអ្នកភូមិម្នាក់មកប្រាប់ម្ដាយ សំអាត ថា ឃើញពូរបស់ សំអាត មានរូបរាងស្គមស្គាំង ត្រូវបានខ្មែរក្រហមឃុំឃាំងនៅមន្ទីរសន្តិសុខតាមាន់ (មានចម្ងាយប្រមាណ៨០គីឡូម៉ែត្រពីផ្លូវបំបែកគុស) ហើយចាប់តាំងពីពេលនោះមកបាត់ដំណឹងពូរបស់ សំអាត រហូត ។

នៅក្នុងភូមិបានមួយរយៈ ខ្មែរក្រហមចាត់តាំងឪពុក សំអាត ឲ្យទៅរែកដីនៅក្នុងកងចល័ត ស្រុកគិរីវង្ស ហើយម្ដាយគាត់ទៅនៅស្រុក១០៨ (ស្រុកគិរីវង្ស ដែលប្រជាជនតែងហៅថាស្រុកក្រោម) ដែលមានព្រំទល់ជាប់ជាមួយនឹងប្រទេសវៀតណាម ។ ចំណែក សំអាត ដែលមានអាយុប្រមាណមួយឆ្នាំត្រូវខ្មែរក្រហមយកទៅដាក់នៅក្នុងកងកុមារ ដោយមានយាយចាស់ម្នាក់ជាអ្នកមើលថែទាំ ។ ពេលនោះដោយសារ សំអាត មានវ័យក្មេងពេក ទើបគាត់ពុំបានចងចាំថាមានអ្វីកើតឡើង ហើយនរណាជាអ្នកប្រព្រឹត្តអាក្រក់មកលើរូបគាត់ទេ? ព្រោះក្រោយរបបខ្មែរក្រហមដួលរលំទៅនៅឆ្នាំ១៩៧៩ ប្រមុះរបស់ សំអាត ចាប់ផ្ដើមរលួយ និងធំក្លិនស្អុយចេញមកក្រៅ ។ ក្រោយមក ម្ដាយរបស់ សំអាត បាននាំគាត់ទៅពិនិត្យនៅមន្ទីរពេទ្យកាល់ម៉ែត្រក្រុងភ្នំពេញ ។ ពេលនោះគ្រូពេទ្យបានរកឃើញឆ្អឹងត្រី និងស្រកីផ្លែអំពិលជូរនៅក្នុងប្រមុះរបស់គាត់បណ្ដាលឲ្យគាត់ពុកឆ្អឹងប្រមុះ និងបាក់ខ្នង់

ប្រមុះ រហូតមកដល់សព្វថ្ងៃ ។

សំអាត លើកឡើងថា រៀងរាល់ពេលដែលម្ដាយគាត់ចេញពីធ្វើការ ម្ដាយគាត់តែងតែដើរវាយសត្វថ្លែនមកដុតឲ្យគាត់ហូប ធ្វើឲ្យគាត់ចង់ចាំរសជាតិសាច់សត្វថ្លែនរហូតមកដល់សព្វថ្ងៃនេះ ។ នៅទីនោះ គ្រួសារ សំអាត មានការខ្វះខាតអាហារយ៉ាងខ្លាំង ព្រោះខ្មែរក្រហមមិនបានបែងចែករបបអាហារឲ្យគ្រួសារគាត់ស្មើនឹងប្រជាជនចាស់ទេ ។ ហេតុដូច្នេះហើយ ទើបម្ដាយមីងរបស់គាត់ម្នាក់ជាអ្នកមូលដ្ឋាន ធ្វើការក្នុងកងវែងអង្ករ និងកិនអង្ករក្នុងភូមិ លួចយកអង្ករមកឲ្យម្ដាយគាត់ដាំហូប ។ ប៉ុន្តែ មិនហ៊ានឲ្យនរណាដឹងទេ ព្រោះថ្ងៃមួយ មីងរបស់ សំអាត ឃើញក្មេងម្នាក់នៅក្នុងភូមិបានទៅរើសអង្ករ ដែលខ្ទាតចេញពីត្បាល់កិន ស្រាប់តែពេលនោះពូ ឡិច ដែលជាអ្នកកិនអង្ករបានលើកក្មេងនោះដាក់លើត្បាល់កិន រួចបង្វិលរហូតដល់ក្មេងវិលមុខ និងហូរទឹកមាត់ដើម្បីជាការព្រមាន ។ ក្រោយរបបខ្មែរក្រហមដួលរលំ ពូឡិច បានភៀសខ្លួនទៅរស់នៅយ៉ាងសុខសាន្តតាមបណ្ដោយទល់ដែនខ្មែរថៃ ប៉ុន្តែគាត់មិនដែលហ៊ានវិលត្រឡប់មកស្រុកកំណើតវិញទេ ចាប់តាំងពីរបបខ្មែរក្រហមដួលរលំទៅនៅឆ្នាំ១៩៧៩ ។

សំអាត បន្តថា មានថ្ងៃមួយឪពុករបស់គាត់បានត្រឡប់មកភូមិ និងបានលើកគាត់ដាក់លើស្មា រួចដើរទៅកន្លែងការដ្ឋានរបស់ម្ដាយគាត់នៅស្រុក១០៨ ។ សំអាត ទៅដល់កន្លែងម្ដាយគាត់ធ្វើការនៅពេលយប់ ។ ពេលនោះ សំអាត មិនដឹងថាម្ដាយគាត់បានម្ហូបមកពីណាទេ ព្រោះស្រាប់តែគាត់ឃើញមានត្រីខនិងបាយជ្រាយ (បបរឈ្មោល) ដែលគាត់មិនដែលបានហូបយូរហើយ ។ សំអាត បាននិយាយទៅកាន់ឪពុកម្ដាយគាត់ទាំងមិនច្បាស់លាស់ថា «ថ្ងៃនេះយើងបានហូបបាយជ្រាយហូបបាយឆ្ងាញ់មួយពេលហើយ» ហើយសម្ដីនេះឪពុកម្ដាយគាត់នៅតែលើកយកមកនិយាយមកដល់សព្វថ្ងៃនេះ ។

នៅឆ្នាំ១៩៧៩ ខ្មែរក្រហមបានកៀរគ្រួសារ សំអាត ឲ្យចេញពីស្រុកដោយប្រាប់ថា ខ្លាចវៀតណាមផ្លោងគ្រាប់ដាក់ ។ ឪពុក សំអាត បានលើក សំអាត ឲ្យជិះរទេះគោ រួចហើយបររហូតទៅដល់ស្រុកឈូក ខេត្តកំពត ទើបកងទ័ពវៀតណាមទៅស្ទាក់ជាប់ និងប្រាប់ឲ្យត្រឡប់មកស្រុកកំណើតវិញ ។



សំអាត (រូបកណ្ដាល) កំពុងអង្គុយក្នុងថ្នាក់រៀនជាមួយគរុនិស្សិតផ្សេងទៀតអំឡុងវគ្គបណ្ដុះបណ្ដាលស្ដីអំពីវិធីសាស្ត្របង្រៀនប្រវត្តិកម្ពុជាប្រជាធិបតេយ្យ



សំអាត កំពុងបង្រៀនសាកល្បងស្តីអំពីប្រវត្តិកម្ពុជាប្រជាធិបតេយ្យ

គ្រួសារ សំអាត បានមករស់នៅភូមិបាម ឃុំគោកព្រិច ស្រុកគិរីវង្ស ខេត្តតាកែវ ។ សំអាត ក៏បានចូលរៀននៅសាលាបឋមសិក្សាក្នុងភូមិ ហើយឆ្នាំ១៩៩៣ គាត់បានប្រឡងជាប់មធ្យមសិក្សាបឋមភូមិ ។

សំអាត បានរៀនបន្តរហូតប្រឡងជាប់មធ្យមសិក្សាទុតិយភូមិនៅឆ្នាំ១៩៩៦ បន្ទាប់មកគាត់ប្រឡងចូលរៀនគ្រូបឋមសិក្សារយៈពេលពីរឆ្នាំ ។ នៅឆ្នាំ១៩៩៨ សំអាត ចេញទៅបង្រៀននៅសាលាបឋមសិក្សាមួយនៅឃុំដងទង់ ហើយឆ្លៀតពេលទំនេរពីការងារគាត់បានរៀនបរិញ្ញាបត្រផ្នែកប្រវត្តិវិទ្យានៅសាកលវិទ្យាល័យឯកជន ។ នៅក្នុងឆ្នាំដដែលគាត់បានប្រឡងប្តូរក្របខណ្ឌពីគ្រូបឋមសិក្សា មកជាគ្រូមធ្យមវិញ ។

មកដល់ឆ្នាំ២០១១ សំអាត បានប្រឡងប្តូរក្របខណ្ឌម្តងទៀត ពីគ្រូកម្រិតមធ្យមសិក្សាបឋមភូមិ មកជាគ្រូមធ្យមសិក្សាទុតិយភូមិ ហើយបច្ចុប្បន្នត្រូវមករៀនបន្តនៅភ្នំពេញ ។ សំអាត បានរៀបរាប់ថា មូលហេតុដែលគាត់ជ្រើសរើសយកមុខវិជ្ជាប្រវត្តិវិទ្យា ព្រោះគាត់យល់ឃើញថាមានសិស្សមួយចំនួនបន្ទាប់ពីប្រឡងបញ្ចប់ថ្នាក់វិទ្យាល័យរួចហើយ បានមើលរំលងមុខវិជ្ជាប្រវត្តិវិទ្យា ។ សិស្សទាំងនោះបានសម្លឹងមើលទៅលើបរិបទសង្គម ព្រោះគ្រូប្រវត្តិវិទ្យាមិនអាចបង្រៀនគួរ និងអាចរកលុយបានដូចជាមុខវិជ្ជាដទៃ ដោយសារមូលហេតុទាំងអស់នោះ ហើយទើបសំអាត ជ្រើសរើសយកប្រវត្តិវិទ្យា ។

សំអាត យល់ថាប្រសិនបើមនុស្សម្នាក់មិនជ្រើសរើសយកប្រវត្តិវិទ្យា មនុស្សពីរនាក់មិនជ្រើសរើសយកប្រវត្តិវិទ្យា តើប្រវត្តិសាស្ត្រខ្មែរទុកឲ្យអ្នកណារៀន? ស្របពេលដែលប្រទេសកម្ពុជាកំពុងមានបញ្ហាព្រំដែនប្រទេសជិតខាងតែងតែបកស្រាយប្រវត្តិសាស្ត្ររបស់គេ មានប្រៀបជាងយើង ។ ម្យ៉ាងវិញទៀត ប្រសិនបើគេបកស្រាយបំភ្លៃ ហើយយើងមិនចេះប្រវត្តិសាស្ត្រខ្លួនទៀតនោះ ការបកស្រាយនោះ ហាក់ដូចជាការពិតដូច្នោះដែរ ។

សំអាត បន្ថែមថា ទោះបីគាត់បានឆ្លងកាត់ ដឹងឮនិងធ្លាប់ឮចាស់ៗនិយាយមែន ប៉ុន្តែគាត់ក៏ត្រូវមានសៀវភៅ និងមានឯកសារច្បាស់លាស់ដែរ ។ ដូច្នេះ ការរៀនសូត្រ ការអានសៀវភៅប្រវត្តិសាស្ត្របានជួយឲ្យគាត់កាន់តែមានសមត្ថភាពពិតប្រាកដថែមទៀត ។ សំអាត បន្តថា គាត់ម្នាក់ ឯងមិនអាចដោះស្រាយបញ្ហានិងនិយាយរឿងរ៉ាវប្រវត្តិសាស្ត្រទាំងអស់បានទេ គឺទាមទារឲ្យគ្រូបង្រៀន និងប្រជាជនចូលរួមជួយឲ្យប្រវត្តិសាស្ត្រឲ្យលេចធ្លោឡើង ។

**សោម ប៊ុនថន**

## សៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ

មជ្ឈមណ្ឌលឯកសារកម្ពុជាបានបោះពុម្ពសៀវភៅ «ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ១៩៧៥-១៩៧៩» ចាប់តាំងពីឆ្នាំ២០០៧មកនិងបានចែកចាយដល់សិស្ស-និស្សិតនិងសាធារណជនទូទាំងប្រទេសជាងមួយនាក់ ។ ជាមួយគ្នានោះដែរ សៀវភៅនេះត្រូវបានបកប្រែជាច្រើនភាសា ហើយអាចរកបានតាមរយៈ

*http://dccam.org/Projects/Genocide/A Hisotry of DK 2007.htm*

# "វេរបុណ្យភ្ជុំ ខ្ញុំឧទ្ទិសជូនប្តី"

រៀងរាល់ឆ្នាំ ពេលរដូវបុណ្យភ្ជុំបិណ្ឌចូលមកដល់ ប្រជាជនខ្មែរតែងតែយកចង្ហាន់ទៅប្រគេនព្រះសង្ឃនៅវត្តដើម្បីឧទ្ទិសកុសលជូនដូនតា និងសាច់ញាតិដែលបានស្លាប់ទៅ ព្រោះបើតាមជំនឿព្រះពុទ្ធសាសនាព្រលឹងរបស់អ្នកទាំងនោះ នឹងមកទទួលនូវបុណ្យកុសលដើម្បីឆាប់ទៅចាប់ជាតិថ្មី ។ ទោះបីយ៉ាងណា សម្រាប់យាយ ស៊ុម រឹម ពិធីបុណ្យនេះមិនមែនតែសម្រាប់ឧទ្ទិសកុសល និងជំនឿប៉ុណ្ណោះទេ ប៉ុន្តែបានធ្វើឲ្យគាត់ចងចាំមិនភ្លេចដល់ប្តី និងកូនរបស់គាត់ដែលស្លាប់ទៅនៅក្នុងរបបខ្មែរក្រហម ។

រឹម មានអាយុ៦៦ឆ្នាំ មានស្រុកកំណើតនៅស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ។ កាលពីកុមារ រឹម បានរៀនដល់ថ្នាក់ទី៨នៅសាលាបឹងខ្យាង ក្រោយមកក៏ឈប់រៀន ។ នៅឆ្នាំ១៩៦២ រឹម បានចាកចេញពីស្រុកកំណើតទៅរស់នៅជាមួយម្តាយមីងនៅក្រុងភ្នំពេញ ។ នៅទីនោះ រឹម បានចូលរៀនកាត់ដេរ ។ រយៈពេលមួយឆ្នាំក្រោយមក មានបុរសម្នាក់ឈ្មោះ ម៉ី មួន ដែលរស់នៅក្នុងភូមិជាមួយគ្នា បានចូលស្តីដណ្តឹងគាត់ ។

នៅឆ្នាំដដែល រឹម បានត្រឡប់មកស្រុកកំណើតដើម្បីរៀបការ ។ រឹម មិនបានប្រកបរបរកាត់ដេរដូចដែលគាត់បានរៀននៅភ្នំពេញទេបន្ទាប់ពីរៀបការរួច គឺគាត់ប្រកបរបរធ្វើស្រែជាមួយប្តី ។ រឹម បានរស់នៅស្រុកកំណើតរហូតដល់ លន់ នល់ ធ្វើរដ្ឋប្រហារឆ្នាំ១៩៧០ ។ ពេលនោះ កម្មាភិបាលខ្មែរក្រហមគ្រប់គ្រងនៅតំបន់ដែលគាត់រស់នៅបានមកប្រាប់គ្រួសារគាត់និងអ្នកភូមិឲ្យចាកចេញពីផ្ទះព្រោះខ្លាចកងទ័ព លន់ នល់ មកចាប់យកទៅសម្លាប់ចោល ។

គ្រួសារ រឹម បានភៀសទៅនៅឃុំកាត់ភ្លុក ខេត្តកំពង់ស្ពឺបានមួយរយៈ ទើបផ្លាស់មករស់នៅ ភូមិត្រពាំងខ្យង ស្រុកគងពិសីវិញ ។ នៅទីនោះ កម្មាភិបាលខ្មែរក្រហមបានជ្រើសរើសប្តីរបស់ រឹម ឲ្យធ្វើឈ្លបភូមិ ដោយទទួលភារកិច្ចជួយរៀបចំផ្នែកសន្តិសុខ



មន្ទីរសន្តិសុខសង់ ឬ គុកសង់

សម្រាប់ប្រជាជននៅតំបន់រំដោះ ចំណែក រីម ធ្វើស្រែជាមួយប្រជាជននៅក្នុងសហករណ៍ភូមិ ។

រហូតដល់ឆ្នាំ១៩៧៤ កម្មាភិបាលខ្មែរក្រហមថ្នាក់លើបានអនុញ្ញាតឲ្យគ្រួសារ រីម ត្រឡប់មកស្រុកកំណើតវិញ ប៉ុន្តែមិនទាន់ឲ្យមកនៅភូមិភ្លាមទេ គឺឲ្យមកនៅវត្តព្រះធាតុ (ដែលស្ថិតនៅមិនឆ្ងាយប៉ុន្មានពីភូមិរបស់គាត់) មួយរយៈសិន ។ រីម បានរស់នៅទីនោះ រហូតដល់កងទ័ពខ្មែរក្រហមរំដោះបានទីក្រុងភ្នំពេញ ឆ្នាំ១៩៧៥ ដោយនៅពេលនោះប្តីរបស់ រីម កាន់តួនាទីជដែល ចំណែក រីម ធ្វើការនៅក្នុងកងចល័ត ។

រីម បន្តថា នៅវេលាព្រលប់ថ្ងៃមួយក្នុងឆ្នាំ១៩៧៨ មានយោធាឃុំឈ្មោះ ម៉ាន់ (ក្រោយមក ស្លាប់ដោយសារធ្លាក់ពីលើផ្ទះ) និងឈ្មោះ ម៉ុន (បច្ចុប្បន្ននៅរស់) ដែលធ្លាប់ស្គាល់ និងរស់នៅស្រុកជាមួយគ្នាបានមកហៅប្តីរបស់គាត់ឲ្យទៅចូលរួមប្រជុំ ។ បន្ទាប់ពីទទួលបានដំណឹងនេះ ប្តីរបស់ រីម បានមកផ្តាំ រីម ឲ្យទៅទទួលគាត់ពីកន្លែងប្រជុំនៅសាលាបាគូមកផ្ទះវិញផង ក្រោយពីគាត់ប្រជុំចប់ ។ នៅព្រឹកថ្ងៃបន្ទាប់ រីម បានទៅទទួលប្តីរបស់គាត់តាមការផ្តាំផ្ញើ ប៉ុន្តែឈ្លបខ្មែរក្រហមដែលយាមនៅកន្លែងប្រជុំប្រាប់ថា ប្តីរបស់គាត់ទៅប្រជុំ និងទៅធ្វើការនៅកន្លែងផ្សេងហើយ រួចហើយឈ្លបនោះក៏ ប្រាប់គាត់ឲ្យត្រឡប់មកផ្ទះវិញ ។ រីម បានរង់ចាំប្តីរបស់គាត់ត្រឡប់មកផ្ទះវិញ ប៉ុន្តែគាត់បាត់ដំណឹងប្តីរបស់គាត់រហូតចាប់តាំងពីថ្ងៃនោះមក ។

រយៈពេលមួយខែក្រោយមក ឈ្លបខ្មែរក្រហមបានមកប្រាប់ រីម ថា អង្គការឲ្យគាត់ផ្លាស់ពីភូមិព្រះធាតុ ទៅរស់ជាមួយម្តាយរបស់គាត់នៅស្រុកកំណើតវិញ ។ រីម ត្រេកអរយ៉ាងខ្លាំងបន្ទាប់ពីទទួលបានដំណឹងនេះ គាត់ក៏ប្រញាប់ប្រញាល់ប្រមូលខោអាវដែលនៅសេសសល់ ចានឆ្នាំង និងរបស់របរបន្តិចបន្តួច រួចនាំកូនរបស់គាត់ទាំងពីរនាក់ដើរតាមក្រោយឈ្លប ។ រីម នៅចងចាំថា ពេលដើរដល់ផ្លូវកែងមួយកន្លែង ឈ្លបក៏បញ្ជាគាត់ឲ្យបត់ចូលតាមផ្លូវទៅគុកសង់ ឃើញដូច្នេះ គាត់ក៏និយាយទៅកាន់ឈ្លបនោះថា ផ្លូវនេះមិនមែនជាផ្លូវទៅផ្ទះរបស់គាត់ទេ ប៉ុន្តែឈ្លបបានឆ្លើយតបទៅគាត់វិញថា ស្ពាននៅខាងមុខបាក់មិនអាចដើរបានទេ ។ ឥឡូវអង្គការ ឲ្យគាត់ទៅនៅភូមិទ្រា (បរិវេណគុកសង់) វិញ ។

នៅពេលដែល រីម ដើរចូលទៅដល់គុកសង់ភ្លាម គាត់ក៏សួរបញ្ជាក់ឈ្លបទៀតថា «អង្គការឲ្យគាត់ទៅនៅជាមួយម្តាយ ហេតុអ្វីបានជាយកគាត់មកដាក់នៅទីនេះ» ។ ពេលនោះ ឈ្លបមិននិយាយអ្វីច្រើនទេ គឺគ្រាន់តែប្រាប់ថា អង្គការឲ្យអ៊ីមករៀនសូត្រនៅទីនេះមួយរយៈសិន ។ បន្ទាប់មក អ្នកយាមគុកនោះ បានមកដកហូតខោអាវ និងសម្ភាររបស់គាត់ទាំងអស់ រួចហើយនិយាយទៅកាន់គាត់ថា «អ្នកឯងជាប់ទាក់ទងជាមួយ សេ.អ៊ី.អា និង កា.ហ្សេ.បេ» ។

ពេលនោះ ទោះបី រីម បានបដិសេធ និងបានសូមអង្វរយកក្រណាត់ ខោអាវខ្លះមកវិញដើម្បីទុកសម្រាប់ប្រើប្រាស់នៅពេលគាត់ឆ្លងទន្លេ (គាត់មានផ្ទៃពោះប្រាំពីរខែ) យ៉ាងណាក៏ដោយក៏ឈ្លបនោះមិនបានលើកលែង និងប្រគល់ក្រណាត់មកឲ្យគាត់វិញដែរ ។ រីម ជាប់ឃុំនៅក្នុងគុកសង់រយៈពេលប្រាំថ្ងៃ ឆ្មាំគុកបានមកហៅ រីម និងអ្នកទោសប្រមាណ៦០នាក់ទៀតឲ្យទៅប្រជុំដោយពេលនោះ ប្រធានគុកប្រាប់គាត់និងអ្នកទោសទាំងអស់ឲ្យខិតខំលត់ដំនិងកែប្រែខ្លួនឡើងវិញ ។

ប្រជុំចប់ អ្នកយាមគុកបានដាក់ឲ្យ រីម រស់នៅជាមួយកូននិងអ្នកទោសផ្សេងទៀតនៅក្នុងបន្ទប់ ដែលក្នុងមួយបន្ទប់មានអ្នកទោស៣០នាក់ ប៉ុន្តែអ្នកយាមគុកមិនបានដាក់ខ្នោះ និងដាក់ច្រវាក់គាត់ទេ ។ មួយរយៈក្រោយមក កងសួរចម្លើយបានហៅ រីម យកទៅសួរចម្លើយម្តងទៀត ប៉ុន្តែគាត់នៅតែបដិសេធពីការជាប់ទាក់ទងជាមួយ សេ.អ៊ី.អា ដដែល ។

រីម បានរៀបរាប់ថា នៅក្នុងគុក គាត់ទទួលបានរបបអាហារពីរពេល គឺថ្ងៃត្រង់ និងពេលល្ងាច ដោយក្នុងមួយពេលៗទទួលបានតែបបររាវមួយវែកប៉ុណ្ណោះ ។ ចំពោះការងារ នៅពេលថ្ងៃ អ្នកយាមគុកបណ្តើរ រីម តាមបណ្តោយមាត់ទន្លេឲ្យទៅកាស់គល់ឈើនៅវត្តកោះខ្នុរ ដែលមានចម្ងាយប្រមាណបីទៅបួនគីឡូម៉ែត្រពីកន្លែងឃុំឃាំង រីឯកូនរបស់គាត់ប្រធានគុកចាត់តាំងឲ្យទៅរកខុស ប្រមូលដី និងកាប់ដើមទន្រ្ទានខែត្រ ។ រីម បន្តថា គាត់ឃើញឆ្មាំគុកបានដាក់ច្រវាក់ជើងអ្នកទោសដែលមានកំហុសធ្ងន់ រួចបណ្តើរទៅធ្វើការនៅកន្លែងផ្សេង ដោយមិនអនុញ្ញាតឲ្យអ្នកទោសទាំងនោះធ្វើការងារ ទាក់ទង និងរស់នៅជាមួយក្រុមរបស់គាត់ទេ ។ ក្រោយមក រីម បានឮដំណឹងពីអ្នកជាប់ទោសដូចគ្នាប្រាប់ថា ប្តីរបស់គាត់ត្រូវ

កងឈ្លបចាប់មកឃុំឃាំងក្នុងគុកសង់នេះ ដោយចោទថា ខ្មែរស ប៉ុន្តែគាត់មិនដែលបានជួបមុខប្តីគាត់ទេ ។

រឹម បន្តថា នៅក្នុងគុកសង់គាត់មិនដែលទទួលរងទារុណកម្ម ពីឆ្មាំគុក ឬកងសួរចម្លើយធ្ងន់ធ្ងរទេ ប៉ុន្តែរៀងរាល់យប់គាត់បាន ឮសួរសំឡេងអ្នកទោសស្រែកឲ្យជួយ និងស្រែកថ្ងូរដោយសារ ការធ្វើទារុណកម្មដ៏គួរឲ្យរន្ធត់ ក្រោមការគ្រប់គ្រងរបស់ប្រធានគុក ឈ្មោះ ម៉ុង និងអនុប្រធានឈ្មោះ ម៉េន (ក្រោយមកអង្គការបាន ផ្លាស់ប្តូរអ្នកថ្មីឲ្យមកជំនួសវិញ) ។ បន្ទាប់ពីសួរចម្លើយរួច រឹម ឃើញឡានចូលមកដឹកអ្នកទោសទាំងនោះចេញទៅបាត់ ប៉ុន្តែគាត់ មិនដឹងថាដឹកយកទៅសម្លាប់ចោល ឬយកទៅកន្លែងណានោះទេ ។

រឹម រៀបរាប់ថា នៅពេលគាត់សម្រាលកូន ឆ្មាំគុកបាន បំបែកគាត់ឲ្យទៅរស់នៅខ្ទមមួយដាច់ដោយឡែកពីគេ ។ រឹម បាន បន្តរៀបរាប់ទាំងរំជួលចិត្តថា “គាត់សម្រាលកូនតែម្នាក់ឯង គ្មាន ពេទ្យ គ្មានក្រណាត់ និងគ្មានឧបករណ៍អ្វីទាំងអស់ ។ គាត់បានយក កាំបិតដែលអង្គការចែកឲ្យសម្រាប់ទុកកាប់ឆ្ការព្រៃ មកកាត់ទងផ្ចិត កូនរបស់គាត់ ។ សំណាងល្អ ពេលនោះកូនស្រីច្បងរបស់គាត់ម្នាក់ ដែលមានអាយុ១៣ឆ្នាំ នៅជាប់ឃុំឃាំងជាមួយគាត់ បានដើររក ឧសមកឲ្យគាត់ដុតឆ្អើរខ្លួន ។ ប៉ុន្តែក្រោយមក អង្គការបានបំបែក កូនស្រីរបស់គាត់ យកទៅដាក់នៅមន្ទីរឃុំឃាំងវត្តកោះវិញ ។ នៅពេលនោះ ដោយសារពុំមានអាហារហូបគ្រប់គ្រាន់ រឹម ដើររក បេះស្លឹកជ្ញី និងស្លឹកឈើព្រៃខ្លួនឯងមកហូបជាមួយបបរដើម្បីឲ្យ មានទឹកដោះឲ្យកូនបៅ ។ ក្រោយមក កូនរបស់គាត់ក៏ស្លាប់ទៅ ។

រឹម បន្ថែមថា ក្រោយពីគាត់សម្រាលកូនបានប្រាំថ្ងៃ ឈ្លប បានបញ្ជាគាត់ឲ្យចេញទៅកាស់គល់ឈើ និងធ្វើការងារដូចអ្នក ទោសផ្សេងៗទៀត ។ រឹម ជាប់ឃុំឃាំងនៅក្នុងគុកសង់រហូតដល់ កងទ័ពវៀតណាមចូលមករំដោះឆ្នាំ១៩៧៩ ទើបគាត់ជួបជុំកូន ដែលនៅរស់ ហើយត្រឡប់មករស់នៅភូមិ បឹងក្អែកវិញ ។

រឹម មិនដែលធ្វើបុណ្យឧទ្ទិសកុសលជូនប្តីគាត់ទេ ចាប់តាំង ពីប្តីគាត់បាត់ខ្លួនទៅ ។ ស្រាប់តែថ្ងៃមួយ ព្រលឹងប្តីរបស់ រឹម បាន មកពន្យល់សប្តិ រឹម ថាគាត់រស់នៅក្នុងគុកសង់លំបាកខ្លាំងណាស់ ហើយថែមទាំងគ្មានអាហារហូបទៀត ។ ក្រោយពីការពន្យល់សប្តិ នេះ រឹម បានយកចង្ហាន់ទៅវត្ត និងនិមន្តព្រះសង្ឃសូត្រធម៌ឧទ្ទិស កុសលជូនប្តីរបស់គាត់នៅក្នុងគុកសង់ ទើបប្តីរបស់គាត់លែងមក ពន្យល់សប្តិគាត់ទៀត ។

រឹម បានបន្ថែមថា “ទោះបីប្តីគាត់ស្លាប់ទៅរយៈពេលយូរ មកហើយក៏ដោយ ក៏នៅរៀងរាល់ពេលរដូវបុណ្យភ្ជុំបិណ្ឌមកដល់ គាត់បានយកចង្ហាន់ទៅប្រគេនព្រះសង្ឃនៅវត្ត និងឧទ្ទិសបុណ្យ កុសលជូនព្រលឹងប្តី និងកូនរបស់គាត់មិនដែលខានឡើយ ព្រោះ គាត់មានជំនឿថាប្តី និងកូនរបស់គាត់ដែលស្លាប់ទៅដោយសារការ អត់ឃ្លាន និងការរងទារុណកម្មនៅក្នុងរបបខ្មែរក្រហមនឹងទទួលបាន អាហារ និងកុសលដែលគាត់ឧទ្ទិសជូនមិនខាន” ។

រឹម បន្តថា “ព្រលឹងប្តី និងកូនរបស់គាត់នឹងបានទៅចាប់ ជាតិ និងសោយសុខនៅឋានថ្មីដែលមិនមានការកាប់សម្លាប់ដូច របបខ្មែរក្រហម” ។ ចំណែកចិត្តរបស់គាត់វិញក៏បានស្ងប់ស្ងាត់ និង លែងចងគំនុំជាមួយនឹងខ្មែរក្រហមទៀតដែរ ។

**សោម ប៊ុនថន**

## រឿងរ៉ាវពិតដើម្បីប្រវត្តិសាស្ត្រ

មជ្ឈមណ្ឌលឯកសារកម្ពុជាសង្ឃឹមថា ប្រជាជនកម្ពុជា គ្រប់រូបដែលធ្លាប់ឆ្លងកាត់របបខ្មែរក្រហមបាន និងកំពុងសរសេរ អត្ថបទឬសៀវភៅអំពីរឿងរ៉ាវពិតផ្ទាល់ខ្លួន ហើយនឹងផ្ញើមក មជ្ឈមណ្ឌលឯកសារកម្ពុជាតាមអាសយដ្ឋានខាងក្រោម ÷

ផ្ទះលេខ៦៦ មហាវិថីព្រះសីហនុ ភ្នំពេញ

ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទលេខៈ (៨៥៥) (២៣) ២១១ ៨៧៥

ទូរស័ព្ទលេខៈ (៨៥៥) (១៦) ៨៧៦ ៦៩២

ទូរសារលេខៈ (៨៥៥) (២៣) ២១០ ៣៥៨

*Email: truthsocheat@dccam.org*

*Home page: www.dccam.org*

*www.cambodiatribunal.org*

# មេរៀនសម្រាប់ជីវិត

រយៈពេលពីរឆ្នាំចុងក្រោយនេះ មានការសង្កេតឃើញថា សិស្សានុសិស្សរៀនសូត្រពីប្រវត្តិសាស្ត្រខ្មែរក្រហម នៅតាមសាលារៀនទូទាំងប្រទេសពីថ្នាក់ទី៩ ដល់ថ្នាក់ទី១២ ។

ការរៀនសូត្រពីប្រវត្តិសាស្ត្រខ្មែរក្រហមនៅតាមសាលាហាក់បីដូចជាភ្លើងសញ្ញាពណ៌ខៀវដែលជាកត្តាចលករមួយដើម្បីជំរុញឲ្យសិស្សានុសិស្សយល់ដឹងពីប្រវត្តិសាស្ត្ររបស់ខ្លួន ក្រោយពីស្តាប់ព្រឿងរ៉ាវទាំងនោះពីឪពុកម្តាយ ជីដូនជីតា និងបងប្អូន ក៏ដូចជាអ្នកដែលធ្លាប់បានឆ្លងកាត់របបខ្មែរក្រហម ។

ទាក់ទងទៅនឹងការដឹងព្រឿងរ៉ាវនៃរបបខ្មែរក្រហម ជូ ចន្ថា អាយុ២៦ឆ្នាំ មានស្រុកកំណើតនៅខេត្តសៀមរាប បច្ចុប្បន្នជាគរុនិស្សិតកម្រិតបរិញ្ញាបត្រជំនាញអក្សរសាស្ត្រខ្មែរ និងប្រវត្តិវិទ្យានៃវិទ្យាស្ថានជាតិអប់រំបានរំឭកឡើងពីអតីតកាលថា កាលពីគាត់អាយុប្រមាណ១៥ឆ្នាំ ឪពុកម្តាយគាត់ធ្លាប់បាននិយាយប្រាប់ពីការហូបចុកមិនគ្រប់គ្រាន់ ការបង្ខិតបង្ខំឲ្យធ្វើការច្រើន និងការកាប់សម្លាប់នៅក្នុងអំឡុងរបបខ្មែរក្រហម ។

ឪពុកម្តាយគាត់បានរៀបរាប់ថា ជីវិតរស់នៅពិតជាមានភាពលំបាកជាខ្លាំងដែលរកអ៊ីមកនិយាយមិនរួច ។ ពិតមែនតែ ចន្ថា មិនបានឆ្លងកាត់របបនេះដោយផ្ទាល់ ប៉ុន្តែឆ្លងតាមរយៈការរៀបរាប់ពីឪពុកម្តាយ ចន្ថា បានបង្ហាញពីអារម្មណ៍តក់ស្លុត ហើយស្ទើរតែមិនជឿនូវអ្វីដែលបានកើតមាន ។ រហូតមកទសវត្សរ៍ឆ្នាំ៩០ ការសិក្សាពីប្រវត្តិសាស្ត្រខ្មែរក្រហមនៅក្នុងថ្នាក់រៀន ក៏មិនទាន់បានទូលំទូលាយប៉ុន្មាននោះដែរ ។ រីឯការរៀបចំការដាក់បញ្ចូលចំណុចណាមួយគឺត្រូវធ្វើឡើងយ៉ាងប្រុងប្រយ័ត្ន និងធ្វើការសិក្សាស្វែងយល់បន្ថែមដើម្បីឲ្យកម្មវិធីសិក្សាទាំងនេះសមស្របទៅតាមបរិបថសង្គម ។

ដូច្នេះជារួម យើងសង្កេតឃើញថា សិស្សហាក់បីដូចជាមានឱកាសតិចតួចណាស់ដើម្បីទទួលបានចំណេះដឹងពីរឿងរ៉ាវនៃរបបខ្មែរក្រហម ក្រៅតែពីស្តាប់ការរ៉ាយរ៉ាប់ពីលោកគ្រូ-អ្នកគ្រូ ។ ប៉ុន្តែសិស្សទាំងនោះអាចនឹងមានឱកាសដឹងព្រឹត្តិការណ៍ដែលកើតឡើងបានច្រើនជាងបណ្តាសិស្សដទៃទៀត ក្នុងករណីលោកគ្រូ អ្នកគ្រូជាអ្នកដែលធ្លាប់ឆ្លងកាត់ និងរស់នៅក្នុងរបបខ្មែរក្រហម ។




ម្យ៉ាងវិញទៀត រាល់ឯកសារដែលពាក់ព័ន្ធនិងបណ្តាប្រភពព័ត៌មានសំខាន់ៗផ្សេងទៀត មិនទាន់មានការអនុញ្ញាតបើកឲ្យសិក្សាទូលំទូលាយប៉ុន្មានទេ ។ លើសពីនេះ

ចំពោះប្រវត្តិសាស្ត្រខ្មែរក្រហម សិស្សភាគច្រើនយល់ឃើញថា ជាខ្លឹមសារមេរៀនប្រវត្តិវិទ្យា ជាមុខវិជ្ជាដែលគេមិនសូវឲ្យតម្លៃ ។ ជាងនេះទៅទៀត មានលោកគ្រូ-អ្នកគ្រូមួយចំនួនហាក់ដូចជាសម្ដែងនូវភាពរួញរាក្នុងការបង្រៀនអំពីប្រវត្តិសាស្ត្រខ្មែរក្រហម ព្រោះមិនចង់រំពុកឡើងវិញពីប្រវត្តិដ៏កម្សត់និងភាពឈឺចាប់ពីអតីតកាល ។

តាមរយៈការសិក្សាស្រាវជ្រាវរបស់លោកវេជ្ជបណ្ឌិត ការ ស៊ុនបូណាត អ្នកឯកទេសជំងឺផ្លូវចិត្តបានអះអាងថា បុគ្គលដែលរស់រានមានជីវិតជាច្រើនពីរបបខ្មែរក្រហមបានទទួលរងការប៉ះទង្គិចផ្លូវចិត្តយ៉ាងខ្លាំង បន្ទាប់ពីគាត់បានជួបប្រទះនូវព្រឹត្តិការណ៍តក់ស្លុត ឬក៏បទពិសោធន៍គួរឲ្យភ័យខ្លាចដែលនៅតែដក់ជាប់នៅក្នុងអារម្មណ៍របស់គាត់ ។ ការប៉ះទង្គិចផ្លូវចិត្តទាមទាររយៈពេលយូរក្នុងការប្រើប្រាស់វិធីសាស្ត្រសម្របសម្រួលផ្លូវអារម្មណ៍ ។

លោកវេជ្ជបណ្ឌិត បានបន្តទៀតថា មានជនរងគ្រោះមួយចំនួនបានភ្ញាក់ឡើងនៅពេលកណ្ដាលយប់ស្រែករកឲ្យគេជួយឬក៏លួចយំតែម្នាក់បន្ទាប់ពីគាត់នឹកឃើញដល់រឿងរ៉ាវដែលគាត់បានជួបប្រទះនៅក្នុងរបបខ្មែរក្រហម ។

ភ្ជាប់ជាមួយការលើកឡើងខាងលើនេះ អ្នកគ្រូ មុំ ម៉េត បច្ចុប្បន្នជាមន្ត្រីចូលនិវត្តន៍នៃក្រសួងអប់រំ យុវជន និងកីឡា បានសម្ដែងនូវផលលំបាកសម្រាប់ខ្លួនគាត់ផ្ទាល់ក្នុងចូលរួមវគ្គបណ្ដុះបណ្ដាលស្ដីពីការបង្រៀន "ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ១៩៧៥-១៩៧៩" ដែលជាកិច្ចការរបស់គម្រោងស្ដីពីការសិក្សាប្រវត្តិសាស្ត្ររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ។ អ្នកគ្រូបានលើកឡើងថា ពេលចាប់ផ្ដើមបង្រៀនដំបូងៗ ទោះបីគាត់ដឹងខ្លួនថា ជាអ្នកអប់រំដែលតម្រូវឲ្យគាត់រឹងមាំ ហើយឈរនៅចន្លោះកណ្ដាលរវាងជនរងគ្រោះ និងអតីតកម្មាភិបាលខ្មែរក្រហមក៏ដោយ ក៏គាត់មិនអាចទប់អារម្មណ៍ក្ដុកក្ដួលរហូតធ្វើឲ្យនិយាយរួលដើមក និងទឹកភ្នែកហូរចុះមកដោយមិនដឹងខ្លួន ពេលដែលអ្នកគ្រូរំឭកពីការបាត់បង់ប្ដីរបស់គាត់នៅក្នុងរបបខ្មែរក្រហម ។

រយៈពេលជាង៣០ឆ្នាំមកហើយ អ្នកគ្រូ ម៉េត បានលាក់ទុកនូវអារម្មណ៍ទុក្ខព្រួយ និងសោកសៅនៅក្នុងចិត្ត ដោយមិនចង់និយាយប្រាប់អ្នកដទៃឲ្យបានដឹងឮ សូម្បីតែកូនចៅផ្ទាល់របស់គាត់ ។ គាត់ព្យាយាមគិតថា រឿងរ៉ាវនេះគឺជាកម្មពៀរដែលគាត់បានសាងមកពីជាតិមុន ។



មុំ ម៉េត

ទស្សនកម្មពៀរ គឺជាទ្រឹស្តីរបស់ព្រះពុទ្ធដែលជាទ្រឹស្តីមួយមានលក្ខណៈពិតទៅនឹងធាតុពិតនៃជីវិតរស់នៅក្នុងសង្គម សម្រាប់ធ្វើការដាស់តឿនដល់បុគ្គលដែលមានបំណងប្រព្រឹត្តិអំពើមិនគប្បីណាមួយដែលប្រាសចាកទៅនឹងសីលធម៌រស់នៅ និងច្បាប់ក្រឹតក្រមរបស់សង្គម ។ ទស្សនកម្មពៀរនេះបានដាក់ទម្ងន់ខាងផ្លូវអារម្មណ៍បែបចិត្តសាស្ត្រយ៉ាងខ្លាំងទៅលើបុគ្គលដែលបានប្រព្រឹត្តិខុស ប៉ុន្តែមិនមែនជាជនរងគ្រោះនោះទេ ដែលត្រូវទោរទន់ទៅតាមទស្សនៈមួយនេះ ។

ការនិយាយពីជីវិតរស់នៅក្នុងរបបខ្មែរក្រហម មិនមែនជាការដុតបញ្ឆេះកំហឹងឲ្យមានការសងសឹកគ្នានោះទេ ប៉ុន្តែជាការស្រាយនូវភាពឈឺចាប់ដែលបានលាក់កប់ក្នុងចិត្តជាច្រើនឆ្នាំ ។ បន្ថែមពីនេះទៀត ការនិយាយមិនគ្រាន់តែធ្វើឲ្យមានភាពធូរស្រាលក្នុងអារម្មណ៍ប៉ុណ្ណោះទេ ថែមទាំងបានចូលរួមជួយដល់ជនរងគ្រោះផ្សេងទៀតឲ្យដឹងពុះរឿងរ៉ាវដែលបានកើតឡើងស្រដៀងៗគ្នានោះដែរ ។

នៅក្នុងការបង្រៀនប្រវត្តិសាស្ត្រខ្មែរក្រហម ទោះជាមានលោកគ្រូ អ្នកគ្រូជាច្រើនមិនធ្លាប់បានឆ្លងកាត់ផ្ទាល់នៅក្នុងរបបនេះក្តី ប៉ុន្តែអ្វីដែលទទួលបានពីសមាជិកក្រុមគ្រួសារ និងចាស់ទុំ តាមរយៈការនិយាយរៀបរាប់ប្រាប់ដល់គាត់ គឺជាកម្លាំងជំរុញ និងលើកទឹកចិត្តនៅក្នុងការស្វះស្វែងរកចំណុចណាមួយ ដើម្បីលើកឡើងក្នុងការបង្រៀនគាត់ ។

នឹង ចាន់ថា អាយុ៣០ឆ្នាំ បច្ចុប្បន្នជាគរុនិស្សិតកម្រិតបរិញ្ញាបត្រជំនាញប្រវត្តិវិទ្យា និងភូមិវិទ្យា បានលើកឡើងថា “ថ្វីបើខ្ញុំមិនធ្លាប់បានឆ្លងកាត់របបខ្មែរក្រហម ប៉ុន្តែឪពុកម្តាយរបស់ខ្ញុំ គឺជាជនរងគ្រោះដែលរស់នៅស្ថិតក្រោមការគាបសង្កត់ និងការបង្ខិតបង្ខំ” ។ ចាន់ថា ក៏បានចែករំលែកបទពិសោធន៍គួរឲ្យភ័យខ្លាចសម្រាប់ខ្លួនគាត់ផ្ទាល់ថា គាត់មានស្រុកកំណើតនៅស្រុកកោះសូទិន ខេត្តកំពង់ចាម ។ ចន្លោះពីឆ្នាំ១៩៨៥-១៩៨៦ ពេលយប់ ប្រជាជននៅក្នុងភូមិតែតែងមានអារម្មណ៍ភិតភ័យ ព្រោះយោធាខ្មែរក្រហមតែងតែឆ្មក់ចូលភូមិដើម្បីប្លន់ស្បៀងអាហារ និងបាញ់គំរាមកំហែង ឬបាញ់សម្លាប់ប្រជាជននៅក្នុងភូមិចោល ។ ចាន់ថា បន្តថា គាត់តែងលើកយកនូវព្រឹត្តិការណ៍ទាំងនោះមកបង្រៀនដល់សិស្សនៅក្នុងថ្នាក់នៅពេលដែលគាត់បង្រៀន ។


នឹង ចាន់ថា

ក្នុងនាមជាគ្រូបង្រៀនមួយរូប ចន្ទាយល់ឃើញថា ការសិក្សាពីប្រវត្តិសាស្ត្រខ្មែរក្រហម យើងត្រូវតែធ្វើការសិក្សាឲ្យបានស៊ីជម្រៅក្នុងគោលបំណងស្វែងយល់ពីផលប៉ះពាល់ដែលកើតមានក្នុងអំឡុងពេលនោះ ។ ប្រវត្តិសាស្ត្រពិតជាមានសារសំខាន់សម្រាប់យុវជនជំនាន់ក្រោយ ជាពិសេសមេដឹកនាំ ដើម្បីជៀសវាងការដឹកនាំប្រទេសទៅរកផ្លូវខុស និងការទប់ស្កាត់កុំឲ្យរបបខ្មែរក្រហមនេះវិលត្រឡប់មកវិញជាលើកទីពី ។ ស្នាមរបួស ក៏ដូចជាផលប៉ះពាល់ផ្លូវចិត្តដែលបន្សល់ទុកពីសង្គ្រាម គឺជាបទពិសោធន៍គួរឲ្យរន្ធត់ដែលមិនអាចបំភ្លេចបានសម្រាប់ប្រជាជនខ្មែរ ជាពិសេសបុគ្គលដែលធ្លាប់បានជួបប្រទះផ្ទាល់នៅក្នុងអំឡុងរបបខ្មែរក្រហម ។ មកទល់នឹងពេលបច្ចុប្បន្ននេះ រឿងរ៉ាវនៃរបបខ្មែរក្រហមត្រូវបានផ្សព្វផ្សាយយ៉ាងទូលំទូលាយទាំងក្នុងប្រទេស និងពិភពលោក តាមរយៈប្រព័ន្ធឃោសនាជាច្រើនដែលរួមមានទូរទស្សន៍ វិទ្យុ និងបណ្តាញសារព័ត៌មានផ្សេងៗ ។

ទន្ទឹមនឹងនេះ ការរំពុកឡើងវិញ ជាមួយនឹងការពិភាក្សាជាសាធារណៈពីរឿងអតីតកាលរបស់ជនរងគ្រោះនិងអតីតកម្មាភិបាល ហាក់បីដូចជាយកមែកឈើមកចាក់នៅលើមុខរបួសចាស់ដែលកំពុងតែជាបន្តិចម្តងៗ ទៅតាមពេលវេលា ។

ចំណែកជនរងគ្រោះ និងអតីតកម្មាភិបាលទាំងនោះ ក៏បានព្យាយាមបំភ្លេចចោលនូវអ្វីៗដែលខ្លួនមិនចង់នឹកឃើញ ហើយបានព្យាយាមដកខ្លួនគេចចេញពីបញ្ហាទាំងឡាយ ។ ទោះបីយ៉ាងណាក៏ដោយ ក៏វិធីសាស្ត្របែបនេះ មិនមែនជាដំណោះស្រាយដ៏ល្អនោះទេសម្រាប់ប្រទេសដែលបានកើតឡើងនូវអំពើប្រល័យពូជសាសន៍ ។

**ម៉ម សុវណ្ណ**

# យ៉ែម ហ៊ុន អតីតមេក្រុមវរសេនាតូចទី១ កងពល៩២០

យ៉ែម ហ៊ុន អាយុ៥៦ឆ្នាំ មានស្រុកកំណើតនៅស្រុកចម្ការលើ ខេត្តកំពង់ចាម ។ សព្វថ្ងៃរស់នៅស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ ។ ហ៊ុន មានប្រពន្ធឈ្មោះ សឿន ឡាំ អាយុ៤៦ឆ្នាំ ព្រមទាំងមានកូនចំនួនបួននាក់ ប្រុសពីរនាក់ ស្រីពីរនាក់ ។ ឪពុកម្តាយរបស់ ហ៊ុន ស្លាប់អស់ហើយ ។ គាត់ជាកូនទីបីក្នុងចំណោមបងប្អូនប្រុសស្រីប្រាំពីរនាក់ ។

កាលពីក្មេង ហ៊ុន បានរៀនតែបន្តិចបន្តួចប៉ុណ្ណោះ ។ នៅឆ្នាំ១៩៧០ ក្រោយរដ្ឋប្រហារទម្លាក់សម្តេចព្រះនរោត្តម សីហនុ ជារៀងរាល់ថ្ងៃ នៅក្នុងភូមិឃុំដែលគាត់រស់នៅមានការគាបសង្កត់បង្ខិតបង្ខំក្មេងប្រុសៗឲ្យធ្វើទាហានប្រឆាំងនឹងរដ្ឋាភិបាល លន់ នល់ ។ នៅឆ្នាំ១៩៧២ ដោយទ្រាំនឹងការគាបសង្កត់មិនបាន ហ៊ុន ក៏សម្រេចចិត្តចូលធ្វើយោធាខ្មែរក្រហមនៅស្រុកកំពង់សៀមនៅក្នុងវរសេនាតូចលេខ១០៨ជាទ័ពការពារតំបន់៤២ ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ កែ ពក ។ កាលចូលធ្វើយោធាដំបូង ហ៊ុន បានឲ្យដឹងថា មិនមានការហាត់ហ្វឹកហ្វឺនខ្លាំងក្លាទេ គឺមួយថ្ងៃហាត់តែមួយម៉ោងប៉ុណ្ណោះ នៅរសៀលម៉ោងបីដល់ម៉ោងបួន ។ ហ៊ុន នៅកំពង់សៀមបានរយៈពេលពីរឆ្នាំ ។ នៅឆ្នាំ១៩៧៤ គាត់បានផ្លាស់មកនៅស្រុកកំពង់ស្វាយ ខេត្តកំពង់ធំវិញ ដើម្បីធ្វើការប្រយុទ្ធជាមួយទាហាន លន់ នល់ ។ កាលណោះ ហ៊ុន នៅកងពលលេខ១២ ដែលមានតាឈិនជាប្រធានកងពល និងតាសយជាអនុបញ្ញាការ ។ នៅទីនោះ ហ៊ុន ប្រយុទ្ធជាមួយទាហាន លន់ នល់ បានមួយខែ ក៏ផ្លាស់ទៅខាងផ្លូវជាតិលេខ៥ មុំបន្ទាយលង្វែក ។



ក្រោយថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ ទើបកងពលរបស់គាត់ចូលមកភ្នំពេញជាមួយនឹងកងពលដទៃទៀត ដោយទៅនៅកន្លែងផ្សេងៗរៀងៗខ្លួន អ្នកខ្លះទៅនៅខាងជ្រោយចង្វារ ខ្លះទៀតទៅនៅខាងផ្សារថ្មី ។ ពេលមកដល់ភ្នំពេញ ហ៊ុន ស្នាក់នៅក្នុងផ្ទះនៅមុំទួលគោក ។ គាត់បានឲ្យដឹងថា ការមកស្នាក់នៅភ្នំពេញគ្រាន់តែជាការសម្រាកប៉ុណ្ណោះ ។

មួយខែក្រោយមក កងពលលេខ១២របស់គាត់ត្រូវបានអង្គការផ្លាស់ទៅការពារព្រំដែននៅខាងមណ្ឌលគិរី ។ កងពលជាច្រើនបានទៅខេត្តមណ្ឌលគិរីនោះដែរ ដូចជាមកពីខាងតាកែវ កំពត បាត់ដំបង សៀមរាបជាដើម ។ កងពលរបស់ ហ៊ុន ធ្វើដំណើរទៅមណ្ឌលគិរីដោយជិះកប៉ាល់ទឹក ដោយចេញពីភ្នំពេញទៅសម្រាកនៅស្ទឹងត្រង់ បួនថ្ងៃរួចឡើងទៅខេត្តក្រចេះ ហើយសម្រាកនៅទីនោះរយៈពេលជាងបីខែ ។ បន្ទាប់មក ហ៊ុន ក៏បន្តដំណើរទៅមណ្ឌលគិរីទៀត តែមិនបានទៅដល់គោលដៅទេ ដោយសារខ្វះស្បៀងអាហារ ទើបកងពលរបស់គាត់សម្រេចចិត្តត្រឡប់មកក្រចេះវិញ ហើយស្នាក់នៅរហូតដល់អំឡុងខែវិច្ឆិកាឬធ្នូ ទើបចាប់ផ្តើមចេញដំណើរទៅមណ្ឌលគិរីដោយជិះរថយន្តវិញ ។ ពេលទៅដល់ទីនោះ កងពលលេខ១២របស់គាត់បានប្តូរទៅជាកងពល៩២០វិញ ។

នៅមណ្ឌលគិរី កងពលរបស់គាត់ត្រូវបានចាត់តាំងឲ្យបោះទីតាំងនៅមុំកែវសីម៉ា ។ ហ៊ុន ត្រូវផ្លាស់ចូលទៅក្នុងវរសេនាធំទី៣ ឈរជើងនៅកែវសីម៉ាដោយមានឈ្មោះ សឿន ជាប្រធាន

វរសេនាធំ ។ នៅវរសេនាធំទី៣ ហ៊ុន មាននាទីជាមេក្រុមនៅក្នុងវរសេនាតូចទី១ ដែលមានឈ្មោះ ព្រាប ជាប្រធាន និង តាចិត ជាអ្នកគ្រប់គ្រងផ្នែកសេដ្ឋកិច្ច ។ ហ៊ុន បានបន្តទៀតថា នៅកែវសីម៉ា មិនមែននៅក្នុងភូមិស្រុកទេ គឺនៅនឹងព្រៃជាប់ភ្នំនិងមានវាលស្រែធំធេងដែលកងទ័ពធ្វើ ។ នៅទីនោះ ក្នុងការទៅការពារព្រំដែនគឺផ្លាស់ប្តូរគ្នាមួយខែម្តង អ្នកដែលមិនបានទៅការពារព្រំដែន គឺនៅធ្វើស្រែនៅឯកងពល ។ ហ៊ុន បន្តទៀតថា ការធ្វើស្រែ មានការលំបាកជាងការទៅការពារព្រំដែនឆ្ងាយណាស់ ។ ការធ្វើស្រែគឺ ប្រើដោយកម្លាំងសត្វគោក្របីមួយចំណែក និងមួយចំណែកទៀត ដោយកម្លាំងមនុស្សគឺត្រូវកាប់ដោយចប ដោយអង្គការបែងចែកឲ្យម្នាក់ៗ ធ្វើក្បាលដីប្រាំម៉ែត្រ និងបណ្តោយហាសិបម៉ែត្រ ។ ពេលប្រូត បើអ្នកណាគ្រុនអង្គការចាត់ឲ្យប្រូតក្បាលប្រាំម៉ែត្រ បណ្តោយមួយរយម៉ែត្រ និងអ្នកមានសុខភាពធម្មតាឲ្យប្រូតក្បាលដប់ម៉ែត្រ បណ្តោយមួយរយម៉ែត្រ ។ លើសពីនេះទៅទៀត ទិន្នផលស្រូវធ្វើបានច្រើនណាស់ តែរបបដែលទទួលបានក្នុងមួយថ្ងៃបានត្រឹមតែម្នាក់មួយកំប៉ុងកន្ទះប៉ុណ្ណោះ ។ ក្នុងមួយថ្ងៃពីរពេល ថ្ងៃហូបបាយ និងល្ងាចហូបបបរ ។ ទាំងម្ហូប ទាំងបាយ យោធាម្នាក់ៗមិនបានឲ្យធ្វើហូបខ្លួនឯងទេគឺស្រេចតែផ្នែកចុងភៅដួសឲ្យប៉ុណ្ណោះ មិនអាចសុំថែមបានទេ ។ ពេលឈឺមានពេទ្យព្យាបាលនិងថ្នាំលេបគ្រប់គ្រាន់ ប៉ុន្តែមិនបានសម្រាក ព្រោះត្រូវដេកលើកៅស៊ូគង់ក្រាលជាប់នឹងដី ។

ហ៊ុន និយាយថា "ចំពោះអ្នកដែលបានទៅការពារព្រំដែន មានរបបហូបគ្រប់គ្រាន់ ទាំងបាយ ទាំងម្ហូបមិនខ្វះទេ ។ ការងារការពារនោះស្រួលណាស់ គ្រាន់តែទៅធ្វើការបន្តិចបន្តួចរួច ហើយមកវិញចងអង្រឹងដេកដល់ពេលអស់ម្ហូប អស់អង្ករ ចង់ហូបអី គ្រាន់តែប្រាប់ក្វាម អង្គការចាត់ចែងឲ្យក្វាមមិនខ្វះទេ ហើយបាយចង់ដាំហូបមួយថ្ងៃប៉ុន្មានដងក៏បានដែរ" ។

នៅអំឡុងឈរជើងនៅកែវសីម៉ា នៅតំបន់របស់ ហ៊ុន មិនមានការប្រជុំញឹកញាប់ទេ ចំពោះយោធាថ្នាក់ក្រោមគ្រាន់តែយូរៗម្តង មកប្រជុំឲ្យពង្រឹងការខិតខំធ្វើស្រែបង្កបង្កើនផល និងការពារព្រំដែនប៉ុណ្ណោះ ។ ចំណែកការប្រជុំសំខាន់ៗ គឺអង្គការហៅចាប់ពីប្រធានកងតូច កងធំ ឡើងទៅ ហើយបានឲ្យមេៗដែលទៅប្រជុំទាំងអស់នោះមកប្រជុំជាមួយកូនក្រុមរាយការណ៍ពីអ្វីដែលបានចូលរួមប្រជុំ ។ ហ៊ុន បានបន្ថែមទៀតថា "គ្មាននរណាម្នាក់មានសិទ្ធិនិយាយគ្នា ឬលេងសើចជាមួយគ្នាច្រើនទេ តែមេៗ ឃើញនឹងចាប់ខ្លួនមិនខាន ព្រោះនៅតាមវរៈមួយៗមានអ្នកចាំសង្កេតពីសកម្មភាពរបស់យោធា" ។

ហ៊ុន បន្តទៀតថា មួយរយៈដែលគាត់ឈរជើងនៅមណ្ឌលគិរី នោះមិនដែលប៉ះប្រយុទ្ធគ្នាជាមួយវៀតណាមនោះទេ គ្រាន់តែឃើញគ្នាទៅវិញទៅមក នៅដីម្ខាងព្រំដែនម្នាក់ប៉ុណ្ណោះ ។ យើងមើលឃើញគ្នា ព្រោះរវាងព្រំដែនវៀតណាម និងខ្មែរយើងខណ្ឌគ្នា ដោយអូរធំមួយ ។ យើងមិនអាចទាក់ទងជាមួយវៀតណាមផ្តេសផ្តាសបានទេ បើអង្គការដឹង មកវិញប្រាកដជាបាត់ខ្លួនមិនខាន" ។

មានយប់មួយ ពេលដែល ហ៊ុន កំពុងដេក ប្រធានរបស់គាត់បានមកហៅគាត់ ពេលទៅដល់កន្លែងទ្រុងមាន់ ប្រធាននោះបានប្រាប់គាត់ថា "ឥឡូវពួកអ្អែង ! មានគ្នា៦នាក់ យាមមាន់របស់អញ! ប្រសិនបើរួចមាន់អញ! បាញ់អ្អែងចោលហើយ!" ។ ក្រោយពេលឃើញប្រធាននោះឡើងលើផ្ទះបាត់ ហ៊ុន ដើរទៅអើតមើលក្នុងទ្រុងមាន់ឃើញប្រធានកងធំរបស់គាត់ឈ្មោះ ភាគ ដែលត្រូវបានចងយ៉ាងណែន ។ គាត់បានចូលទៅក្នុងទ្រុងមាន់នោះបន្ធូរចំណង ព្រមទាំងឲ្យបារីជក់ និងអាំងសាច់ឲ្យហូបជាមួយបាយទៀតផង ដោយនឹកឃើញថា ធ្លាប់កំសត់កម្រជាមួយគ្នាតាំងពីដើមមក ។ ព្រឹកឡើងប្រហែលម៉ោង៦ ហ៊ុន ឃើញក្រុមពេជ្ឈឃាតមានគ្នាបីនាក់បណ្តើរ ភាគ ចេញពីភូមិទៅព្រៃប្រហែលពីររយម៉ែត្រពីភូមិ មួយសន្ទុះក្រោយមកឮស្នូរកាំភ្លើងបីគ្រាប់ជួនៗគ្នាចេញពីកន្លែងនោះ ។ ហ៊ុន បញ្ជាក់ថា នៅតាមវរសេនាធំនីមួយៗមានក្រុមពេជ្ឈឃាត ។ មួយម៉ោងក្រោយមក គាត់បានលួចទៅមើលកន្លែងនោះឃើញ ភាគ ស្លាប់បាត់ទៅហើយ ដោយដៃទាំងពីរនៅជាប់ចំណងនៅឡើយ ។ ក្រុមពេជ្ឈឃាត បានបាញ់ភាគ បីគ្រាប់ពីក្រោយខ្នង ។

អំឡុងឆ្នាំ១៩៧៥-១៩៧៦ នៅតាមកងពលនីមួយៗ មនុស្សត្រូវគេយកទៅសម្លាប់ច្រើនណាស់ និងក្រោយៗមកទៀត ចាប់ពីថ្នាក់ប្រធានវរសេនាតូចដល់ប្រធានកងពលត្រូវចាប់យកទៅសម្លាប់ទាំងអស់ ដោយយកលេសថា ហៅទៅបំពេញវិជ្ជានៅភ្នំពេញ ។ ក្រោយពីបាត់ដំណឹងជាងបីខែ ទើបដឹងថាអ្នកទាំងនោះត្រូវបានអង្គការកម្ទេចអស់ហើយ ។ ចំពោះ តាឈិន និង តាសយ

អតីតប្រធានរបស់ ហ៊ិន ត្រូវអង្គការចាប់ស្លរចម្លើយ និងចតជាខ្សែ អាត់មកចាក់ឲ្យស្លាប់ទៀតផង ។ ដោយ នៅក្នុងបទសម្ភាសន៍នោះ តាឈិន និងតាសយ បានសារភាពថាបានចូលខ្សែក្បត់ ។ អ្នកនៅក្នុងកងពលទាំងអស់ជឿទាំងស្រុងថា មេៗទាំងពីរនេះជាជនក្បត់ ។

ក្រោយពីតាឈិន និង តាសយ ត្រូវបានកម្ទេច អ្នកដែលមកជំនួសតំណែងអ្នកទាំងពីរមាន តា សាន ហៅ តា០៦ មកពីកងពល ៨០១ ឡើងជាប្រធានកងពល និង តាឡី ជនជាតិលាវ ជាអ្នករស់នៅទីនោះស្រាប់ជាអនុប្រធាន ។ ការផ្លាស់ប្តូរមេថ្មី គឺការរស់នៅហូបចុកមានភាពងាយស្រួលជាងមុន ដោយមួយថ្ងៃហូបបីពេល ហើយការធ្វើស្រែគឺធម្មតា ។

នៅឆ្នាំ១៩៧៩ កងទ័ពវៀតណាមវាយខេត្តមណ្ឌលគិរី ។ ដោយមិនអាចទប់ទល់ជាមួយវៀតណាមបាន យោធាខ្មែរក្រហមក៏នាំគ្នាឆ្លងទន្លេមកខាងស្ទឹងត្រែងវិញ រួចបន្តមកឆ្លងទន្លេមកខាងខេត្តក្រចេះ ត្រង់ចំកោះរង៉ាវ ។ នៅកោះរង៉ាវ បានមួយរយៈ ក្រុមរបស់ ហ៊ិន បានសុំទូកអ្នកស្រុកឆ្លងមកត្រើយម្ខាងទៀតមកនៅខាងលើព្រែកប្រសប់វិញ ព្រោះនៅខាងណោះ កងពល៨០១នៅទីនោះ ហើយទៅដើម្បីសុំស្បៀងគេហូបខ្លះ ។ នៅទីនោះបានមួយរយៈ មេៗខាងកងពល៩២០របស់ ហ៊ិន បានមកហៅក្រុមរបស់គាត់ទៅវិញ ដោយបន្តដំណើរទៅខាងភ្នំជី ។ ហ៊ិន ក៏បានរៀបការនៅទីនោះតែម្តង ។ នៅភ្នំជីបានប្រហែលបីខែ ក្រុមរបស់គាត់ត្រូវអង្គការហៅឡើងទៅខាងភ្នំដងរែកវិញ មកនៅខាងមុំបីដែលស្ថិតក្រោមការគ្រប់គ្រងរបស់តាម៉ុក និងសុន សេន ។

ក្រោយសម័យខ្មែរក្រហមដួលរលំទៅ ហ៊ិន នៅតែធ្វើជាយោធាខ្មែរក្រហមដដែល ។ នៅក្នុងឆ្នាំ១៩៨៥ ក្រោយពីកងទ័ពដណ្តើមបានតំបន់មុំបី ហ៊ិន បានជូនប្រពន្ធទៅស្រុកកំណើតនៅស្រុកបន្ទាយស្រី ហើយក៏បានបែកគ្នាតាំងពីពេលនោះមក ។ នៅឆ្នាំ ១៩៨៦ ហ៊ិន រត់មកធ្វើជាកងឈ្លបនៅកងពល៩១២ ដែលជាឈ្លបរបស់ខ្មែរក្រហមដដែលនៅខាងស្រុកវ៉ារិនវិញ ។ នៅដើមឆ្នាំ ១៩៨៧ ដោយសារតែធ្វើទាហានមានការលំបាកខ្លាំងពេក ហ៊ិន ក៏ឈប់ធ្វើទាហានមកធ្វើជាអ្នកស្រុករកស៊ីធម្មតាវិញ ជាមួយប្រពន្ធក្រោយរបស់គាត់នៅព្រៃស្អាក ។ គ្រួសាររបស់ ហ៊ិន រស់នៅទីនោះដល់ឆ្នាំ១៩៩៨ ទើបត្រឡប់មករស់នៅភូមិរំចេក ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ រហូតដល់បច្ចុប្បន្ន ។

**ផាង សារៈមុនិន្ទ**

# ដំណឹងស្វែងរកបងស្រី

នាងខ្ញុំឈ្មោះ ហ៊ីម ថន អាយុ៥៨ឆ្នាំ រស់នៅភូមិសណ្តោ ឃុំជាងទង ស្រុកត្រាំកក់ ខេត្តតាកែវ សូមប្រកាសស្វែងរកប្អូនប្រុសឈ្មោះ ហ៊ីម ញ៉ាយ ដែលបានបាត់ខ្លួន ក្រោយពីចាកចេញពីភូមិកំណើតទៅធ្វើជានិរសានៅក្នុងរបបខ្មែរក្រហមតាំងពីអាយុ១១ឆ្នាំ ។ ឪពុកនាងខ្ញុំឈ្មោះ បូរ ម្តាយឈ្មោះ ថាន់ ។ នាងខ្ញុំមានបងប្អូន ៦នាក់គឺៈ ១) ហ៊ីម មុំ (ស្រី) ២) ហ៊ីម ឡី (ស្រី) ៣) នាងខ្ញុំ ៤) ហ៊ីម ញ៉ីវ (ប្រុស) ៥) ហ៊ីម ញ៉ាយ (បាត់ខ្លួន) និង ៦) ហ៊ីម ទូច ភេទស្រី (ស្លាប់) ។ ហ៊ីម ញ៉ាយ ត្រូវបានចាត់តាំងឲ្យធ្វើជានិរសារជាមួយមេកងចល័តឈ្មោះ ញ៉ី ហៀង នៅភូមិសណ្តោ ឃុំជាងទង នៅក្នុងរបបខ្មែរក្រហម ហើយបានធ្វើដំណើរទៅតាមកងចល័តរហូត ។ ក្រោយពីរបបខ្មែរក្រហមដួលរលំទៅនៅឆ្នាំ១៩៧៩ ប្អូនប្រុស ហ៊ីម ញ៉ាយ ធ្លាប់ផ្តល់ដំណឹងមកគ្រួសារម្តងតាមរយៈឪពុកមាថា បានទៅធ្វើជាជាងតខ្សែភ្លើងនៅភ្នំពេញ ។ ក្រោយមក ខ្ញុំឮដំណឹងថា ប្អូនប្រុស ញ៉ាយ បានផ្លាស់មកធ្វើការនៅកំពតវិញ ប៉ុន្តែមិនបានត្រឡប់មកស្រុកកំណើតទេ ដោយសារស្រុកកំណើតមិនទាន់មានសន្តិភាព ។ ចាប់តាំងពីពេលនោះមក នាងខ្ញុំបាត់ដំណឹងប្អូនប្រុសរហូតមកទល់សព្វថ្ងៃនេះ ។

អាស្រ័យហេតុនេះ ប្រសិនបើបងប្អូនណាបានទទួលដំណឹងឬធ្លាប់បានស្គាល់ឈ្មោះ ហ៊ីម ញ៉ាយ សូមទាក់ទងមកមជ្ឈមណ្ឌលឯកសារកម្ពុជាតាមរយៈទូរស័ព្ទលេខ ០២៣ ២១១ ៨៧៥ ឬ ០១៦ ៨៧៦ ៦៩២ អាស័យដ្ឋានផ្ទះលេខ ៦៦ មហាវិថីព្រះសីហនុ រាជធានីភ្នំពេញ ។

**សូមអរគុណ!**

# ក្បច់ទឹកទន្លេ

ពីរដងក្នុងមួយឆ្នាំ ចរន្តលំហូរទឹកនៃបឹងទន្លេសាបធ្វើការផ្លាស់ប្តូរទិសដៅរបស់វា ដែលយើងអាចប្រដូចទៅនឹងលំហូរនៃខ្សែជីវិតរបស់មនុស្សដែលឆ្លងកាត់ការកើត ចាស់ ឈឺ ស្លាប់ ។ ម៉ម កល្យាណី គឺជានាយកផ្នែករូបថតនៅក្នុងខ្សែភាពយន្តឯកសារហូលីវូត ក្រោមចំណងជើងថា “INSIDE JOB” ដែលខ្សែភាពយន្តនេះទទួលបានពានរង្វាន់ អូស្ការ ហូលីវូត នៅសហរដ្ឋអាមេរិក ។ ម៉ម កល្យាណី បានចំណាយ ពេលជាងពីរឆ្នាំនៅស្រុក កំណើតរបស់ខ្លួន គឺប្រទេសកម្ពុជា ដើម្បីតាមដានខ្សែ ជីវិតប្រជាជន កម្ពុជាបីរូបដែល រស់នៅក្រោមឥទ្ធិ ពលនៃការកាប់ឆ្ការ ព្រៃឈើ ការនេសាទ ត្រីហួសកម្រិតនិងប្រាក់ បំណុល ។




នៅកណ្តាលព្រៃភ្នំដាច់ស្រយាលនៃភាគឦសានប្រទេសកម្ពុជា សាវ សាមួន រស់នៅជាមួយគ្រួសារក្នុងខ្ទមស្បូវមួយខ្នងសង់នៅលើជម្រៀលភ្នំ ដែលព័ទ្ធជុំវិញដោយចម្ការស្វាយចន្ទីវាលស្រែពណ៌ខៀវស្រងាត់ និងព្រៃដ៏ក្រាស់នៃតំបន់ឦសាន ។ សាមួន និងក្រុមគ្រួសារគឺជាជនជាតិភាគតិចមួយក្នុងចំណោមជនជាតិភាគតិច ទាំងម្ភៃប្អូនក្រុមដែលកំពុងមានវត្តមាននៅក្នុងប្រទេសកម្ពុជាសព្វថ្ងៃ ដែលរស់នៅដោយពឹងផ្អែកលើដី និងធនធានព្រៃឈើ ដើម្បីចិញ្ចឹមជីវិត ។ នៅជុំវិញខ្លួន សាមួន និងក្រុមគ្រួសារបានឃើញដោយផ្ទាល់ភ្នែកនូវការរុករានទន្ទ្រានដីធ្លីពីសំណាក់ក្រុមហ៊ុនធំៗ ការកាប់ឆ្ការ និងការកាប់បំផ្លាញព្រៃឈើ ។ សាមួនដឹងខ្លួនឯងថា គាត់លែងខ្លាចសត្វព្រៃកាចសាហាវ និងខ្មោចទៀតហើយ ដែលធ្លាប់តែដើរត្រាច់ចរក្នុងព្រៃដែលជាលំនៅដ្ឋានរបស់សាមួន ។ ពេលនេះ សាមួនបែរជាមកខ្លាចមនុស្សទៅវិញ ។

បឹងទន្លេសាបដែលមានទីតាំងនៅភាគ កណ្តាលប្រទេសកម្ពុជាគឺជា ជម្រកត្រីនិងជីវចម្រុះគ្រប់ ប្រភេទ ។ ភូមិនេសាទនៅ លើទន្លេគឺជាទីលំ នៅដ្ឋានរបស់ សារី និងគ្រួសារដែល រស់នៅដោយពឹង ផ្អែកលើរបរ នេសាទដើម្បី ចិញ្ចឹមជីវិត ។ ជាកូនច្បងនៅ ក្នុងគ្រួសារដែលមាន បងប្អូនប្រាំមួយនាក់ សារី ត្រូវបង្ខំចិត្តបោះបង់ចោលការ សិក្សាក្នុងវ័យ១៨ឆ្នាំដើម្បីជួយរកស៊ី ចិញ្ចឹមគ្រួសារ ។ ជីវិតនៅលើផ្ទៃទឹកបានផ្លាស់ប្តូរយ៉ាងឆាប់រហ័សដោយសារតែចំនួនត្រីមានការធ្លាក់ចុះយ៉ាងគំហុក ការដាក់ឧបករណ៍ធំៗដើម្បីចាប់ត្រី និងកំណើននៃការនេសាទត្រីខុសច្បាប់ ធ្វើឲ្យរបររកត្រីក៏ធ្លាក់ចុះដែរ ។ សារី និងគ្រួសារបានតស៊ូយ៉ាងលំបាកលំបិនដើម្បីរកត្រីសម្រាប់បរិភោគប្រចាំថ្ងៃ ។ នៅពេលដែល សារី ឈរនៅលើទូករបស់ខ្លួនហើយភ្នែកសម្លឹងទៅរកផ្ទៃទឹកដ៏ធំល្វឹងល្វើយ ដាច់កន្ទុយភ្នែក



សារ៉ សាមួន

ជាមួយនឹងចិត្តនឹកភ្នក់ឆ្ងល់ថាតើអនាគតរបស់ខ្លួននឹងត្រាច់ចរទៅរកទិសខាងណា ។

ក្នុងភូមិដ៏តូចមួយមិនឆ្ងាយប៉ុន្មានពីរាជធានីភ្នំពេញ ខៀវ ហើយនិងម្តាយកំពុងតែប្រមូលផលស្រូវប្រចាំឆ្នាំ ។ ដើម្បីសម្រេចបានកិច្ចការផ្ទះរស្រែចម្ការ ខៀវ និងម្តាយបានទៅខ្ចីបុលគេដើម្បីយកលុយទៅទិញជីស្រែ និងក្របីមួយក្បាល ។ ដើម្បីសងបំណុលគេវិញ ខៀវ បានត្រៀមខ្លួនចូលទៅធ្វើការទៅរោងចក្រនៅក្នុងទីក្រុងភ្នំពេញដើម្បីប្រឡូកជាមួយអ្នកជិតខាងរបស់គាត់ផ្សេងទៀតដែលបានធ្វើចំណាកស្រុករួចទៅហើយ ។ ប៉ុន្តែ នៅក្នុងទីក្រុងដ៏មមាញឹកនេះ ខៀវ ស្វែងយល់ឃើញថា ជីវិតរបស់គាត់និងជីវិតរបស់ក្មេងស្រីឯទៀតដែលកំពុងធ្វើការនៅរោងចក្រត្រូវបែងចែកជាពីរ គឺការតព្វកិច្ចផ្ញើលុយទៅផ្ទះ និងខិតខំសន្សំលុយដើម្បីជួយគ្រួសារនៅផ្ទះឯជនបទ ។ នៅពេលដែល ខៀវ កំពុងរង់ចាំស្រឡាងដើម្បីជិះឆ្លងទៅផ្ទះ គាត់បានបង្ហាញពីវិធីដែលគាត់ និងគ្រួសារអាចរស់រានមានជីវិតបានឆ្ងាយពីទីក្រុង ។



ខៀវ

រឿង "ក្បង់ទឹកទន្លេ" បង្ហាញនូវដំណើរជីវិតមួយដ៏វិសេសវិសាល និងមិនធ្លាប់មានពីមុនមកដែលផ្តើមចេញពីតំបន់ជនបទចុងកាត់មាត់ញក ព្រៃភ្នំ និងភូមិនេសាទនៅលើផ្ទៃទឹកដ៏ស្រស់ត្រកាលទៅកាន់ទីក្រុងភ្នំពេញ ដែលពោរពេញទៅដោយសំណង់អគាររោងចក្រកាត់ដេរ ។ រឿងនេះក៏ឆ្លុះបញ្ចាំងបន្ថែមទៀតនូវ



សារី

រឿងរ៉ាវរបស់ប្រទេសមួយដែលកំពុងតែប្រឈមមុននឹងភាពប្រទាញប្រទង់គ្នារវាងតំបន់ជនបទនាពេលបច្ចុប្បន្ន និងការគំរាមកំហែងនៃឧស្សាហកម្មនាពេលអនាគត ។ ខ្សែភាពយន្តត្រូវបានថតដោយ ម៉ម កល្យាណី, ផលិតដោយ ឆាំង យុ និងជំនួយការផលិតដោយ ឡេង រតនៈ ។

"ក្បង់ទឹកទន្លេ" គឺជាខ្សែភាពយន្តរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ដែលទទួលបានទិដ្ឋាការពីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ លេខ ១៨៨ វ.វ កាលពីថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១២ ។

**មជ្ឈមណ្ឌលឯកសារកម្ពុជា**

# ការិយាល័យព័ត៌មានសាធារណៈ

«ការិយាល័យព័ត៌មានសាធារណៈ» របស់មជ្ឈមណ្ឌលឯកសារកម្ពុជា បានបើកបម្រើជូននិស្សិត អ្នកស្រាវជ្រាវ បុគ្គលិករាជការ និងអង្គការក្រៅរដ្ឋាភិបាល និងបុគ្គលទាំងឡាយដែលមានចំណាប់អារម្មណ៍ចង់យល់ដឹងអំពីប្រវត្តិសាស្ត្ររបបកម្ពុជាប្រជាធិបតេយ្យ និងព្រឹត្តិការណ៍វិវឌ្ឍន៍របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាឬសាលាក្តីខ្មែរក្រហម ។

មជ្ឈមណ្ឌលឯកសារកម្ពុជាជាកន្លែងប្រមូលផ្តុំនិងចងក្រងឯកសារអំពីរបបកម្ពុជាប្រជាធិបតេយ្យបានច្រើនបំផុត ។ ឯកសារនៅមជ្ឈមណ្ឌលឯកសារកម្ពុជាមានប្រាំប្រភេទ ។ ប្រភេទឯកសារទីមួយគឺជាឯកសារជាក្រដាសសន្លឹកដែលមានចំនួនជិតមួយលានទំព័រ ។ ប្រភេទឯកសារទីពីរគឺជាបទសម្ភាសន៍ដែលបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាចុះទៅធ្វើសម្ភាសជាមួយជនរងគ្រោះនិងអតីតកម្មាភិបាលខ្មែរក្រហម ។ ប្រភេទឯកសារទីបីគឺជារូបថតទាក់ទងទៅនឹងសម័យខ្មែរក្រហម ។ ប្រភេទឯកសារទីបួនគឺជាឯកសារទាក់ទងទៅនឹងការធ្វើផែនទីរណ្តៅសាកសព និងទីតាំងសម្លាប់របស់ខ្មែរក្រហម និងឯកសារប្រភេទទីប្រាំគឺជាខ្សែភាពយន្តឯកសារដែលបានផលិតឡើងក្នុងរបបខ្មែរក្រហមនិងសម័យក្រោយមកទៀត ។

តាមរយៈការិយាល័យព័ត៌មានសាធារណៈ សាធារណជនអាចអាននិងស្រាវជ្រាវឯកសារទាំងនេះបាន ។ ឯកសារទាំងនេះរួមមាន ៖ ប្រវត្តិរូបកម្មាភិបាលខ្មែរក្រហម ចម្លើយសារភាព កំណត់ហេតុរបស់បក្ស ទូរលេខឆ្លើយឆ្លង ព័ត៌មានដែលបានមកពីការសម្ភាសន៍ជាមួយអតីតកម្មាភិបាលខ្មែរក្រហម និងទិន្នន័យគន្លងនិទ្ទេសបង្ហាញពីរណ្តៅសាកសព ទីតាំងគុក និងបូជនីយដ្ឋានប្រល័យពូជសាសន៍ ។

«ការិយាល័យព័ត៌មានសាធារណៈ» មានផ្តល់ជូននូវសេវាចម្បងបីយ៉ាង ៖

**១) បណ្ណាល័យ ៖** នៅក្នុងបណ្ណាល័យរបស់យើង សាធារណជនអាចអានឯកសារ សៀវភៅ និងទស្សនាវដ្តី ស្តាប់កាសែតសំឡេង ទស្សនាខ្សែភាពយន្តឯកសារ និងមើលរូបថតដែលបានមកពីមជ្ឈមណ្ឌលឯកសារកម្ពុជា សារមន្ទីរប្រល័យពូជសាសន៍ទួលស្លែង បណ្ណសារដ្ឋានជាតិកម្ពុជា និងពីប្រភពផ្សេងៗទៀត ។

**២) មជ្ឈមណ្ឌលអប់រំ ៖** មជ្ឈមណ្ឌលមានបញ្ចាំងជូននូវខ្សែភាពយន្តឯកសារ និងបង្រៀនអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ប្រធានបទទាក់ទងនឹងអង្គជំនុំជម្រះវិសាមញ្ញ និងប្រធានបទដទៃៗទៀត ។ ភាពយន្តឯកសារអំពីខ្មែរក្រហមមានបញ្ចាំងជូនទស្សនារៀងរាល់ថ្ងៃ ។

**៣) ក្រុមការងារផ្នែកតុលាការ ៖** ទីប្រឹក្សាផ្នែកឯកសារនិងផ្នែកច្បាប់របស់យើងនឹងផ្តល់ជំនួយផ្នែកស្រាវជ្រាវដល់អ្នកជំនាញផ្នែកច្បាប់កម្ពុជានិងអង្គការសហប្រជាជាតិដែលធ្វើការងារផ្នែកតុលាការ ក៏ដូចជាដល់សាធារណជនទូទៅដែរ ។

ការិយាល័យព័ត៌មានសាធារណៈមានទីតាំងនៅអគារលេខ៦៦ មហាវិថីព្រះសីហនុ ខាងកើតវិមានឯករាជ្យ ។ ការិយាល័យរបស់យើងបើកជូនសាធារណជនពីថ្ងៃច័ន្ទដល់ថ្ងៃសុក្រ ពេលព្រឹកពីម៉ោង៨ដល់ម៉ោង១២ និងពេលរសៀលពីម៉ោង២ដល់ម៉ោង៥ ។ ប្រសិនបើអស់លោកអ្នកមានចម្ងល់ ឬចង់រៀបចំព្រឹត្តិការណ៍ជាក្រុមណាមួយ សូមទាក់ទងបុគ្គលិករបស់យើង ស៊ុំ សាវីណា តាមរយៈទូរស័ព្ទលេខ ០២៣ ២១១ ៨៧៥ ។ **សូមអរគុណ ។**

# ដកស្រង់ពីសក្ខីកម្មរបស់សាក្សី ភី ភួន : ការព្រួយបារម្ភចំពោះភាពមិនត្រឹមត្រូវនៃនីតិវិធីសម្ភាសន៍




នៅក្នុងពេលដែល វចឹម ទន់ ហៅ ភី ភួន ហៅ ចៀម ផ្តល់សក្ខីកម្មនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ក្រុមមេធាវីរបស់ អៀង សារី បានលើកឡើងនូវចំណុចមិនប្រក្រតីនៅក្នុងខ្សែអាត់សំឡេងនៃបទសម្ភាសន៍លើកទី២របស់ ភី ភួន ដែលការិយាល័យសហចៅក្រមស៊ើបអង្កេតបានសម្ភាសន៍ជាមួយគាត់ ។ ក្រុមមេធាវីបានកំពុងស្នើឲ្យអង្គជំនុំជម្រះកោះអញ្ជើញអ្នកបកប្រែភាសាដែលមានវត្តមាននៅក្នុងពេលសម្ភាសន៍នោះមកឆ្លើយបំភ្លឺអំពីស្ថានការណ៍នៃការធ្វើបទសម្ភាសន៍នោះ ។ ក្រុមមេធាវីបានចោទថា បទសម្ភាសន៍នេះបង្ហាញឲ្យឃើញពីសកម្មភាពនៃខបាយកលសម្ងាត់មួយ គឺរយៈពេលនៃសម្ភាសន៍នេះដោយសំណួរ និងចម្លើយត្រូវបានរៀបចំដោយយោងទៅតាមអ្វីដែលបានសម្ភាសន៍លើកមុនជាមួយ ភី ភួន ដែលមិនបានថតសំឡេង ។ បន្ទាប់មកគឺអានសំណួរចម្លើយនេះដាក់ក្នុងឧបករណ៍ថតសំឡេងដោយបានបំភាន់ថា ជាការធ្វើបទសម្ភាសន៍ពិតប្រាកដ ។ ព្រឹត្តិការណ៍នេះ បានប៉ះពាល់យ៉ាងខ្លាំងទាំងការពិចារណារបស់អង្គជំនុំជម្រះចំពោះភាពជឿជាក់ទៅលើ ភី ភួន ដែលជាសាក្សីដ៏សំខាន់ម្នាក់ ។ ភី ភួន ប្រហែលជាអាចលាក់បាំង នៅពេលដែលត្រូវបានសួរអំពីនីតិវិធីសម្ភាសន៍ ។ ម្យ៉ាងទៀតគឺទម្ងន់ដែលអង្គជំនុំជម្រះយកចិត្តទុកដាក់ជាពិសេសទៅលើការសង្ខេបបទសម្ភាសន៍របស់ការិយាល័យសហចៅក្រមស៊ើបសង្កេត ដែលមិនសូវស៊ីសង្វាក់គ្នាជាមួយសក្ខីកម្មផ្ទាល់មាត់របស់ ភី ភួន ។

ភាពខុសប្លែករបស់អង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជា ជាមួយតុលាការព្រហ្មទណ្ឌនានានោះ គឺតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម ត្រូវបានយកតាមគំរូប្រព័ន្ធច្បាប់បារាំង civil law ដែលតម្រូវឲ្យចៅក្រមមានតួនាទីក្នុងការស៊ើបអង្កេតជាបឋម ។ ដោយយោងតាមទ្រឹស្តី វាគួរតែបានលទ្ធផលនៃការស៊ើបអង្កេតវែងឆ្ងាយមួយ និងការជំនុំជម្រះតែក្នុងរយៈពេលខ្លីមួយ ។ ភាពមិនលម្អៀង នៃចៅក្រមស៊ើបអង្កេត គឺ "ស្វែងរកការពិត" ដោយប្រមែប្រមូលទាំងភស្តុតាងដែលដាក់បន្ទុក និងដោះបន្ទុកដាក់ក្នុងសំណុំឯកសារ ដែលរួមមានទាំងព័ត៌មានចាំបាច់សម្រាប់ចៅក្រមអង្គសវនាការធ្វើការវិនិច្ឆ័យ ។ ប៉ុន្តែមានតែសាក្សីតិចតួចប៉ុណ្ណោះដែលត្រូវបានមកផ្តល់សក្ខីកម្មផ្ទាល់មាត់ចំពោះសកម្មភាព ឬការប្រព្រឹត្តរបស់ជនជាប់ចោទនៅក្នុងអង្គសវនាការ ។ ដូចដែលយើងបានដឹងហើយថា ចៅក្រមស៊ើបអង្កេត គឺឯករាជ្យ និងអព្យាក្រឹត ដូច្នេះរាល់សេចក្តីថ្លែងការណ៍របស់សាក្សីគួរត្រូវជឿជាក់ និងត្រឹមត្រូវ ដើម្បីទទួលទុកជាភស្តុតាង ដោយមិនចាំបាច់កោះអញ្ជើញសាក្សីជាច្រើនមកបង្ហាញខ្លួនជាលើកទីពីរ នៅក្នុងអង្គសវនាការជំនុំជម្រះក្តីទេ ។

ដូចមាននៅក្នុងអត្ថាធិប្បាយរបស់ខ្ញុំកាលពីលើកមុន "ការអនុញ្ញាតទទួលយកសេចក្តីថ្លែងការណ៍របស់សាក្សី ជំនួសឲ្យការផ្តល់សក្ខីកម្មផ្ទាល់មាត់" ។ សហព្រះរាជអាជ្ញាកំពុងតែស្វះស្វែងរក

ការយល់ព្រមពីអង្គជំនុំជម្រះ ដើម្បីទទួលយកនូវការសង្ខេបបទសម្ភាសន៍យ៉ាងច្រើនរបស់ការិយាល័យសហចៅក្រមស៊ើបសង្កេត ដោយមិនចាំបាច់កោះអញ្ជើញសាក្សីមកផ្តល់សក្ខីកម្មផ្ទាល់មាត់ ។ នីតិវិធីនេះក៏វាស្របជាមួយ «ការអនុវត្តនីតិច្បាប់ civil law តាំងពីមុនពេលបង្កើតអង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជា ។ ច្បាប់បានកំណត់សារសំខាន់ ចំពោះការប្រើប្រាស់កំណត់ត្រាសរសេរ ដែលប្រមែប្រមូលដោយសហចៅក្រមស៊ើបសង្កេត» និងភាពចាំបាច់សម្រាប់ «វិធីសាស្ត្រអាចបត់បែនបាន» នៅក្នុងករណីឧក្រិដ្ឋកម្មធ្ងន់ធ្ងរ ។ ច្បាប់នោះបានចែងថា ៖

> *កំណត់ត្រាសរសេរនៃបទសម្ភាសន៍ ដែលធ្វើឡើងដោយអ្នកស៊ើបអង្កេត ដែលធ្វើការងារនៅក្រោមការគ្រប់គ្រងរបស់សហចៅក្រមស៊ើបអង្កេត អាចមានតម្លៃនិងលក្ខណៈត្រឹមត្រូវគ្រប់គ្រាន់ គឺកំណត់ត្រានោះបានចុះហត្ថលេខាដោយមន្ត្រីតុលាការ និងសាក្សី ដោយស៊ីសង្វាក់ជាមួយនឹងសំឡេងនៅក្នុងឧបករណ៍ថតសំឡេង ។*

ថ្វីបើកាលពីលើកមុនអង្គជំនុំជម្រះបានយល់ព្រមចំពោះសេចក្តីថ្លែងការណ៍លើ «សេចក្តីសន្និដ្ឋាននៃភាពជាប់ពាក់ព័ន្ធ និងភាពត្រឹមត្រូវ» របស់ការិយាល័យសហចៅក្រមស៊ើបសង្កេត ។ ប៉ុន្តែ នៅពេលថ្មីៗនេះ ការិយាល័យសហចៅក្រមស៊ើបសង្កេតខ្វះការគាំទ្រ និងមិនសូវទទួលបានប្រយោជន៍ ចំពោះសំណេរសង្ខេបបទសម្ភាសន៍របស់សាក្សី ។ សំណេរសង្ខេបទាំងនោះទទួលបាន «ភាពមានតម្លៃ ឬភាពមានទម្ងន់តិចតួចណាស់» ដោយអង្គជំនុំជម្រះផ្តល់ឱកាសឲ្យគ្រប់ភាគីប្រឈមមុខជាមួយសាក្សី ។ យ៉ាងហោចណាស់ក៏សំណេរសង្ខេបជាផ្នែកមួយដែលសហចៅក្រមស៊ើបសង្កេតបានអនុវត្តដោយមានថតសំឡេងដាក់ក្នុងឧបករណ៍ថតសំឡេងនៅក្នុងពេលដែលគេជួបសម្ភាសន៍សាក្សី និងបន្ទាប់មកបានកត់ត្រាសង្ខេប ជាជាងការធ្វើប្រតិចារឹកនូវសំឡេងទាំងស្រុង ។

គ្រប់ភាគីទាំងអស់ទទួលស្គាល់ថាការសង្ខេបបទសម្ភាសន៍របស់សាក្សីខ្វះនៅមិនទាន់ត្រឹមត្រូវនៅឡើយ ។ ចៅក្រមអះអាងថារាល់កំហុសឆ្គង មិនបានប៉ះពាល់ដល់ភាពត្រឹមត្រូវនូវការសង្ខេបបទសម្ភាសន៍សាក្សី ។ ផ្ទុយទៅវិញ ក្រុមមេធាវីការពារក្តីពោលថាភស្តុតាងដោះបន្ទុកមិនត្រូវបានដាក់បញ្ចូល ។ ក្រុមរបស់ នួន ជា បានជំទាស់ថា «វត្ថុតាងទាំងឡាយមិនសូវស៊ីសង្វាក់រវាងការសរសេរ និងសំឡេងនៅក្នុងឧបករណ៍ ថតសំឡេងនេះវាឈានទៅរកការមិនគួរឲ្យទុកចិត្តចំពោះការស៊ើបអង្កេតប្រកបដោយសុភវិនិច្ឆ័យ ។ គំរូបញ្ហានៃភាពមិនស៊ីសង្វាក់នៅក្នុងកំណត់ត្រា និងភាពមិនពេញលេញ ដែលផ្តល់ឲ្យអង្គជំនុំជម្រះនេះ ជាហេតុផលមួយដែលការជឿជាក់ថាភស្តុតាងប្រហែលជាត្រូវប្រឌិតឡើង» ។ យោងទៅតាមការធ្វើវិភាគទៅលើការសង្ខេបបទសម្ភាសន៍ចំនួន១៣ បានបង្ហាញបន្ថែមនូវការបាត់ និងលម្អៀងព័ត៌មានដូចខាងក្រោមនេះ កំណត់ត្រាសរសេរតែងតែកែធ្វើឲ្យមានលក្ខណៈខុសពីភាពដើម ហើយសេចក្តីថ្លែងការណ៍ទាំងនោះ សោះកក្រោះទៅក្នុងសក្ខីកម្មចោទប្រកាន់ ដោយមានលក្ខណៈគ្រាន់តែស្របទៅតាមអ្នកស៊ើបអង្កេតប៉ុណ្ណោះ ។ ជាក់ស្តែងគឺមានសំណួរនាំមុខ ដោយថ្លែងការណ៍អះអាងអំពីចំណេះដឹង ។ នេះជាការជះឥទ្ធិពលដល់ការប្រតិបត្តិនៅពេលដែលអ្នកស៊ើបអង្កេតសង្ខេបបទសម្ភាសន៍របស់សាក្សីដោយកត់សំគាល់ទៅតាមលំដាប់លំដោយ និងគ្រប់ជ្រុងជ្រោយ ។ នេះហើយជាការបរាជ័យក្នុងការបង្ហាញអារម្មណ៍ថាវាជាការពិត ។

ក្រុមមេធាវីរបស់ នួន ជា ក៏បានដកស្រង់ស្រដៀងនេះដោយលើកជាឧទាហរណ៍អ្នកស៊ើបអង្កេតធ្វើបទសម្ភាសន៍ជាមួយសាក្សី «ដោយមិនបានថតសំឡេងដាក់ក្នុងឧបករណ៍ថតសំឡេង» ដោយមិនមានប្រតិចារឹកពីបទសម្ភាសន៍ ឬក៏បំពេញបែបបទទោះបីវាជាតម្រូវការស្នូគស្មាញនៃវិធានរបស់អង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជា ដែលសរសេរកំណត់ត្រារាល់បទសម្ភាសន៍ទាំងអស់ក៏ដោយ ក៏ប៉ុន្តែនៅក្នុងសប្តាហ៍នេះ តុលាការបានបោះពុម្ពផ្សាយ ឧទាហរណ៍នៃការអនុវត្តនេះ គឺចាប់ផ្តើមនៃប្រតិចារឹក ដោយសាក្សីនិយាយ «ខ្ញុំបាននិយាយអស់ហើយកាលពីម្សិលមិញ ហើយអ្នកសម្ភាសន៍ត្រូវឆ្លើយថា «ប៉ុន្តែខ្ញុំចង់ឲ្យអ្នករៀបរាប់ឈ្មោះពួកគេម្តងទៀត ពីព្រោះកាលពីម្សិលមិញខ្ញុំមិនបានថតសំឡេងនៅក្នុងឧបករណ៍ថតសំឡេង ។

នៅថ្ងៃទី១ ខែសីហា ឆ្នាំ២០១២ មេធាវីចុងចោទបាននិយាយទៅកាន់អ្នកបកប្រែភាសាដែលមានវត្តមាននៅក្នុងពេលដែលការិយាល័យសហចៅក្រមស៊ើបអង្កេតសម្ភាសន៍ជាមួយ ភីភូន ។ អ្នកបកប្រែភាសាបានបង្ហាញថា អ្នកស៊ើបអង្កេតនៅ

ការិយាល័យសហចៅក្រមស៊ើបអង្កេតបានផ្ញើបទសម្ភាសន៍ជាមួយ ភី ភួន នោះគឺមិនត្រូវបានថតសំឡេងឡើយ ។ អ្នកស៊ើបអង្កេតនៅការិយាល័យសហចៅក្រមស៊ើបអង្កេតបានរៀបចំសរសេរសំណួរចម្លើយ ដោយយោងតាមការផ្ញើសម្ភាសន៍លើកមុនដែលមិនបានថតសំឡេងនោះ បន្ទាប់មកសំណួរចម្លើយទាំងនោះត្រូវបានយកមកអានដាក់ក្នុងឧបករណ៍ថតសំឡេង ។ ចំណែកការសរសេរកំណត់ត្រា ក៏យោងទៅតាមការរៀបចំការថតសំឡេងសំណួរចម្លើយនោះដែរ ។

នៅពេលដែលក្រុមមេធាវី អៀង សារី លើកបញ្ហានេះជាលើកដំបូងទៅលើសក្ខីកម្ម ភី ភួន នៅក្នុងអង្គជំនុំជម្រះគឺ "អ្វីដែលខ្ញុំត្រូវនិយាយនោះ គឺថាយើងកំពុងសួរសំណួរទៅសាក្សីនេះ ។ វាមានបញ្ហាមួយចំនួន ត្រូវសួរអំពីអ្វីដែលកើតមានឡើងនៅក្នុងសក្ខីកម្មរបស់គាត់ ។ ការប្រឈមមុខដោយផ្ទាល់មាត់ប្រហែលជាពុះពារជន្ទះលើនីតិវិធីមិនត្រឹមត្រូវជាច្រើន ដែលបង្កើតឡើងដោយការិយាល័យសហចៅក្រមស៊ើបអង្កេតចំពោះការសង្ខេបបទសម្ភាសន៍ ។ ទោះជាយ៉ាងណាក៏ដោយ ដំណោះស្រាយនេះគឺនៅមិនទាន់មានចម្លើយនៅឡើយ ៖ អ្វីទៅដែលជាតម្លៃនៃការស៊ើបអង្កេតដ៏វែងឆ្ងាយប្រកបដោយសុភវិនិច្ឆ័យមួយបន្ថែមទៅលើដំណើរការរបស់តុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមនេះ បើសាក្សីសំខាន់ម្នាក់នេះចាំបាច់ត្រូវតែហៅមកផ្តល់សក្ខីកម្មនៅអង្គជំនុំជម្រះម្តងទៀត?

**អាន ហាញឌុល**

# ដំណឹងស្វែងរកបងស្រី

ខ្ញុំបាទឈ្មោះ សេក ធា ភេទប្រុស ជាមន្ត្រីរាជការនៅក្រសួងបរិស្ថាន សព្វថ្ងៃរស់នៅផ្ទះលេខ ៖ គ១៣៦ ភូមិ៩ ផ្លូវសុធារសសង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ។ នៅក្នុងរបប ប៉ុល ពត ខ្ញុំនិងគ្រួសាររស់នៅភូមិខ្វយ ឃុំអូម្លូ ស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម ។ ខ្ញុំសូមប្រកាសរកបងស្រីឈ្មោះ សេក សារិន ភេទស្រី កើតនៅឆ្នាំ១៩៥៦ (ឆ្នាំរកា) ។

ខ្ញុំបាទមានឪពុកឈ្មោះ សេក ពិន (ស្លាប់នៅឆ្នាំ១៩៧៨) និងម្តាយឈ្មោះ គឹក វ៉ាន់ (នៅរស់) ព្រមទាំងមានបងប្អូនបង្កើតចំនួន៧នាក់ ដែលមានរាយនាមខាងក្រោម ៖

១) សេក វន ភេទស្រី

២) សេក ប្រាក់ ភេទប្រុស

៣) សេក សារិន ភេទស្រី (បាត់ខ្លួន)

៤) សេក ឡៃ ភេទស្រី

៥) សេក សារឿន ភេទស្រី

៦) សេក ស៊ីណា ភេទស្រី (ស្លាប់ឆ្នាំ១៩៩៣)

៧) សេក ធា ភេទប្រុស (ពៅ)

នៅសម័យ ប៉ុល ពត សេក សារិន ជានារីពេទ្យនៅឃុំអូម្លូ ដោយបានប្តូរឈ្មោះថា មិត្ត មួន ។ ក្រោយឆ្នាំ១៩៧៥ គាត់ត្រូវបានបញ្ជូនទៅនៅមន្ទីរពេទ្យព្រះកេតុមាលា ក្រុងភ្នំពេញមួយរយៈ ។ តមក នៅឆ្នាំ១៩៧៧ ក្រុមគ្រួសារខ្ញុំបានជួបគាត់ចំនួនពីរដងពេលដែលក្រុមគ្រូពេទ្យទៅកាប់អំបោសនៅ ភូមិខ្វយ ។ នៅឆ្នាំ១៩៧៨ ក្រុមគ្រួសារខ្ញុំបានឮដំណឹងថាក្រុមគ្រូពេទ្យមិត្ត មួន ត្រូវរំសាយឲ្យទៅនៅកងចល័តដោយមិនដឹងមូលហេតុ ហើយចាប់តាំងពីនោះមកដល់របប ប៉ុល ពត ដួលរលំក៏បាត់ដំណឹងគាត់រហូត ។

ប្រសិនបើបងប្អូនណាបានឮ ឬស្គាល់ឈ្មោះដូចខាងលើ សូមមេត្តាទាក់ទងមកខ្ញុំបាទតាមរយៈ អាសយដ្ឋានដូចមានរៀបរាបខាងលើ ឬតាមរយៈទូរស័ព្ទលេខ ០១២ ៦០០ ៩៦៦ ឬមជ្ឈមណ្ឌលឯកសារកម្ពុជា ០១៦ ៨៧៦ ៦៩២ ។ **សូមអរគុណ ។**

# សេចក្តីសម្រេចក្នុងការដោះលែងជនជាប់ចោទ អៀង ធីរិទ្ធ ពីមន្ទីរឃុំឃាំង

អៀង ធីរិទ្ធ ដែលជាជនជាប់ចោទម្នាក់ក្នុងចំណោមជនជាប់ចោទបួននាក់ដែលត្រូវបានចោទប្រកាន់ដោយអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ត្រូវបានដោះលែងចេញពីមន្ទីរឃុំឃាំងកាលពីថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១២ ក្រោយពីជនជាប់ចោទរូបនេះត្រូវបានរកឃើញថា មិនមានសម្បទាគ្រប់គ្រាន់ក្នុងការចូលរួមក្នុងកិច្ចដំណើរការតុលាការដោយសារតែអាការជំងឺវង្វេងវង្វាន់ភ្លេចភ្លាំងធ្ងន់ធ្ងរ ។ កាលពីដើមខែកញ្ញាកន្លងទៅ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានសម្រេចថា អៀង ធីរិទ្ធ ដែលមានអាយុ៨០ឆ្នាំ និងជាស្ត្រីតែម្នាក់គត់ដែលត្រូវបានចោទប្រកាន់ដោយតុលាការនេះ ត្រូវបានដោះលែងដោយគ្មានលក្ខខណ្ឌពីមន្ទីរឃុំឃាំង តែ អៀង ធីរិទ្ធ ឋិតនៅក្រោមបទចោទប្រកាន់ដដែល ។ ភាគីព្រះរាជអាជ្ញាបានប្តឹងទៅឧទ្ធរណ៍ចំពោះសេចក្តីសម្រេចនេះដោយទាមទារឲ្យមានលក្ខខណ្ឌខ្លះចំពោះការដោះលែង អៀង ធីរិទ្ធ ។ អង្គជំនុំជម្រះតុលាការកំពូលរកឃើញថា មិនមានការចាំបាច់ណាមួយក្នុងការរក្សាទុក អៀង ធីរិទ្ធ នៅក្នុងមន្ទីរឃុំឃាំងទេ ខណៈពេលដែលតុលាការកំពូលកំពុងតែពិចារណានិងដោះលែងជនជាប់ចោទរូបនេះដោយភ្ជាប់នូវភស្តុតាងមួយចំនួន ។ តុលាការកំពូលមានពេលតិចជាង១៥ថ្ងៃដើម្បីកំណត់ថាតើលក្ខខណ្ឌសមរម្យណាមួយក្នុងការដោះលែង អៀង ធីរិទ្ធ ក្នុងករណីដែលគាត់មានជំងឺវង្វេងវង្វាន់ ។



រូបទី៣ រាប់ពីស្តាំ ៖ អៀង ធីរិទ្ធ ជួបជាមួយគណៈប្រតិភូបរទេស ពេលធ្វើទស្សនកិច្ចនាប្រទេសជប៉ុន និងរូបខាងស្តាំបំផុតឈ្មោះ សែម អ្នកចម្រៀង នៅក្រសួងអប់រំ និងឃោសនាការនៃរបបកម្ពុជាប្រជាធិបតេយ្យ

ក្រោយពីការវិភាគផ្នែកវេជ្ជសាស្ត្រដ៏ហ្មត់ចត់និងសវនាការជាច្រើនដងមក អង្គជំនុំជម្រះបានរកឃើញកាលពីខែវិច្ឆិកា ឆ្នាំមុនថា អៀង ធីរិទ្ធ "មិនអាចយល់ឲ្យបានគ្រប់គ្រាន់ទេក្នុងអំឡុងពេលសវនាការមកលើរូបគាត់ ហើយការមិនយល់បែបនេះ អៀង ធីរិទ្ធ មិនអាចទទួលការណែនាំឲ្យបានជាក់លាក់និងមានប្រសិទ្ធភាពពីសំណាក់មេធាវីបានទេ ហើយគាត់ក៏មិនអាចចូលរួមសវនាការឲ្យបានជាក់លាក់ដើម្បីការពារខ្លួនឯងបានដែរ" ដែលធ្វើឲ្យ អៀង ធីរិទ្ធ មិនមានកាយសម្បទាគ្រប់គ្រាន់ក្នុងការចូលរួមក្នុងតុលាការព្រហ្មទណ្ឌអន្តរជាតិរបស់ករណីជនជាប់ចោទ ស្រ្តីម្នា ។ តុលាការកំពូលបានសម្រេចបោះបង់ចោលការចោទប្រកាន់ក្នុងករណី០០២និងសម្រេចដោះលែង អៀង ធីរិទ្ធ ពីករណី០០២ ។

តុលាការកំពូលបានប្រឆាំងទៅនឹងសេចក្តីសម្រេចដោយរកឃើញថា ដើម្បីផលប្រយោជន៍យុត្តិធម៌ "ក្រោយពីរកឃើញថាមិនមានសម្បទាគ្រប់គ្រាន់ វិធានការណ៍សមស្របណា

មួយត្រូវតែចាត់ជាចាំបាច់តាមតែអាចធ្វើទៅបាន ទោះបីជាតិចតួចក្តី គឺដើម្បីភាពរីកចម្រើនដែលអាចធ្វើទៅបានណាមួយ» ។ ក្នុងកិច្ចខិតខំប្រឹងប្រែងដើម្បី «ប្រើប្រាស់ឲ្យអស់ធនធានដែលអាចរកបានក្នុងការជួយឲ្យស្ថានភាពជនជាប់ចោទឲ្យមានសម្បទាឡើងវិញ» តុលាការកំពូលបានបង្គាប់ឲ្យ អៀង ធីរិទ្ធ បន្តនៅក្នុងមន្ទីរឃុំឃាំងរយៈពេលប្រាំមួយខែទៀតដើម្បីទទួលការព្យាបាលបន្ថែម ។

កាលពីខែសីហា អ្នកជំនាញវេជ្ជសាស្ត្របីរូបបានធ្វើការវាយតម្លៃទៅលើស្ថានភាពសុខភាពរបស់ អៀង ធីរិទ្ធ ម្តងទៀត ហើយរកឃើញថា ស្ថានភាពផ្លូវចិត្តរបស់ អៀង ធីរិទ្ធ កាន់តែមានសភាពធ្ងន់ធ្ងរជាងមុន ។ គ្រូពេទ្យរបស់ អៀង ធីរិទ្ធ មិនយល់ស្របទៅនឹងរបាយការណ៍របស់អ្នកជំនាញវេជ្ជសាស្ត្រទាំងបីរូបខាងលើទេ ហើយបានដាក់របាយការណ៍ដោយខ្លួនឯងមួយ ដោយអះអាងថា អៀង ធីរិទ្ធ គ្រាន់តែទទួលរងជំងឺបាត់បង់ការចងចាំធម្មតាប៉ុណ្ណោះ ដែលជាជំងឺធម្មតារបស់មនុស្សចាស់ ។ ការរកឃើញដែលមានលក្ខណៈចម្រូងចម្រាស់គ្នានេះត្រូវបានយកមកពិភាក្សាក្នុងសវនាការ ។ អ្នកជំនាញវេជ្ជសាស្ត្រមាន មន្ទិលសង្ស័យទៅនឹងវិធីសាស្ត្រនិងការវិនិច្ឆ័យរបស់គ្រូពេទ្យ ចក់ ធីតា ដែលបានអះអាងថា ខ្លួនមានលក្ខណៈថតភាពច្រើនជាង ព្រោះតែខ្លួនជាស្ត្រី និងជាជនជាតិខ្មែរ ដែលមានទំនាក់ទំនងជាមួយ អៀង ធីរិទ្ធ យ៉ាងល្អប្រសើរជាមួយគ្នា ។

ដោយផ្អែកលើយោបល់របស់គ្រូពេទ្យ ចក់ ធីតា ភាគីដើមបណ្តឹងរដ្ឋប្បវេណីបានស្នើសុំឲ្យមានការតែងតាំងអ្នកជំនាញបន្ថែមទៀតដែលរួមមានគ្រូពេទ្យស្ត្រីដែលមានដើមកំណើតនិយាយភាសាខ្មែរ ដែល «ស្គាល់វប្បធម៌ខ្មែរ និងមិនមានឧបសគ្គក្នុងការនិយាយភាសាខ្មែរជាមួយជនជាប់ចោទ» ។

ផ្ទុយមកវិញ ដោយយោងទៅតាមយោបល់របស់អ្នកជំនាញ ទាំងភាគីការពារក្តី និងភាគីព្រះរាជអាជ្ញា បានយល់ព្រមថា អៀង ធីរិទ្ធ មិនមានសម្បទាគ្រប់គ្រាន់ដើម្បីចូលរួមក្នុងដំណើរការកាត់ទោសបានទេ ហើយគួរតែត្រូវបានដោះលែងចេញពីមន្ទីរឃុំឃាំងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ ប៉ុន្តែខណៈពេលដែលភាគីការពារក្តីស្នើឲ្យមានការដោះលែងដោយគ្មានលក្ខខណ្ឌ ភាគីព្រះរាជអាជ្ញាទាមទារឲ្យមានលក្ខខណ្ឌចំនួនប្រាំមួយក្នុងការដោះលែង ៖

១) ជនជាប់ចោទត្រូវជូនដំណឹងដល់អង្គជំនុំជម្រះអំពីអាសយដ្ឋានដែលខ្លួនត្រូវស្នាក់នៅ ហើយមិនត្រូវប្តូរទីលំនៅដោយមិនមានការអនុញ្ញាតពីអង្គជំនុំជម្រះឡើយ ។

២) ជនជាប់ចោទត្រូវបានទទួលការត្រួតពិនិត្យពីសុវត្ថិភាពដោយអាជ្ញាធរឬមន្ត្រីដែលតែងតាំងដោយអង្គជំនុំជម្រះ ។

៣) ជនជាប់ចោទត្រូវប្រគល់លិខិតឆ្លងដែន និងឯកសារធ្វើដំណើរពាក់ព័ន្ធដទៃទៀត ។

៤) ជនជាប់ចោទមិនត្រូវទាក់ទងដោយផ្ទាល់ ឬដោយប្រយោលជាមួយជាមួយជនជាប់ចោទផ្សេងទៀតឡើយ (លើកលែងតែប្តីរបស់ខ្លួនគឺ អៀង សារី)

៥) ជនជាប់ចោទមិនត្រូវទាក់ទងដោយផ្ទាល់ និងដោយប្រយោលជាមួយសាក្សី អ្នកជំនាញ ឬ ជនរងគ្រោះណាម្នាក់ដែលនឹងត្រូវមកធ្វើសក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះ ហើយមិនត្រូវជ្រៀតជ្រែក ជាមួយរដ្ឋបាលយុត្តិធម៌ណាមួយឡើយ និង

៦) ជនជាប់ចោទត្រូវទទួលការព្យាបាលសុខភាពដោយគ្រូពេទ្យដែលចាត់តាំងដោយអង្គជំនុំជម្រះរៀងរាល់ប្រាំមួយខែម្តងដែលលើកទីមួយនឹងត្រូវធ្វើនៅក្នុងអំឡុងខែមីនា ឆ្នាំ២០១៣ ។

អង្គជំនុំជម្រះបានជំទាស់ទៅនឹងសំណើរបស់ភាគីដើមបណ្តឹងរដ្ឋប្បវេណី ដែលរកឃើញថា អ្នកជំនាញវេជ្ជសាស្ត្រ «មានការលំបាកក្នុងការយល់ដឹងឲ្យបានគ្រប់ជ្រុងជ្រោយអំពីវប្បធម៌ និងភាសាក្នុងការត្រួតពិនិត្យស្ថានភាពរបស់ជនជាប់ចោទ» និងរកឃើញទៀតថា របាយការណ៍របស់គ្រូពេទ្យ ចក់ ធីតា មិនស៊ីគ្នាទៅនិងការសន្និដ្ឋានរបស់អ្នកជំនាញទាំងបីទេ ។ ភាគីដើមបណ្តឹងរដ្ឋប្បវេណីបានបញ្ជាក់ថា មានវិធានការណ៍ជាច្រើនដែលត្រូវបានធ្វើឡើងដើម្បីជួយឲ្យស្ថានភាពរបស់ជនជាប់ចោទប្រសើរឡើង តែជនជាប់ចោទនៅតែមិនអាចបញ្ជាក់នូវសិទ្ធិស្របច្បាប់នៅចំពោះមុខតុលាការ និងមិនមានសម្បទាគ្រប់គ្រាន់ក្នុងការចូលរួមក្នុងកិច្ចដំណើរការកាត់ទោស ។ អង្គជំនុំជម្រះបានសម្រេចថា កិច្ចដំណើរការនៃការដោះលែង អៀង ធីរិទ្ធ គឺ «មិនមានកាលកំណត់ណាមួយរហូតដល់ និងលុះត្រាតែអង្គជំនុំជម្រះចាប់ផ្តើមកិច្ចការចោទ

ប្រកាន់បន្តប្រឆាំងនឹងជនជាប់ចោទ» ។

ទោះបីជាអង្គជំនុំជម្រះបានអះអាងថា «មិនមានការរំពឹងទុកដ៏សមហេតុផលណាមួយ» ដែលស្ថានភាពផ្លូវចិត្តរបស់ អៀង ធីរិទ្ធ អាចវិលមករកដូចដើមវិញនោះ អង្គជំនុំជម្រះបានអះអាងថា ក្នុងការថែទាំស្ថានភាពអ្នកដែលមានជំងឺវង្វេងវង្វាន់គឺអាចធ្វើទៅបាន ហើយអង្គជំនុំជម្រះបានយល់ស្រប និងធ្វើការពិគ្រោះជាមួយអ្នកជំនាញមួយឆ្នាំម្តងដើម្បីមើលថាតើមានវិធីសាស្ត្រព្យាបាលជំងឺថ្មីៗដែលជួយឲ្យជនជាប់ចោទអាចវិលទៅរកសភាពដើមបានវិញដែរឬទេ ។

ទាក់ទងទៅនឹងលក្ខខណ្ឌមួយចំនួនដែលស្នើដោយភាគីព្រះរាជអាជ្ញា អង្គជំនុំជម្រះរកឃើញថា ខ្លួន «មិនអាចអនុវត្តវិធានច្បាប់ទៅលើជនជាបចោទក្នុងអំឡុងពេលនៃការស្នាក់នៅក្នុងផ្ទះរបស់ជនជាប់ចោទបានទេ» ហើយអង្គជំនុំជម្រះត្រូវតែដោះលែងជនជាប់ចោទដោយគ្មានលក្ខខណ្ឌព្រោះៈ

១) អង្គជំនុំជម្រះកង្វះខាតនូវមូលដ្ឋានច្បាប់ដើម្បីដាក់លក្ខខណ្ឌបង្ខំ និង

២) ស្ថានភាពផ្លូវចិត្តធ្វើឲ្យលក្ខខណ្ឌទាំងអស់នោះមិនអាចអនុវត្តបាន និងមិនអាចបង្ខំបាន ។

ពេលប្តឹងទៅឧទ្ធរណ៍ ភាគីព្រះរាជអាជ្ញាបានអះអាងថា អង្គជំនុំជម្រះបានសម្រេចចិត្តខុសដោយ «ដកហូតវិធានផ្លូវច្បាប់ខ្លួនឯង» ។ ភាគីព្រះរាជអាជ្ញាបានអះអាងថា ការដែលអនុញ្ញាតឲ្យមានការថែទាំវេជ្ជសាស្ត្រ និងធ្វើឲ្យស្ថានភាពប្រសើរឡើងការស្នាក់នៅផ្ទះរបស់ជនជាប់ចោទគឺមិនមែនអចិន្ត្រៃយ៍ទេ តែអាចត្រឡប់មកកាន់អង្គជំនុំជម្រះវិញបាន ។ ហេតុដូចនេះ អង្គជំនុំជម្រះគួរតែបញ្ជាក់ឲ្យបានជាមុនថា បើការឃុំខ្លួនបន្តគឺជារឿងសមរម្យគួរតែយកមកពិចារណា ហើយប្រសិនបើ «ក្នុងកាលៈទេសៈណាមួយនៃករណីនេះ» ការដោះលែងដោយមាន និងគ្មានលក្ខខណ្ឌនោះគឺត្រូវតែធានាឲ្យច្បាស់ ។ ផ្ទុយមកវិញ ក្រោយពីចេញសេចក្តីសម្រេចអំពីការមិនមានការឃុំខ្លួនបន្ត អង្គជំនុំជម្រះ បានរកឃើញដោយភាន់ច្រឡំថា វិធានការណ៍បង្ខិតបង្ខំមិនគួរយកមកពិចារណា និងបង្គាប់ឲ្យធ្វើដូច្នេះទេ ។

សេចក្តីសម្រេចអំពីភាពសមរម្យនៃលក្ខខណ្ឌបង្ខិតបង្ខំអាចនិងរកឃើញនៅក្នុងសេចក្តីសម្រេចកាលពីខែធ្នូ ឆ្នាំ២០១១ ។ នៅក្នុងសេចក្តីសម្រេចនោះ អង្គជំនុំជម្រះតុលាការកំពូលបានពិចារណាយុត្តិសាស្ត្រច្បាប់អន្តរជាតិ និងរកឃើញថា «ការដោះលែងដោយគ្មានលក្ខខណ្ឌមិនមែនជាយោបល់ដែលមានតែមួយជម្រើសចំពោះតុលាការឧក្រិដ្ឋកម្មអន្តរជាតិដែលនៅតែបិតក្នុងដំណើរការកាត់ទោសដដែលទោះជាមានឧបសគ្គ» ដែលអាចនឹងលប់ចោលនាពេលអនាគត ។ លើសពីនេះទៅទៀត មានវត្តមានបែបនេះ នៅក្នុងប្រព័ន្ធច្បាប់កម្ពុជាចំពោះការគ្រប់គ្រងការដោះលែង ។ ពិសេសជាងនេះទៅទៀត អង្គជំនុំជម្រះតុលាការកំពូលរកឃើញថា «មិនស៊ីសង្វាក់គ្នាចំពោះបុព្វហេតុយុត្តិធម៌» ដោយបញ្ជាក់ថា អង្គជំនុំជម្រះ បានពិចារណាឲ្យជនជាប់ចោទបន្តស្នាក់នៅក្នុងមន្ទីរឃុំឃាំងបណ្តោះអាសន្ន និងអាចយកមកបញ្ចូលក្នុងកិច្ចដំណើរការវិញ ប្រសិនបើស្ថានភាពរបស់ជនជាប់ចោទមានភាពប្រសើរឡើង ដោយគ្មានលក្ខខណ្ឌអ្វីមួយទេ «ដោយបន្តធ្វើកិច្ចការទៅមុខទៀតក្នុងទិសដៅកិច្ចដំណើរការប្រឆាំងនឹងជនជាប់ចោទ» ។ លទ្ធផលនៃសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលបង្កឲ្យមានការងឿងឆ្ងល់ថា តើអង្គជំនុំជម្រះតុលាការកំពូលយល់ស្របទៅនឹងសំណើរបស់ព្រះរាជអាជ្ញាដែរឬអត់ដែលសេចក្តីសម្រេចរបស់អង្គជំនុំជម្រះបញ្ជាក់ពីលទ្ធភាពថា អៀង ធីរិទ្ធ អាចនឹងយកមកកាន់តុលាការនាពេលណាមួយនាថ្ងៃអនាគត ។

បទបញ្ញារបស់អង្គជំនុំជម្រះតុលាការកំពូលក្នុងការដោះលែង អៀង ធីរិទ្ធ បន្ទាប់ពីជាប់ឃុំឃាំង អស់រយៈពេលប្រាំឆ្នាំ បានបញ្ជាក់ច្បាស់ថា អង្គជំនុំជម្រះតុលាការកំពូល និងគាំទ្រឲ្យមានការដោះលែងដូចទៅនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះ និងអ្វីដែលត្រូវបានលើកឡើងដោយភាគីព្រះរាជអាជ្ញា ។ ទោះបីជាអ្នករួចរស់ជីវិតពីរបបខ្មែរក្រហមមានការក្តៅក្រហាយទៅនឹងការដោះលែងនេះបន្ទាប់ពីរង់ចាំភាពយុត្តិធម៌អស់រយៈពេលជាងសាមសិបឆ្នាំក៏ដោយ ជនរងគ្រោះក៏អាចនឹងទទួលយកបានចំពោះការដោះលែងនេះដែរ ត្រង់ថា ការដោះលែងនេះគឺជាទម្រង់មួយនៃភាពយុត្តិធម៌ដែលនឹងអាចយកមកអនុវត្តនៅក្នុងប្រព័ន្ធច្បាប់កម្ពុជា ។

**អាន ហាញឌុល**

# ហេតុអ្វីបានជាកម្ពុជាត្រូវសម្លឹងមើលឱ្យហួសពីអង្គជំនុំជម្រះ វិសាមញ្ញក្នុងតុលាការកម្ពុជាដើម្បីយុត្តិធម៌?

ចំពោះមនុស្សជាច្រើន ផ្លូវដីនៅក្នុងរូបដែលឆ្ពោះទៅកាន់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាធ្វើឲ្យយើងនឹកទៅដល់អត្ថបទដែលមានចំណងជើងថា "ផ្លូវដីវែងឆ្ងាយឆ្ពោះទៅកាន់យុត្តិធម៌" ដែលសរសេរដោយលោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា ។ ចំពោះចំណុចខ្លះ ផ្លូវដី និងមានគ្រលុកជាច្រើនគឺប្រៀបដូចជាឧបសគ្គដែលតុលាការឧបត្ថម្ភដោយអង្គការសហ



ផ្លូវចូលទៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា




ប្រជាជាតិជួបប្រទះនៅអំឡុងពេលកាត់ទោសអ្នកដែលត្រូវទទួលខុសត្រូវចំពោះការសម្លាប់ប្រជាជនកម្ពុជាមួយភាគបួននៃប្រជាជនទាំងអស់ដោយខុសច្បាប់ដើម្បីនាំយកទីបញ្ចប់ដែលមានការពេញចិត្តពីមនុស្សគ្រប់ៗគ្នា ។

ចំពោះការសាកសួរសាក្សី រចឹម ទន់ និងសាក្សីជំនាញសាស្ត្រាចារ្យ ដេវីដ ឆេនដល័រ ដែលបានបញ្ចប់នៅពេលថ្មីៗនេះ បង្ហាញឲ្យឃើញថា សវនាការលើសំណុំរឿង០០២ ប្រឆាំងនឹងជនត្រូវចោទ នួន ជា, ខៀវ សំផន និង អៀង សារី មានដំណើរការល្អ ។ ទោះបីជាមានការចោទប្រកាន់អំពីការជ្រៀតជ្រែកផ្នែកនយោបាយ ភាពមិនយុត្តិធម៌ក្នុងការកាត់ទោស និងអំពើពុករលួយក៏ដោយ ក៏សវនាការនៅតែបន្តផ្តល់ឱកាសឲ្យប្រជាជនកម្ពុជារាប់ពាន់នាក់ចូលរួមក្នុងដំណើរការស្វែងរកយុត្តិធម៌ ហើយនៅពេលជាមួយគ្នានេះដែរក៏រំពូកដល់ជំពូកដ៏ខ្មៅងងិតមួយនៃប្រវត្តិសាស្ត្រ ។

នៅក្នុងចំណោមប្រជាជនរាប់រយនាក់ដែលបានធ្វើដំណើរពីចម្ងាយមកកាន់សាលាក្តីខ្មែរក្រហមនៅប៉ុន្មានសប្តាហ៍មុន អ្នកខ្លះបានបង្ហាញពីអារម្មណ៍និងប្រតិកម្មចំពោះដំណើរការរបស់តុលាការនៅពេលធ្វើបទសម្ភាសន៍ដោយរៀបរាប់ពីសេចក្តីលម្អិតដែលជនដៃដល់ប្រព្រឹត្តប្រល័យពូជសាសន៍ អ្នកខ្លះទៀតលើកឡើងពីដំណើរការផ្សះផ្សាដើម្បីនាំមកនូវសន្តិភាពនៅក្នុងប្រទេស ។

**សេចក្តីសង្ខេបឧបសគ្គដែលជួបប្រទះដើម្បីឆ្ពោះទៅកាន់យុត្តិធម៌**

ទាក់ទងនឹងពាក្យចចាមអារាមនៃការអស់ថវិកាយើងនឹងមានការងឿងឆ្ងល់ថាតើតុលាការអាចដំណើរទៅមុខទៀតដោយរបៀបណា? សាលាក្តីខ្មែរក្រហម ត្រូវការជំនួយថវិកា៩១លានដុល្លារសហរដ្ឋអាមេរិក បន្ថែមទៅលើថវិកា១៥០លានដុល្លារ


គង់ វ៉ិន

ដែលទទួលរួចមកហើយដើម្បីដំណើរការរហូតដល់ឆ្នាំ២០១៣ និងបន្តដំណើការសើុបអង្កេតរបស់តុលាការក្នុងសំណុំរឿង ០០៣ និង ០០៤ ។ នៅពេលដែលយើងសួរអ្នកភូមិថាតើគាត់មានដឹងពីការស្វែងរកជំនួយថវិការនៅសាលាក្តីខ្មែរក្រហមដែរឬទេ គង់ វ៉ិន ដែលមកពីខេត្តព្រៃវែងដឹងថា ដំណើរការកាត់ទោសតម្រូវឲ្យការចំណាយខ្ពស់ ។ ប៉ុន្តែ គាត់សង្ឃឹមថាអ្នកផ្តល់ជំនួយក្នុងស្រុក និងអន្តរជាតិនឹងបន្តផ្តល់ជំនួយដល់ដំណើរការស្វែងរកយុត្តិធម៌របស់កម្ពុជាទោះបីជាវាតម្រូវឲ្យមានការចំណាយខ្ពស់ក៏ដោយ ។ ជាមួយនឹងដំណើរការនីតិវិធីទាំងនេះ គង់ វ៉ិន ចង់ឲ្យក្មេងជំនាន់ក្រោយអាចអង្កេតដើម្បីសិក្សា និងតាមដានដើម្បីប្រើប្រាស់មេរៀននេះដើម្បីធានាមិនឲ្យមានឧក្រិដ្ឋកម្មប្រល័យពូជសាសន៍កើតឡើងម្តងទៀត ។

ទីពីរ មានការព្រួយបារម្ភថាតុលាការមិនមានពេលវេលាគ្រប់គ្រាន់ដើម្បីបញ្ចប់សវនាការ ។ ទាក់ទងនឹងបញ្ហាសុខភាពនៃជំងឺវង្វេងវង្វាន់របស់ អៀង ធីរិទ្ធ ដែលធ្វើឲ្យគាត់មិនអាចទទួលបានការកាត់ទោសគឺជាបញ្ហានៅសាលាក្តីខ្មែរក្រហម ។ ប្រសិនបើតុលាការមិនអាចពន្លឿនដំណើរការកាត់ទោសឲ្យលឿនទេ តុលាការប្រាកដជាប្រឈមនឹងបញ្ហាដែលថាជនត្រូវចោទផ្សេងទៀតប្រហែលជានឹងស្ថិតនៅក្នុងស្ថានភាពដែលតុលាការមិនអាចកាត់ទោសបាន ។ ប្រសិនបើសំណុំរឿង០០២ ត្រូវពន្យារពេលតទៅមុខទៀតប្រជាជនកម្ពុជាប្រហែលជាបាត់បង់ចំណង់ក្នុងការស្វែងរកយុត្តិធម៌ពីជនជាប់ចោទដែលប្រព្រឹត្តអំពើនេះនៅចន្លោះឆ្នាំ១៩៧៥ ដល់ ១៩៧៩ ។ នៅក្នុងចំណោមអ្នកភូមិ៣០នាក់ដែលផ្តល់បទសម្ភាសន៍អ្នកភូមិប្រាំនាក់បានលើកឡើងពីការព្រួយបារម្ភដែលថាដំណាក់កាលកាត់ទោសជាច្រើនដំណាក់របស់សាលាក្តីខ្មែរក្រហមនឹងរារាំងការកាត់ទោសជនត្រូវចោទ ។ អ្នកភូមិខ្លះបានសំណូមពរឲ្យការកាត់សេចក្តីបញ្ចប់ទៅពីមួយឆ្នាំ ទៅប្រាំឆ្នាំខាងមុខ ។ គង់ សាមិត ជាអ្នកដែលនៅរស់ពីអំពើប្រល័យពូជសាសន៍នៅខេត្តស្វាយរៀង និង សេង សុភ័ក្រ្ត ដែលជាសិស្សវិទ្យាល័យម្នាក់មកពីខេត្តកណ្តាល បានបង្ហាញពីការអស់សង្ឃឹមភាពមិនសប្បាយចិត្ត និងភាពសោកស្តាយ ប្រសិនបើជនដៃដល់ស្លាប់ ។ អ្នកទាំងពីរក៏ព្រួយបារម្ភថាជនរងគ្រោះគួរតែអាចមើលឬយ៉ាងហោចណាស់ស្តាប់សាលក្រមសេចក្តីសម្រេចលើជនត្រូវចោទមុនពេលស្លាប់ ពីព្រោះជនរងគ្រោះខ្លះក៏មានវ័យចំណាស់ដូចជាជនត្រូវចោទដែរ ។

ទីបី ការប្រឆាំងជាបន្តបន្ទាប់ និងការជំទាស់របស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការចោទប្រកាន់បន្ថែមទៅលើអតីតមន្ត្រីជាន់ខ្ពស់នៃរបបខ្មែរក្រហមលើសពីសំណុំរឿង០០២ ឧទាហរណ៍ សំណុំរឿង០០៣ និង០០៤ បណ្តាលឲ្យមានការជំទាស់មិនទទួលស្គាល់ចៅក្រម ឡូរ៉ង់ កាស្តេ អាសឺម៉េត ជនជាតិស៊ុីស ដែលតែងតាំងដោយអង្គការសហប្រជាជាតិឲ្យធ្វើជាសហចៅក្រមសើុបអង្កេត ។

បញ្ហានេះនៅតែជាឧបសគ្គរារាំងមិនឲ្យមានការសើុបអង្កេតបន្ថែមដូច្នេះវាបណ្តាលឲ្យមានការជំទាស់នឹងបំណងរបស់ប្រជាជនដែលចង់ឃើញជនត្រូវចោទទទួលការកាត់ទោសតាមវិធានច្បាប់ ។ ថ្មីៗនេះ រាជរដ្ឋាភិបាលកម្ពុជាបានទទួលស្គាល់ការតែងតាំងអតីតព្រះរាជអាជ្ញាជនជាតិអាមេរិកដែលធ្លាប់ធ្វើការសើុបអង្កេតនៅអតីតប្រទេសយូហ្គោស្លាវី នៅទីក្រុងឡាអេ ដើម្បីសើុបអង្កេតនៅក្នុងសំណុំរឿង០០៣ និង០០៤ ទៅតាមជំហររបស់ចៅក្រម ឡូរ៉ង់ ។ ប៉ុន្តែនៅតែមានពាក្យចចាមអារាមទាក់ទងនឹងគោលបំណងនៃការតែងតាំងនេះ ។

បញ្ហាទីបួន ទាក់ទងនឹងសមត្ថភាពរបស់បុគ្គលិកបម្រើការនៅសាលាក្តីខ្មែរក្រហម ។ កំហុសជារឿយៗទាក់ទងនឹងការបកប្រែជាបីភាសាគឺ ភាសាអង់គ្លេស បារាំង និងខ្មែរនៅពេលជំនុំជម្រះបានធ្វើឲ្យមានការពន្យារពេល ការយល់ខុសគ្នា និងការមិនពេញចិត្តជារឿយៗរវាងភាគីទាំងអស់ ។ អង្គជំនុំជម្រះបានណែនាំឲ្យអ្នកបកប្រែកបកប្រែពាក្យសម្តីទំនាក់ទំនងឲ្យត្រឹមត្រូវ និងណែនាំឲ្យភាគីទាំងអស់រៀបចំសំណួរនិងចម្លើយឲ្យសាមញ្ញនិងងាយ

ស្រួលយល់ ។ ទោះបីជាអង្គជំនុំជម្រះបានជួបប្រទះនឹងបញ្ហាដែលមិនអាចជៀសរួចនៅពេលគ្រប់គ្រងដំណើរការតុលាការជាបឋមក៏ដោយ ក៏អង្គជំនុំជម្រះក៏បានតែងតាំងបុគ្គលិកដែលមានសមត្ថភាពជាបន្តបន្ទាប់ដើម្បីជួយសម្រួលការងារតុលាការដែរ ។ ជាងនេះទៅទៀត ចៅក្រមកម្ពុជាដែលត្រូវបានតែងតាំងមិនត្រឹមតែមានបទពិសោធន៍តិចឬជំនាញតិចតួចក្នុងការដោះស្រាយបញ្ហានៅចំពោះមុខទេ ប៉ុន្តែថែមទាំងទទួលការចោទប្រកាន់ពីអំពើពុករលួយនិងស្នើឲ្យមានការស៊ើបអង្កេតទៅលើក្រមសីលធម៌របស់សហចៅក្រមស៊ើបអង្កេត ។

## លទ្ធផលដែលអាចកើតមានដោយសារតែឧបសគ្គទាំងនេះ

ប្រសិនសាលាក្តីខ្មែរក្រហមមិនអាចដោះស្រាយឧបសគ្គទាំងនេះដែលរារាំងដល់ «ដំណើរដ៏វែងឆ្ងាយទៅកាន់យុត្តិធម៌» ដូចជាឧបសគ្គនៃការស៊ើបអង្កេតបន្តនិងការស៊ើបអង្កេតដោយលម្អៀង និងឧបសគ្គនៃសំណុំរឿង០០៣ និង០០៤ទេ នោះជនដែលដៅផ្សេងទៀតដែលនៅមានអំណាចនិងស្ថិតនៅក្នុងនិទណ្ឌភាពនឹងមិនអាចទទួលខុសត្រូវចំពោះតួនាទីរបស់ខ្លួនចំពោះសង្គ្រាមទេ ដូច្នេះវានឹងអាចរារាំងដល់ភាពជឿជាក់និងសេចក្តីសង្ឃឹមរបស់ប្រជាជនកម្ពុជាដែលចង់មើលលទ្ធផលនៃការងារល្អរបស់សាលាក្តីខ្មែរក្រហម ។



ប៉ុន ណាក្រុន



គង់ សុដាណា

ឧបសគ្គរវាងរាជរដ្ឋាភិបាលកម្ពុជា និងសាលាក្តីខ្មែរក្រហម ធ្វើឲ្យប៉ះពាល់ដល់ផលប្រយោជន៍រួម ។ វាអាចបំផ្លាញដល់គោលបំណងរួមគឺការនាំយកអ្នកដែលត្រូវទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មដ៏សាហាវឃោរឃៅ ។ ការបរាជ័យនេះនឹងបង្កើតនូវភាពមិនទុកចិត្តនិងភាពមិនជឿជាក់លើប្រសិទ្ធភាពរបស់អង្គការសហប្រជាជាតិ ព្រមទាំងធ្វើឲ្យក្មេងៗកម្ពុជាដែលមានចំនួន៥០ភាគរយនៃប្រជាជនសរុបមានចម្ងល់ទៅលើវិធាននៃច្បាប់ដែលទើបតែបង្កើតឡើងនៅក្នុងប្រទេស ។ ការទុកចិត្តដែលគេស្មានមិនដល់នឹងបង្អាក់ដល់ភាពរីកចម្រើន និងការអភិវឌ្ឍន៍ប្រទេសនៅក្នុងរយៈពេលខ្លី និងរយៈពេលវែង ពីព្រោះប្រជាជននឹងបាត់បង់ភាពស្មោះត្រង់ចំពោះរដ្ឋាភិបាល និងប្រព័ន្ធយុត្តិធម៌ ។

នៅពេលសួរសំណួរអំពីការទុកចិត្តទៅលើសាលាក្តីខ្មែរក្រហមក្នុងការផ្តល់យុត្តិធម៌ អ្នកភូមិ១០នាក់ក្នុងចំណោមអ្នកភូមិ១៣នាក់បានបង្ហាញពីការទុកចិត្តទៅលើតុលាការក្នុងការផ្តល់យុត្តិធម៌ដល់ប្រជាជន ។ ខណៈពេលដែលអ្នកផ្តល់បទសម្ភាសន៍ដែលមានវ័យកណ្តាលជឿថា ការប្រើប្រាស់ច្បាប់ក្នុងស្រុក និងច្បាប់អន្តរជាតិរួមគ្នានិងបុគ្គលិកនឹងធ្វើឲ្យមានការកាត់ទោសមិនលម្អៀងនៅតុលាការ ។ អ្នកផ្តល់បទសម្ភាសន៍វ័យក្មេងដូចជា ប៉ុន ណាក្រុន និង គង់ សុដាណា ជឿជាក់ទៅលើដំណើរការនីតិវិធីរបស់តុលាការនិងវិធាននៃច្បាប់សម្រាប់កាត់ទោស ។ ទោះបីជាតុលាការសម្រេចដោះលែងជនត្រូវចោទណាម្នាក់ឬទាំងអស់ក៏ដោយ ក៏អ្នកទាំងពីរនៅតែ «ទុកចិត្ត» និង «ជឿជាក់» ទៅលើសេចក្តីសម្រេចរបស់ចៅក្រមដែរ ។ គេជឿជាក់ថា តុលាការធ្វើការបានហ្មត់ចត់និងព្យាយាមអស់ពីសមត្ថភាពដើម្បីផ្តល់យុត្តិធម៌ដល់ប្រជាជន ។

## តើដំណើរការនីតិវិធីរបស់សាលាក្តីខ្មែរក្រហមមានតម្លៃដែរឬទេ?

ទោះបីជាមានបញ្ហាដែលមិនចេះចប់ចេះហើយ និងការចោទប្រកាន់ទៅលើសាលាក្តីខ្មែរក្រហមលោក ចាស៊ីស ហ្គោស្តូនមានយោបល់ផ្សេងខុសពីអ្នកដទៃ ។ លោក ហ្គោលស្តូនយល់ ថា

ការជំរុញឲ្យមានការផ្សះផ្សាជាតិរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី និងតុលាការអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដា គឺមិនមែនត្រឹមតែជាសេចក្តីសម្រេច និងការផ្តន្ទាទោសនៅពេលចុងបញ្ចប់នៃដំណើរការនីតិវិធីប៉ុណ្ណោះទេ កិច្ចខំប្រឹងប្រែងរបស់តុលាការដើម្បីបញ្ចប់ការបដិសេធមិនទទួលខុសត្រូវរបស់ជនជាប់ចោទនៅពេលកាត់ទោស និងជំរុញឲ្យមានការរកឃើញការពិតនូវអ្វីដែលបានកើតឡើងក៏ជាផ្នែកមួយដែរ ។ ជំហរដ៏គួរឲ្យគោរពរបស់សាលាក្តីខ្មែរក្រហមនិងសវនាការកាត់ទោសគឺជាផ្នែកមួយនៃមេរៀនដ៏សំខាន់គឺវាបង្ហាញថាយុត្តិធម៌ "មិនត្រឹមតែបានសម្រេចរួចហើយទេ ប៉ុន្តែថែមទាំងមានការមើលឃើញយុត្តិធម៌នោះផងដែរ" ដូច្នេះវាអាចសម្រេចបាននូវគោលការណ៍យុត្តិធម៌ដែលបើកចំហរ ។ ការបញ្ចប់ដំណើរការនីតិវិធីលើសំណុំរឿង០០១នៅសាលាក្តីខ្មែរក្រហមដោយមានសម្ពាធនិងបញ្ហាជាច្រើនបានធ្វើឲ្យដំណើរការនីតិវិធីដំណើរការទៅយឺតនិងបាត់បង់ប្រសិទ្ធភាពនៃដំណើរការនីតិវិធីលើសំណុំរឿង០០២ ដូច្នេះ វាអាចបណ្តាលឲ្យមានជំពូកបរាជ័យមួយទៀតនៅក្នុងការស្វែងរកយុត្តិធម៌ ការអភិវឌ្ឍន៍និងដំណើរការវិវឌ្ឍន៍នៅក្នុងប្រទេសកម្ពុជា ។

## តើមានអ្វីកើតឡើងនៅពេលនេះ?

ដោយមានច្បាប់នៅក្នុងសង្គមយើងបានសុំឲ្យអ្នកផ្តល់បទសម្ភាសន៍ផ្តល់នូវសំណូមពរ និងយោបល់ទៅលើមធ្យោបាយដើម្បីដើរនៅលើផ្លូវដ៏វែងឆ្ងាយឆ្ពោះទៅកាន់យុត្តិធម៌ និងចៀសផុតពីចំណុចគ្រលុកនៅលើផ្លូវនោះ ។

យោងទៅតាម សេង សុភ័ក្រ្ត ក្មេងជំនាន់ក្រោយគួរតែសិក្សាអំពីប្រវត្តិសាស្រ្តជាតិ និងស្រឡាញ់សង្គមរបស់ខ្លួន ដូច្នេះទើបមិនអាចដឹកនាំខុស ឬមានការភាន់ច្រឡំចំពោះប្រវត្តិសាស្រ្តជាតិ ដើម្បីចៀសវាងមិនឲ្យមានប្រវត្តិសាស្រ្តដែលកើតឡើង ។ ប៉ុន ណាក្រុន បានបន្ថែមយោបល់របស់ខ្លួនថាការធ្វើការជាក្រុមនិងលទ្ធភាពដោះស្រាយការយល់ឃើញខុសគ្នា និងជម្លោះគឺជាគន្លឹះសម្រាប់បញ្ចៀសនូវជម្លោះ និងសង្គ្រាមដែលអាចកើតមាននៅអនាគត និងស្រដៀងនឹងអ្វីដែលបានកើតឡើងនៅក្នុងរបបខ្មែរក្រហម ឆ្នាំ១៩៧៥-១៩៧៩ ។

សិស្សប៉ូលិស នី ផល្លា, គង់ គន្ធី, គង់ សុផាណា និង ស៊ាវ ងីឈ័ន មកពីភ្នំពេញ បានសង្កត់ធ្ងន់ពីសារសំខាន់នៃការបង្រៀនក្មេងជំនាន់ក្រោយឲ្យមានឆន្ទៈការពារជាតិមិនប្រព្រឹត្តបទល្មើសនិងមិនជំរុញអ្នកដទៃធ្វើអំពើបែបនោះ ។ អ្នកផ្តល់បទសម្ភាសន៍ទាំងនេះក៏ជំរុញឲ្យមានការលើកឡើងជាសំណួរដើម្បីបង្កើនការយល់ដឹងរបស់ប្រជាជនទៅលើរបបកម្ពុជាប្រជាធិបតេយ្យដើម្បីទប់ស្កាត់ និងមានការសិក្សាពីអំពើប្រល័យពូជសាសន៍ ។ ជាក់ស្តែង ងីឈ័ន បានលើកឡើងពីសារសំខាន់នៃការសិក្សានៃការកើនឡើងនិងធ្លាក់ចុះនៃបក្សកុម្មុយនីស្តកម្ពុជា ព្រមទាំងមូលហេតុនៃការបង្កើតសង្រ្គាមដែលអាចធ្វើឲ្យប្រទេសជាតិទាំងមូលអាចទប់ស្កាត់ព្រឹត្តិការណ៍បែបនេះមិនឲ្យកើតមានឡើងម្តងទៀត និងមិនឲ្យមានលទ្ធផលដ៏អាក្រក់បែបនេះ ។


ស៊ាវ ងីឈ័ន

នៅទីបញ្ចប់ សា អិន មកពីខេត្តតាកែវជឿជាក់យ៉ាងមុតមាំទៅលើសារសំខាន់នៃការសិក្សា ។ គាត់បានសង្កត់ធ្ងន់ថា មិនត្រឹមតែសាលាក្តីខ្មែរក្រហមទេដែលមានសារសំខាន់សម្រាប់កាត់ទោសជនដៃដល់ចំពោះឧក្រិដ្ឋកម្មដែលអ្នកទាំងនោះបានប្រព្រឹត្ត ប៉ុន្តែការអប់រំក្មេងជំនាន់ក្រោយអំពីគោលបំណងវិធានច្បាប់និងដំណើរការនីតិវិធីរបស់តុលាការក៏មានសារសំខាន់ស្មើគ្នាដែរ ។ ការធ្វើបែបនេះគឺជាការផ្តល់តួនាទីដល់ក្មេងជំនាន់ក្រោយឲ្យចេះការពារប្រទេសមិនឲ្យមានអំពើហិង្សានិងជំរុញឲ្យមានការគោរពសិទ្ធិមនុស្សរវាងគ្នាទៅវិញទៅមក ។ គាត់ក៏សង្ឃឹមថា ក្មេងដែលកើតក្រោយរបបប្រល័យពូជសាសន៍នឹងអាចសិក្សាពីបទពិសោធន៍របស់មនុស្សចាស់ដើម្បីកសាងប្រទេសកម្ពុជាឲ្យល្អជាងមុន ។

វាហាក់ដូចជាថាតុលាការតែមួយមិនអាចដោះស្រាយនូវ

តម្រូវការចង់បានយុត្តិធម៌របស់ប្រជាជនទេ ។ មធ្យោបាយតែមួយដែលប្រហែលជាអាចឲ្យប្រជាជនកម្ពុជាអាចមានអារម្មណ៍


សា អិន

ពេញចិត្តនិងអស់ចិត្តពីសេចក្តីឈឺចាប់របស់ខ្លួនជួបប្រទះគឺការយកឈ្នះទៅលើអតីតកាលដោយការអភ័យទោស និងអប់រំក្មេងជំនាន់ក្រោយអំពីមេរៀននៃការ "អភ័យទោស" ។ ការបង្កើតសារមន្ទីរគឺជាទស្សនះសមរម្យមួយសម្រាប់ក្មេងនិងមនុស្សចាស់ គឺយើងអាចសាងសង់ស្តូប និងសួនច្បារ, កន្លែងអភិរក្សនៅតាមវាលពិឃាដ ប្រារព្ធពិធីរំឭកដល់ភូមិខេត្ត និងប្រទេសនៅថ្ងៃសំខាន់ណាមួយ ហើយអ្វីដែលសំខាន់សម្រាប់បង្រួបបង្រួមគឺជាគំនិតល្អ ដែលយើងគួរតែជំរុញឲ្យមាន ។ សង្គមស៊ីវិលត្រូវតែអភិរក្សអ្វីដែលមានសរសេរប្រវត្តិសាស្ត្រខ្លួនឯង និងចងក្រងនៅក្នុងវប្បធម៌សម័យទំនើប ។ ការធ្វើបែបនេះអាចរក្សាអាចជាការផ្សះផ្សាជាតិបានយូរអង្វែងជាងសាលាក្តីខ្មែរក្រហម ។ ខ្ញុំមានមោទកភាពដែលបានធ្វើការងារជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជារយៈពេលខ្លី ។ មជ្ឈមណ្ឌលឯកសារកម្ពុជាមានគោលបំណងឆ្លុះបញ្ចាំងការចងចាំ និងផ្សះផ្សា ។ **អេនរេច្ឆ អ៊ិច**

## អានទស្សនាវដ្តីតាមគេហទំព័រ

ទស្សនាវដ្តីស្វែងរកការពិតទាំងអស់ត្រូវបានផ្សព្វផ្សាយតាមគេហទំព័ររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ។ អ្នកអានអាចរកបានតាមៈ http://dccam.org/Projects/Magazines/Magazine_Searching.htm ។ ព័ត៌មានបន្ថែម សូមទាក់ទង ញាណ សុជាតិ ទូរស័ព្ទលេខ ០១៦ ៨៧៦ ៦៩២ ឬ ០២៣ ២១១ ៨៧៥ ។

**សូមអរគុណ!**


ក្រុមគម្រោងឃ្លាំមើលតុលាការខ្មែរក្រហម ថតរូបជាមួយនិស្សិតសាកលវិទ្យាល័យកម្ពុជា

# ថ្នាក់រៀននៅទួលស្លែង

*មជ្ឈមណ្ឌលឯកសារកម្ពុជាបានបង្កើតថ្នាក់រៀនសាធារណៈមួយនៅសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង ។ ថ្នាក់រៀននេះត្រូវបានបង្កើតឡើងក្នុងខែវិច្ឆិកា ឆ្នាំ២០១១ ដោយមានកិច្ចសហការវាងមជ្ឈមណ្ឌលឯកសារកម្ពុជា និងក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ។ សារមន្ទីរទួលស្លែងគឺជាអតីតសាលារៀនដ៏ទំនើបមួយដែលបានសង់ឡើងជាលើកដំបូងនៅក្នុងឆ្នាំ១៩៦២ ។ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ខ្មែរក្រហមបានប្រែក្លាយសាលារៀននេះទៅជាគុកដ៏សម្ងាត់បំផុតមួយក្នុងចំណោមគុកចំនួន១៩៦ទូទាំងប្រទេស ។ អ្នកទោសភាគច្រើនដែលត្រូវបញ្ជូនទៅទួលស្លែងគឺជាកម្មាភិបាលខ្មែរក្រហមដែលត្រូវបានចោទប្រកាន់ពីបទប្រព្រឹត្តអំពើក្បត់ជាតិដូចជា ការសហការជាមួយរដ្ឋាភិបាលបរទេស ឬធ្វើជាអ្នកស៊ើបការណ៍ឲ្យសេ.អ៊ី.អា ឬ កា.ហ្សេ.បេ ជាដើម ។*

*អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា នៅក្នុងសាលក្រមកាត់សេចក្តីអតីតប្រធានគុកទួលស្លែងឈ្មោះ កាំង ហ្កេកអ៊ាវ ហៅឌុច បានកំណត់ថា យ៉ាងហោចណាស់មានអ្នកទោសចំនួនប្រហែល១២២៧៣នាក់ បានជាប់ឃុំនៅគុកទួលស្លែង ។ អ្នកសារព័ត៌មានបស្ចិមប្រទេសភាគច្រើនបានប្រើប្រាស់តួលេខប្រាំពីរនាក់សម្រាប់អ្នកដែលបានរួចរស់ជីវិតពីមន្ទីរនេះ ហើយតួលេខនេះត្រូវបានប្រើប្រាស់ម្តងហើយម្តងទៀត អស់ជាងសាមសិបឆ្នាំមកហើយ ។ ទោះជាយ៉ាងនេះក្តី បន្ទាប់ពីបានធ្វើការស្រាវជ្រាវអស់រយៈពេលជាច្រើនឆ្នាំមក មជ្ឈមណ្ឌលឯកសារកម្ពុជាបានរកឃើញថា មានអ្នកទោសយ៉ាងតិច១៧៩នាក់ត្រូវបានដោះលែងពីគុកទួលស្លែងពីឆ្នាំ១៩៧៥ដល់ឆ្នាំ១៩៧៨ហើយមានអ្នកទោសប្រមាណជា២៣នាក់បន្ថែមទៀតបានរស់រានមានជីវិតនៅពេលវៀតណាមផ្តួលរំលំរបបខ្មែរក្រហមនៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ។ ព័ត៌មានបន្ថែមសូមអានទស្សនាវដ្តីស្វែងរកការពិតលេខ ១៣៤ ។*

*ចាប់តាំងពីការប្រែក្លាយពីកន្លែងរៀនសូត្រមួយទៅជាកន្លែងដ៏គួរឲ្យរន្ធត់ និងមហន្តរាយមួយ ទួលស្លែងមិនដែលទទួលបានមុខងាររបស់ខ្លួនដូចកាលពីដើមវិញឡើយ ។ ទោះជាយ៉ាងនេះក្តី នៅពេលអនាគត ដើម្បីទាមទារមកវិញនូវកេរដំណែលអប់រំដែលមានលក្ខណៈវិជ្ជមានរបស់ទួលស្លែង និងដើម្បីបន្ថែមសមាសភាពអប់រំមួយទៅក្នុងសារមន្ទីរនេះ ថ្នាក់រៀននេះត្រូវបានបង្កើតឡើងដើម្បីផ្តល់ការបង្រៀន និងការពិភាក្សាដោយឥតគិតថ្លៃអំពីប្រវត្តិសាស្ត្ររបបខ្មែរក្រហម និងប្រធានបទដែលជាប់ទាក់ទងដូចជា អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ ថ្នាក់រៀននេះក៏ជាវេទិកាសាធារណៈមួយសម្រាប់ឲ្យអ្នកមកទស្សនា និងអ្នកដែលនៅរស់រានមានជីវិតចែករំលែកព័ត៌មានគ្នាក្នុងការថែរក្សារយៈកាលនៃប្រវត្តិសាស្ត្រកម្ពុជាដ៏មានសារសំខាន់មួយទុកឲ្យអ្នកជំនាន់ក្រោយបានរៀនសូត្រ ។*

*បុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជា និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង ដែលមានសញ្ញាបត្រមកពីបរទេស និងបានទទួលវិញ្ញាបនបត្រពីក្រសួងអប់រំ យុវជន និងកីឡា ផ្នែកការបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ(១៩៧៥-៧៩) ព្រមទាំងមានការចូលរួមពីអ្នកជំនាញជាតិនិងអន្តរជាតិដែលមានជំនាញលើប្រវត្តិសាស្ត្រប្រទេសកម្ពុជា និងអ្នកដែលនៅរស់រានមានជីវិតពីមន្ទីរស-២១នឹងបង្រៀននៅថ្នាក់រៀននេះ ។ សម្រាប់ព័ត៌មានទាក់ទងនិងថ្នាក់រៀននេះ សូមទាក់ទង ស៊ិរ សាវីណា តាមរយៈទូរសព្ទ័លេខ ០២៣ ២១១ ៨៧៥ ។*

- ***ទីកន្លែង : អាគារ “ក” ជាន់លើ***
- ***ពេលវេលា : ច័ន្ទ ២-៣រសៀល***
  ***ពុធ ៩-១០ព្រឹក***
  ***សុក្រ ២-៣រសៀល***

# លោកឪពុកខ្ញុំក្នុងរបបខ្មែរក្រហម

របបខ្មែរក្រហមបានឡើងកាន់អំណាចនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ បន្ទាប់ពីយកជ័យជម្នះលើកងទ័ពរបស់សេនាប្រមុខ លន់ នល់ ។ ប៉ុន្តែ របបដឹកនាំនោះបាន ធ្វើឲ្យប្រជាពលរដ្ឋខ្មែរដែលឆ្លងកាត់និងនៅរស់រានមានជីវិត នៅតែចងចាំមិនភ្លេចអំពីហេតុការណ៍ដែលកើតឡើងចំពោះរូបគាត់ក្នុងអំឡុងពេលបីឆ្នាំប្រាំបីខែ និងម្ភៃថ្ងៃ ដែលក្នុងនោះក៏មានឪពុក ខ្ញុំម្នាក់ដែរ ។

ឪពុកខ្ញុំឈ្មោះ សូត យុន កើតនៅឆ្នាំ១៩៤៥ ដែលមកដល់ពេលនេះគាត់មានអាយុ៦៧ឆ្នាំហើយ ។ សព្វថ្ងៃ ឪពុកខ្ញុំជាកសិករនៅភូមិព្រែកលីវ ឃុំរការអារ ស្រុកកងមាស ខេត្តកំពង់ចាម ។

ជារឿយៗ ឪពុកខ្ញុំបាននិយាយប្រាប់កូនៗ ពិសេសខ្ញុំដែលចង់ដឹងពុំអំពីហេតុការណ៍ដែលបានកើតឡើងក្នុងរបបខ្មែរក្រហម ។ គាត់បានរៀបរាប់ថា នៅមុនរបបខ្មែរក្រហមគ្រួសាររបស់ខ្ញុំមានជីវភាពសាមញ្ញដូចប្រជាជននៅក្នុងភូមិដែរ ។ នៅពេលឪពុកខ្ញុំមានអាយុ១៨ឆ្នាំ គាត់បួសជាសាមណេរ ។ ឪពុកខ្ញុំបួសបានរយៈពេល ១០វស្សា គាត់ក៏សឹកមកជាគ្រហស្ថនៅឆ្នាំ១៩៧០ ។


ឪពុកម្តាយរបស់ សុខហេង ថតនៅឆ្នាំ១៩៨៧

ក្រោយមក ឪពុករបស់ខ្ញុំបានរៀបការជាមួយម្តាយខ្ញុំឈ្មោះ ផាត់ នាង ។ នៅមុន ឆ្នាំ១៩៧៥ ឪពុកម្តាយរបស់ខ្ញុំមានកូនពីរនាក់ ប៉ុន្តែពេលនោះកូនប្រុសទីមួយឈ្មោះ សូត វុទ្ធី ដែលមានអាយុប្រមាណដប់ឆ្នាំបានស្លាប់ដោយសារកើតជំងឺកញ្ច្រិល នៅតែបងស្រីទីពីរ សូត ឃីម ដែលសព្វថ្ងៃមានអាយុ៤០ឆ្នាំ ។

នៅមុនរបបខ្មែរក្រហមទទួលជ័យជម្នះ ឪពុករបស់ខ្ញុំជាមេក្រុម ដែលពេលនោះគាត់ត្រូវទទួលការងារបន្តពីមេភូមិមកធ្វើដូចជា ដើរប្រាប់សមាជិកក្នុងក្រុមឲ្យទៅចូលរួមប្រជុំនៅក្នុងភូមិ ឬឲ្យទៅធ្វើការងារផ្សេងៗ ។

ពេលដែលខ្មែរក្រហមចូលមកដល់ភូមិ នៅខែមេសា ដំណែងរបស់ឪពុកខ្ញុំមិនបានផ្លាស់ប្តូរទេ ដោយសារគាត់មានទីលំនៅក្នុងភូមិអចិន្ត្រៃយ៍ ឬជាប្រជាជនមូលដ្ឋាន ។ ហេតុដូច្នេះហើយបានជាខ្មែរក្រហមមិនជម្លៀសគ្រួសារខ្ញុំទៅកន្លែងផ្សេង ។ ពេលនោះ ដោយសារតែភាពស្លូតត្រង់របស់ឪពុកខ្ញុំទើបគាត់នៅកាន់ដំណែងដដែល ប៉ុន្តែគាត់មិនមានសិទ្ធិសម្រេចធំដុំទេ ។

ចាប់តាំងពីខ្មែរក្រហមចូលកាន់អំណាចភ្លាម ការរស់នៅមានការប្រែប្រួលយ៉ាងខ្លាំងឪពុកខ្ញុំមិន

ដែលបានហូបឆ្អែត ឬឆ្ងាញ់ម្តងណាឡើយ ហើយគាត់ត្រូវរស់នៅបែកពីគ្រួសារ ប៉ុន្តែដោយគាត់ជាប្រជាជនចាស់ ទើបអង្គការអនុញ្ញាតឲ្យមកជួបប្រពន្ធកូន ។

នៅសម័យនោះ អង្គការបានចាត់ឪពុកខ្ញុំឲ្យធ្វើការងារច្រូតស្រូវ ហើយប្រសិនជាខែភ្ជួ គាត់ត្រូវដាន់រហាត់ទឹកចាប់ពីម៉ោង៦ល្ងាច រហូតជិតភ្លឺតែម្តងទើបឈប់ ។ ពេលនោះ ដោយសារភូមិខ្ញុំមានទំហំធំ ទើបអង្គការបង្កើតរោងបាយដប់កន្លែង ដែលក្នុងចំណោមនោះមានរោងបាយខ្លះមានរបបអាហារប្រសើរជាងឪពុកខ្ញុំ ។ នៅពេលប្រជុំម្តងប្រធានកងនោះតែងតែលើកឡើងពី "សមូហភាព" និង "ភាពស្មើគ្នា" ប៉ុន្តែដោយសារអត់ទ្រាំពុំបាន ឪពុកខ្ញុំក៏ឡើងមានយោបល់ថា "បើនិយាយទៅសមូហភាពប្រសើរណាស់ ។ ប៉ុន្តែ ប្រសិនបើនិយាយពាក្យនេះ ទាល់តែគ្រប់តំបន់ ឬគ្រប់កន្លែងទាំងអស់មានការហូបចុកស្មើគ្នា ធ្វើការស្មើគ្នា មិនមែនដូចកន្លែងខ្ញុំរស់នៅហូបមិនគ្រប់គ្រាន់ តែកន្លែងខ្លះបានហូបគ្រប់គ្រាន់នោះទេ" ។ បន្ទាប់ពីឪពុកខ្ញុំនិយាយចប់ភ្លាម ប្រធានកងបានជ្រើសរើសគាត់យកទៅកសាង ប៉ុន្តែដោយសារបងប្អូនជីទូតមួយរបស់គាត់អង្វរប្រធានកងនោះ ទើបឪពុករបស់ខ្ញុំបានរួចខ្លួន ។

ដោយឡែក នៅពេលនោះ អង្គការបានចាត់តាំងបងស្រីខ្ញុំទៅលើកទំនប់ថ្មី ស្ថិតនៅឃុំស្ដេន ស្រុកកងមាស ខេត្តកំពង់ចាម ។ បងស្រីខ្ញុំត្រូវធ្វើការងារធ្ងន់ធ្ងរ ហើយពេលខ្លះគាត់ត្រូវធ្វើការងាររយៈពេលបីយប់បីថ្ងៃជាប់គ្នា ។ ប្រជាជនមួយចំនួនបានស្លាប់ដោយសារបាក់កម្លាំង និងគ្មានថ្នាំពេទ្យព្យាបាល ហើយអ្នកមួយចំនួនទៀតទទួលរងប៉ះពាល់រហូតមកដល់សព្វថ្ងៃនេះ ។

នៅពេលនោះ គ្រប់សកម្មភាពទាំងអស់របស់ប្រជាជន ដូចជា រអ៊ូនៅពេលធ្វើការងារ ត្រូវកងឈ្លបរាយការណ៍ទៅថ្នាក់លើ ។ ចំណែកអ្នកដែលឈឺ កងឈ្លបបានយកទៅព្យាបាលនៅមន្ទីរពេទ្យ គឺយកទៅសម្លាប់ចោលតែម្តង ព្រោះមិនដែលឃើញអ្នកជំងឺនោះត្រឡប់មកភូមិវិញទេ ។

រហូតមកដល់ពេលនោះ នៅក្នុងភូមិរបស់ខ្ញុំមានទំនប់មួយឈ្មោះ ទំនប់កុមារ ដែលមានប្រវែងពីរគីឡូម៉ែត្រ កសាងឡើងដោយកុមារក្រោម១៨ឆ្នាំ ដែលបន្សល់ពីរបបខ្មែរក្រហម ។

ក្រោយរបបខ្មែរក្រហមដួលរលំ ឪពុកម្តាយរបស់ខ្ញុំរស់នៅភូមិឃុំដដែលនិងមានកូនប្រាំពីរនាក់(ស្រីបីនិងប្រុសបួននាក់) ។ ខ្ញុំជាកូនទីពក្នុងគ្រួសារ ហើយសព្វថ្ងៃខ្ញុំរៀននៅសកលវិទ្យាល័យភូមិន្ទភ្នំពេញ ផ្នែកប្រវត្តិវិទ្យា ឆ្នាំទី៣ ។

**សូត សុខហេង**



ពិធីរៀបការរបស់បងប្រុស សុខហេង ថតនៅឆ្នាំ១៩៩២

# ស្វែងរកឪពុករស់ជិត៤០ឆ្នាំ

លោក ជួន រក្សា បានតាមរកដំណឹងឪពុកឈ្មោះ ជួន ហេង អស់រយៈពេលជិត៤០ឆ្នាំ ។ ជួន ហេង ដែលជាវេជ្ជបណ្ឌិតមួយរូប និងមានតំណែងជាប្រធានមន្ទីរពេទ្យខេត្តតាកែវរហូតដល់ដង្ហើមចុងក្រោយនៃរបបលន់ នល់ ត្រូវបានអ្នកជងទាំងពួងដែលរស់នៅខេត្តតាកែវ និងអ្នកដែលមានអាជីពជាពេទ្យដូចគ្នាស្គាល់ជាទូទៅកាលពីជំនាន់នោះ ។ វេជ្ជបណ្ឌិត ជួន ហេង ត្រូវបានស្មើដោយកម្មាភិបាលខ្មែរក្រហមទៅរៀនសូត្រកាលពីដើមឆ្នាំ១៩៧៦ ហើយគាត់បានបាត់ខ្លួនជារៀងរហូតតាំងពីពេលនោះមក ដែលកាលនោះ រក្សា គឺជាក្មេងប្រុសម្នាក់ ដែលមានអាយុត្រឹមប្រាំបីឆ្នាំនៅឡើយ ។ បច្ចុប្បន្ននេះ រាល់ពេលដែល រក្សា ចុះទៅបំពេញការងារនៅខេត្តតាកែវម្តងៗ គាត់មិនដែលភ្លេចចូលទៅលេងមន្ទីរពេទ្យខេត្ត ជាកន្លែងដែលគាត់និងឪពុករបស់គាត់ធ្លាប់រស់នៅជាមួយគ្នាទេ ។ ថ្មីៗនេះ ស្ថានភាពជំងឺរបស់ អៀង សារី ដែលកាន់តែធ្ងន់ធ្ងរជាងមុនបានជំរុញឲ្យ រក្សា ខិតខំស្វែងរកឪពុករបស់ខ្លួនកាន់តែមានសន្ទុះខ្លាំងជាងមុន ។ ពេលនោះ រក្សា បានធ្វើដំណើរទៅខេត្តតាកែវ និងបានដើរជុំវិញបរិវេណមន្ទីរពេទ្យ ជាកន្លែងដែលគាត់ធ្លាប់រត់លេងកាលពីក្មេង ទឹកភ្នែករបស់គាត់ចាប់ផ្តើមហូរស្រក់ដោយមិនដឹងខ្លួនទាំងអារម្មណ៍រំជួលចិត្តដោយគិតថាគាត់មិនមានឱកាសជួបជុំឪពុករបស់គាត់ទៀតទេ ។ រក្សា មានគំនិតមួយក្នុងចិត្តថា "ពុក! កូនមានកំហុសមួយព្រោះកូនមិនអាចស្វែងរកទីកន្លែងដែលលោកពុកស្លាប់បាន" ។

រក្សា បានទន្ទឹងរងចាំ និងខំស្វែងរកឪពុករបស់គាត់តាំងពីថ្ងៃដែលឪពុករបស់គាត់ចាកចេញពីផ្ទះមកម្ល៉េះ ។ ក្រោយពីឪពុករបស់គាត់ចេញពីផ្ទះបានពីរបីថ្ងៃ រក្សា បានសួរម្តាយពីដំណឹងឪពុកជានិច្ច ព្រោះគាត់ធ្លាប់តែនៅជាមួយឪពុកមិនដែលបែកឡើយ ។ ជាមួយគ្នានោះដែរ រក្សា ក៏សាកសួរអ្នកជិតខាងពីដំណឹងរបស់ឪពុកគាត់ដែរ ។ ប៉ុន្តែចម្លើយដែលទទួលបាននៅតែមានភាពច្របូកច្របល់និងពិបាកយល់ ។ អ្នកខ្លះបានប្រាប់គាត់ថា ឪពុករបស់គាត់នឹងត្រឡប់មកផ្ទះវិញទៅថ្ងៃស្អែក ឬថ្ងៃខានស្អែក ។ អ្នកខ្លះទៀតប្រាប់គាត់ថា ឪពុករបស់គាត់ត្រូវបានសម្លាប់ទៅភ្នំជញ្ជាំង ក្នុងស្រុកព្រះនេត្រព្រះ អ្នកខ្លះទៀតនិយាយថា ឪពុករបស់គាត់ត្រូវបានខ្មែរក្រហមដឹកតាមរថយន្តឆ្ពោះទៅសេរីសោភ័ណ ចំណែកអ្នកខ្លះទៀតនិយាយថា ឪពុករបស់គាត់ត្រូវបានយកទៅកន្លែងផ្សេងទៀតក្រៅពីស្រុកសេរីសោភ័ណ ។ ចម្លើយផ្សេងគ្នាបែបនេះធ្វើឲ្យ រក្សា មានការលំបាកក្នុងការសម្រេចថា ឪពុករបស់ខ្លួននៅទីណា ។ ទោះជាយ៉ាងនេះក្តី រក្សា មិនដែលបាក់ទឹកចិត្តក្នុងការស្វែងរកឪពុកទេ ។

ការស្វែងរកសមាជិកគ្រួសារ ដែលបានបាត់ខ្លួននិងស្លាប់នៅតែជារឿងដ៏ចាំបាច់មួយនៅក្នុងសង្គមខ្មែរនាពេលបច្ចុប្បន្ន ទោះបីជារបបខ្មែរក្រហមបានដួលរំលំជាងសាមសិបឆ្នាំហើយក៏ដោយ ។ ខណៈពេលដែលគ្រួសារកម្ពុជានីមួយៗបាត់បង់សាច់ញាតិយ៉ាងហោចណាស់ម្នាក់ក្នុងរបបខ្មែរក្រហម សាច់ញាតិដែលនៅរស់បានបន្តរងចាំសាច់ញាតិដែលបានបាត់ខ្លួនត្រឡប់មកផ្ទះវិញ ទោះបីជាអ្នកដែលនៅរស់មិនដឹងទាល់តែសោះថា សាច់ញាតិដែលបានបាត់ខ្លួននោះត្រូវបានបញ្ជូនទៅទីណា ។ ពេលខ្លះ អ្នកដែលនៅរស់ដឹងថាសមាជិករបស់ខ្លួនត្រូវបានបញ្ជូនទៅកន្លែងណាមួយដែលខ្លួនស្គាល់ និងត្រូវបានខ្មែរក្រហមសម្លាប់នៅទីនោះ តែសាច់ញាតិមិនអាចរកឃើញអដ្ឋិធាតុរបស់បងប្អូនរបស់ខ្លួនទេ ។

រក្សា មានរូបភាពរបស់ឪពុកដក់ជាប់ក្នុងចិត្តជានិច្ច ដែលជាហេតុធ្វើឲ្យគាត់មានសេចក្តីក្លាហាន និងមិនដែលបោះបង់ការព្យាយាមក្នុងការស្វែងរកឪពុកម្តងណាឡើយ ។ រក្សា មានអារម្មណ៍ថា គាត់រស់នៅជាមួយឪពុករាល់ថ្ងៃ ។ ដោយសារតែគាត់មានរូបថតរបស់ឪពុកគាត់ក្នុងឯកសណ្ឋានជានិស្សិត ហើយព្យួរនៅលើជញ្ជាំងក្នុងផ្ទះរាល់ថ្ងៃ រក្សា មានការចងចាំនូវមុខមាត់ និងសកម្មភាពរបស់ឪពុកជានិច្ច ។

នៅពេលដែលឪពុករបស់គាត់ធ្វើការនៅមន្ទីរពេទ្យតាកែវ រក្សា ហើយនិងឪពុករស់នៅក្នុងផ្ទះមួយនៅក្នុងបរិវេណមន្ទីរពេទ្យ ដែលផ្តល់ជូនដោយរដ្ឋាភិបាល ។ រក្សា ត្រូវបានឪពុកនាំទៅលេង ទីនោះជាញឹកញាប់ និងបានធ្វើដំណើរជាប្រចាំរវាងខេត្តតាកែវ និង ទីក្រុងភ្នំពេញ ។ សព្វថ្ងៃ ផ្ទះនោះនៅមានវត្តមានដដែល តែត្រូវ បានប្រើប្រាស់ជាឃ្លាំងផ្ទុកឥវ៉ាន់របស់មន្ទីរពេទ្យ ។ រក្សា នៅតែ តាំងចិត្តថា នឹងស្វែងរកឪពុកឲ្យទាល់តែឃើញនៅថ្ងៃណាមួយ ។

ទីបំផុត រក្សា បានរកឃើញប្រវត្តិរូប និងរូបថតរបស់ឪពុក ដែលត្រូវបានបញ្ជូនទៅមន្ទីរស-២១ ដែល រក្សា មិនដែលស្មានដល់ ទាល់តែសោះថា ឪពុករបស់ខ្លួនត្រូវបានបញ្ជូនទៅទីនោះ ។ ប្រវត្តិ រូបនោះបានបង្ហាញថា ឪពុករបស់គាត់ឈ្មោះ ដួន ហេង ត្រូវបាន ចាប់ខ្លួននៅថ្ងៃទី១០ ខែមករា ឆ្នាំ១៩៧៦ នៅឃុំជប់ ស្រុក ព្រះនេត្រព្រះ ពេលដែលគាត់មានអាយុ៣៧ឆ្នាំ ។ ក្រោយពីរក ឃើញប្រវត្តិរូប និងរូបថតនោះ រក្សា បាននិយាយដោយអារម្មណ៍ រំជួលចិត្តថា «នេះគឺជាថ្ងៃដែលខ្ញុំសប្បាយរីករាយបំផុតនៅក្នុង ជីវិតរបស់ខ្ញុំ ។ គ្មានថ្ងៃណាដែលខ្ញុំសប្បាយរីករាយជាងថ្ងៃដែលខ្ញុំ រកឃើញឪពុកខ្ញុំទេ ។ ខ្ញុំមានអារម្មណ៍ហាក់បីដូចជារកឃើញឪពុក របស់ខ្ញុំនៅរស់ដូច្នោះដែរ» ។

ការរកឃើញរូបថតឪពុករបស់ រក្សា កើតឡើងត្រឹមតែ ប៉ុន្មានថ្ងៃប៉ុណ្ណោះ ក្រោយពីរូបថតពណ៌សខ្មៅចំនួន១.៤២៧សន្លឹក ត្រូវបានផ្តល់ជូនមកមជ្ឈមណ្ឌលឯកសារកម្ពុជា ដោយស្ត្រីម្នាក់ ដែលជាអតីតមន្ត្រីរដ្ឋាភិបាលកាលពីទសវត្សរ៍៨០ ។ ដូចគ្នាទៅនឹង អ្វីដែល រក្សា រកឃើញឪពុករបស់គាត់ដែរ រូបថតទាំង១.៤២៧សន្លឹក នោះនឹងផ្តល់ជាពន្លឺដល់អ្នកផ្សេងទៀតដែលកំពុងតែស្វែងរកសាច់ ញាតិរបស់ខ្លួនដែលបានបាត់ខ្លួនកាលពីជំនាន់ខ្មែរក្រហម ។ រូបថត ដែលទើបតែរកឃើញនេះនឹងជួយអ្នករួចរស់ជីវិតក្នុងការស្វែងរក សាច់ញាតិរបស់ខ្លួន ។

រូបថតស្ទើរតែទាំងអស់សុទ្ធតែមានឈ្មោះសរសេរនៅពី ក្រោយខ្នង រូបថតចំនួន៦៣សន្លឹកមិនត្រូវបានស្គាល់អត្តសញ្ញាណទេ និងរូបពីរសន្លឹកទៀតគឺជារូបជនបរទេសស្បែកស ។ ខណៈពេលដែល អ្នករួចរស់ជីវិតកំពុងស្វែងរកសាច់ញាតិរបស់ខ្លួនដែលបានបាត់ខ្លួន រូបថតទាំងអស់នេះនឹងត្រួសត្រាយផ្លូវដល់អ្នកស្វែងរកសាច់ញាតិ ដែលបានបាត់ខ្លួនអស់រយៈពេលជាច្រើនឆ្នាំមកហើយ ។ លោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជាបាននិយាយទាក់ទង ទៅនឹងរូបថតដែលរកឃើញនោះថា «រូបថតនីមួយៗយ៉ាងហោច ណាស់ក៏មានសាច់ញាតិម្នាក់នៅរស់ដែរ ។ សាច់ញាតិដែលរស់ អាចនឹងដឹងពីដោកនាដកម្មរបស់សាច់ញាតិដែលបានបាត់ខ្លួន តាមរយៈរូបថតទាំងអស់នេះ» ។ កាលពីពាក់កណ្តាលខែសីហា ឆ្នាំ២០១២នេះ លោក គូ សុខចន្ធី ក៏បានប្រគល់រូបថតអ្នកទោស ស-២១ ចំនួន១៤សន្លឹកមកមជ្ឈមណ្ឌលឯកសារកម្ពុជាដែរ ដែល រូបថតទាំងអស់នេះគាត់បានរក្សាទុកតាំងពីគាត់នៅក្មេង ហើយ បានឃើញរូបនេះពេលដែលគាត់ឃើញគំនររូបថតជាច្រើនត្រូវ បានគរដុត តែឆេះមិនទាន់អស់ ។

រក្សា យល់ថា ការរកឃើញឪពុករបស់គាត់គឺជាសុបិនមួយ ដែលបានក្លាយជាការពិត ជាសុបិនដែលកម្រនឹងទទួលបាន ។ ទាំង អារម្មណ៍រំជើបរំជួលពេលដែលរកឃើញរូបថត និងប្រវត្តិរូបឪពុក រក្សា បាននឹកឃើញឡើងវិញនូវប្រវត្តិពេលដែលឪពុកនិងម្តាយ


ប្រវត្តិរូបអ្នកទោសជាប់ឃុំឃាំង
លេខទៀង :
ទីផ្នែក
មកពី
១- ឈ្មោះដើម ដួន ហេង
- ឈ្មោះក្រៅ
២- អាយុ ៣៧ ឆ្នាំ ជនជាតិ ខ្មែរ ភេទ ប្រុស
៣- ទីលំនៅកំណើតកើតនៅភូមិ
ឃុំ ស្រុក ខេត្ត
៤- ក្រសួងនឹងនាទី មុនថ្ងៃរំដោះភ្នំពេញ (ក្នុង ឆ្នាំ ១៩៧៥)
៥- ក្រសួងនឹងនាទី បច្ចុប្បន្ន
៦- ឪពុកឈ្មោះ ម្តាយឈ្មោះ
៧- ប្រពន្ធ ឬ ប្តី ឈ្មោះដើម ឈ្មោះក្រៅ
៨- ទីលំនៅកំណើត កើតនៅភូមិ ឃុំ
ស្រុក តំបន់ ខេត្ត
៩- បច្ចុប្បន្ន នៅ
១០- មានកូនប្រុស ចំនួន នាក់ កូនស្រី ១ នាក់
១១- ទីកន្លែងចាប់ខ្លួន
១២- ចាប់ខ្លួន ថ្ងៃទី ១០ ខែ ១ ឆ្នាំ ១៩៧៦

ប្រវត្តិរូបរបស់ ដួន ហេង ដែលទើបតែរកឃើញកាលពីថ្មីៗកន្លងទៅនេះ

របស់គាត់បានបាត់ខ្លួន និងការបាត់ខ្លួនបងស្រីនិងបងប្រុសរបស់អស់រយៈពេលដប់ឆ្នាំ ។

## ជីវិតកុមារភាព

ចាប់កំណើតក្នុងឆ្នាំ១៩៦៨ក្នុងគ្រួសារអ្នកចេះដឹងមួយ និងមានបងប្អូនបីនាក់ រក្សា រស់នៅម្តុំ ផ្ទះរបស់ លន់ នល់ ក្នុងសង្កាត់ទួលទំពូង ។ ឪពុករបស់គាត់ឈ្មោះ ជួន ហេង កើតក្នុងឆ្នាំ១៩៣៧ គឺជាវេជ្ជបណ្ឌិតមួយរូប រហូតដល់ថ្ងៃអវសាននៃរបប លន់ នល់ ។ គាត់គឺជាប្រធានពេទ្យខេត្តតាកែវ ។ ពេលធ្វើការនៅខេត្តតាកែវ ឪពុករបស់ រក្សា តែងតែនាំគាត់ទៅមកខេត្តតាកែវជាប្រចាំ ។ ក្នុងចំណោមបងប្អូនទាំងបីនាក់ រក្សា មានមុខមាត់ស្រដៀងឪពុកជាងគេ ហើយតែងតែនៅក្បែរឪពុកជានិច្ចធ្វើឲ្យមិត្តរួមការងាររបស់ឪពុកគាត់ស្គាល់គាត់យ៉ាងច្បាស់កាលពីជំនាន់ លន់ នល់ ។ ជួន ហេង ត្រូវបានមិត្តរួមអាជីពអះអាងថា ជាវេជ្ជបណ្ឌិតមានកេរ្តិ៍ឈ្មោះមួយរូប ដែលតែងតែជួយអ្នកជំងឺដោយអស់ពីចិត្តថ្លើម ។ មុនយោធាខ្មែរក្រហមចូលដល់ទីរួមខេត្តតាកែវបន្តិច វេជ្ជបណ្ឌិត ជួន ហេង កំពុងតែមមាញឹកយ៉ាងខ្លាំង ក្នុងការព្យាបាលរបួសប្រជាជន និងទាហាន លន់ នល់ ដែលត្រូវរបួសក្នុងសមរភូមិ ។ រក្សា ដែលនៅជាមួយឪពុកកាលពីពេលនោះបាននិយាយថា ជួនកាលឪពុករបស់គាត់ត្រូវបើករថយន្តទៅដឹកអ្នករងរបួសនៅសមរភូមិដោយខ្លួនឯង ។ គាត់ធ្លាប់ឃើញឪពុករបស់គាត់ប្រឡាក់ពេញខ្លួននូវឈាមរបស់អ្នករងរបួស ហើយពេលខ្លះទៀត គាត់ឃើញឪពុករបស់គាត់ភ្ញាក់ពីព្រលឹមដើម្បីទៅព្យាបាលអ្នករបួស ។

ពេលដែលយោធាខ្មែរក្រហមកាន់កាប់ផ្លូវជាតិពីតាកែវមកភ្នំពេញ ការធ្វើដំណើររវាងតំបន់ទាំងពីរអាចធ្វើបានដោយឧទ្ធម្ភាគចក្រប៉ុណ្ណោះ ។ ពីរបីខែមុននឹងខ្មែរក្រហមទទួលជ័យជម្នះ ជួន ហេង កាន់តែមមាញឹកជាងមុនដោយសារតែចំនួនប្រជាជន និងទាហានត្រូវរបួសកាន់តែមានចំនួនច្រើនចូលមកមន្ទីរពេទ្យ ។ ពេលនោះដែរ ឪពុករបស់ រក្សា មិនអាចនាំគាត់មកភ្នំពេញដើម្បីជួបជាមួយម្តាយ និងបងប្អូនបានទេ ។ នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ពេលដែលយោធាខ្មែរក្រហមចូលដល់ទីរួមខេត្តតាកែវ បុគ្គលិកពេទ្យ



ជួន រក្សា និងក្រុមគ្រួសារ

មួយចំនួនធំមិនបានមកធ្វើការទេ ។ តែក្នុងនាមជាប្រធានពេទ្យ វេជ្ជបណ្ឌិត ជួន ហេង បានមកធ្វើការដូចសព្វមួយដងដើម្បីព្យាបាលអ្នករបួសដែលកំពុងតែដង្ហោយហៅគ្រូពេទ្យ ។

## របបខ្មែរក្រហមចូលមកដល់

យោធាខ្មែរក្រហមពណ៌ខ្មៅងងឹតបានចូលដល់ក្រុងតាកែវ នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ ១៩៧៥ ដែលកាលនោះ វេជ្ជបណ្ឌិត ជួន ហេង កំពុងព្យាបាលអ្នកជំងឺ ។ ភ្លាមនោះដែរ ក្នុងភាពចលាចល យោធាខ្មែរក្រហមបានអំពាវនាវឲ្យអ្នកដែលមានតំណែងក្នុងរដ្ឋាភិបាលទាំងអស់មកជួបជុំគ្នាក្នុងទីរួមខេត្តតាកែវដោយយកលេសថា ខ្មែរក្រហម និងឲ្យអ្នកនោះត្រឡប់ទៅធ្វើការនៅកន្លែងដើមវិញ ។ វេជ្ជបណ្ឌិត ជួន ហេង បានបង្ហាញខ្លួន និងរាយការណ៍ជូនយោធាខ្មែរក្រហមដែលមានទឹកមុខប្រកបដោយកំហឹងអំពីតួនាទីពិតប្រាកដរបស់ខ្លួន ។ ក្រោយពីមន្ត្រីរដ្ឋាភិបាលទាំងអស់ជួបជុំគ្នាហើយ យោធាខ្មែរក្រហមជាច្រើននាក់បាននាំមន្ត្រីទាំងអស់ឆ្ពោះទៅវត្តចម្ប៉ា ខាងលិចអង្គតាសោម ស្ថិតក្នុងស្រុកត្រាំកក់ ។

វេជ្ជបណ្ឌិត ជួន ហេង និងអ្នកដទៃទៀតត្រូវបានបណ្តើរទៅកាន់គោលដៅវត្តចម្ប៉ាជាមួយ រក្សា ក្រោមកំដៅថ្ងៃដ៏ក្តៅនៃខែចែត្រ ទាំងគ្មានអាហារ និងទឹកសម្រាប់ផឹក ។ ដោយការហត់នឿយ រក្សា មិនអាចដើរបានយូរទេ ហើយពេលនោះឪពុករបស់គាត់បានឲ្យគាត់ជិះករ និងអៀវដើម្បីធ្វើដំណើរទៅមុខទៀត ។ ដោយធ្ងន់ផងនិងក្តៅផង ឪពុករបស់ រក្សា បានឈប់ជាច្រើនលើក ច្រើនសារដែលជាហេតុធ្វើឲ្យឪពុករបស់គាត់ដាច់ពីហ្វូងមនុស្សរាប់រយនាក់ដែលដើរទៅជាមួយគ្នា ។

ពេលដែលឪពុករបស់គាត់កំពុងតែអៀវ រក្សា មានយោធាខ្មែរក្រហមក្មេងម្នាក់ដែលស្គាល់ឪពុកគាត់ បានប្រាប់គាត់ឲ្យគេចចេញពីហ្វូងមនុស្សនោះដោយប្រាប់ថា អ្នកទាំងអស់នោះនឹងត្រូវយកទៅសម្លាប់នៅជិតវត្តចម្ប៉ា ។ ពេលនោះ ឪពុករបស់គាត់បានខិតខំគេចវេះបំបែកខ្លួនចេញពីហ្វូងមនុស្សនោះ ហើយទីបំផុត ឪពុករបស់គាត់បានធ្វើដំណើរមកដល់ភូមិកំណើតរបស់គាត់នៅភូមិសម្តេចពាន់ ស្រុកព្រៃកប្បាស ។ ទីនោះហើយដែល រក្សា និងឪពុករបស់គាត់បានជួបជុំគ្រួសារឡើងវិញដែលមកពីភ្នំពេញ ។

នាចុងឆ្នាំ១៩៧៥ ខ្មែរក្រហមមានបំណងបញ្ជូន «ប្រជាជនថ្មី» ដែលមានសមាសភាពមិនល្អទៅកាន់តំបន់ដែលសម្បូរដោយវាលស្រែក្នុងខេត្តពោធិ៍សាត់ និងបាត់ដំបង ។ ពេលដែលកម្មាភិបាលខ្មែរក្រហមប្រកាសរកអ្នកស្ម័គ្រដើម្បីទៅខេត្តទាំងពីរនេះ ឪពុករបស់ រក្សា ក៏លើកដៃដើម្បីស្ម័គ្រចិត្តទៅខេត្តបាត់ដំបង ដោយគាត់គិតថា តំបន់នោះមានវាលស្រែធំល្វឹងល្វើយ ដូច្នេះប្រហែលជាមានផលដំណាំ និងស្រូវច្រើនហូបចុកគ្រប់គ្រាន់ជាងស្រុកព្រៃកប្បាស ។ មួយរយៈក្រោយមក ក្រុមប្រជាជនថ្មីដែលជ្រើសរើសដោយខ្មែរក្រហមត្រូវបានដឹកតាមរថភ្លើងឆ្ពោះទៅសេរីសោភ័ណ ។ រក្សា មិនចាំថា ការធ្វើដំណើរនោះស៊ីពេលប៉ុន្មានថ្ងៃទេ តែគាត់ចាំបានថា រថភ្លើងបានទៅដល់សេរីសោភ័ណនៅវេលាម៉ោងប្រហែលជាប្រាំបីល្ងាច ។ ក្រោយពីនៅសេរីសោភ័ណបានបីបួនថ្ងៃ គ្រប់សមាជិកគ្រួសាររបស់ រក្សា ទាំងអស់ត្រូវបានដឹកតាមរថយន្តទៅនៅភូមិប៉ោយសំរោង ឃុំប៉ុស្តិ៍ចាស់ ស្រុកព្រះនេត្រព្រះ សព្វថ្ងៃខេត្តបន្ទាយមានជ័យ ដែលនៅទីនោះ គ្រួសាររបស់ រក្សា បានរស់នៅជាមួយគ្រួសារអ្នកមូលដ្ឋានមួយ ។ ក្រោយពេលទៅដល់ទីនោះ ឪពុករបស់ រក្សា អាចនៅជួបជុំគ្រួសារបានតែបីថ្ងៃប៉ុណ្ណោះ មុននឹងឪពុករបស់គាត់ត្រូវបានបញ្ជូនឲ្យទៅរៀនសូត្រ តាមពិតខ្មែរក្រហមបញ្ជូនឪពុកគាត់ទៅមន្ទីរសន្តិសុខជុប ។ ថ្ងៃដែលឪពុករបស់គាត់ត្រូវបានបញ្ជូនទៅជុប រក្សា មិននៅផ្ទះទេ មានតែម្តាយ បងស្រី និងប្អូនប្រុសប៉ុណ្ណោះដែលនៅផ្ទះ ។ ដោយសារកម្មាភិបាលខ្មែរក្រហមត្រូវនាំឪពុករបស់គាត់ទៅជាបន្ទាន់ ហើយមិនអាចរង់ចាំ រក្សា ត្រឡប់មកវិញបាន ឪពុករបស់គាត់បាននិយាយ ផ្តាំទៅ រក្សា តាមរយៈបងស្រីរបស់គាត់ថា «ប្រាប់កូនរក្សាផងថា កុំរពឹសពេក ត្រូវចេះនៅជាមួយម៉ាក់ និងបងប្អូន ។ ប៉ាទៅតែពីរបីថ្ងៃទេ ត្រឡប់មកវិញហើយ» ។ នេះជាសម្តីឪពុកដែលបានផ្តាំមក រក្សា ជាលើកចុងក្រោយតាមរយៈបងស្រីរបស់គាត់ ។ ឪពុករបស់គាត់មិនបានវិលតាមការសន្យាទេ ហើយ រក្សា ក៏មិនដែលបានទទួលដំណឹងពីឪពុកជារៀងរហូតតាំងពីពេលនោះមក ។

រក្សា បាននិយាយរៀបរាប់ថា ចាប់តាំងពីឪពុករបស់គាត់ត្រូវបានបញ្ជូនទៅជុប ម្តាយរបស់គាត់នៅផ្ទះមានជំងឺជាប្រចាំរហូតដល់គាត់បាត់បង់ជីវិតដោយគ្មានវត្តមានរបស់ រក្សា ។ រក្សា ចាំបានថា ម្តាយគាត់បានឲ្យគ្រឿងអលង្ការបន្តិចបន្តួចដែលយកមកពី

ភ្នំពេញទៅអ្នកមូលដ្ឋានរហូតអស់ពីខ្លួនដើម្បីស៊ើបសួរពីដំណឹងរបស់ឪពុកគាត់ ។ តែចម្លើយដែលម្តាយ និងរក្សាទទួលបានគឺថាឪពុកនឹងត្រឡប់មកវិញថ្ងៃស្អែក ឬថ្ងៃខានស្អែក ។ តែនោះគ្រាន់តែជាការកុហកប៉ុណ្ណោះ ។ ឪពុករបស់គាត់មិនបានមកវិញទេ ដែលជាហេតុធ្វើឲ្យម្តាយរបស់គាត់មានជំងឺកាន់តែខ្លាំងឡើងៗ ។

ក្នុងឆ្នាំ១៩៧៧ រក្សា ត្រូវបានចាត់តាំងឲ្យចូលក្នុងកងកុមារ ហើយត្រូវបានបញ្ជូនឲ្យទៅធ្វើការឆ្ងាយពីផ្ទះ ។ ពេលដែលគាត់ធ្វើការឆ្ងាយពីផ្ទះ ហើយមិនត្រូវបានអនុញ្ញាតមកលេងផ្ទះម្តាយរបស់គាត់មានជំងឺកាន់តែធ្ងន់ជាងមុន ដែលក្រោយមកត្រូវបានបញ្ជូនទៅមន្ទីរពេទ្យនៅសេរីសោភ័ណជាមួយបងស្រី និងប្អូនប្រុសរបស់គាត់ ។ ចាប់តាំងពីពេលនោះមក រក្សា ក៏មិនដែលបានជួបអ្នកទាំងបីដែរ ។

## កុមារកំព្រានៅជាមួយម្តាយចិញ្ចឹម

ក្រោយពីបែកម្តាយ បងស្រី និងប្អូនប្រុសយូរ រក្សា ខិតខំរូតរះរត់ទៅជួបម្តាយ និងបងប្អូនវិញ ក្រោយពីទាហានវៀតណាមមានជ័យជម្នះលើខ្មែរក្រហម ។ ដោយបែកគ្នាយូរ រក្សា មានចិត្តនឹករឭកម្តាយនិងបងប្អូនខ្លាំងណាស់ ។ ប៉ុន្តែពេលមកដល់ផ្ទះ រក្សា មិនបានជួបម្តាយនិងបងប្អូនទេ ដែលជាហេតុធ្វើឲ្យជីវិតរបស់គាត់កាន់តែតែលតោលដូចចករសាត់គ្មានត្រើយ ។ ដោយគ្មានបងប្អូនសម្រាប់ជាទីពំនាក់អាស្រ័យនិងក្តីរឭកម្តាយផង រក្សា បានយំយ៉ាងខ្លាំងដោយក្តីអស់សង្ឃឹម និងការបាត់បង់ដោយគ្មានអ្វីប្រៀបផ្ទឹមបាន ។ ដោយមិនដឹងថាត្រូវទៅណា រក្សា ក៏នៅជាមួយឪពុកម្តាយចិញ្ចឹមនៅជិតទីរួមស្រុកមង្គលបុរី រហូតមក ។

រក្សា រស់នៅជាមួយឪពុកម្តាយចិញ្ចឹមរហូតដល់ឆ្នាំ១៩៨៩ ដោយបានរៀនសូត្របន្តិចបន្តួច ។ នៅឆ្នាំនោះដែរ រក្សា បានចូលធ្វើទាហានរដ្ឋាភិបាលនៅសេរីសោភ័ណ ហើយគាត់បានចូលវាយប្រយុទ្ធជាមួយទាហានខ្មែរក្រហមនៅសមរភូមិចំនួនពីរលើកដោយក្តីកំហឹងឈឺចាប់ដែលបានធ្វើឲ្យសាច់ញាតិរបស់គាត់បែកបាក់គ្នា ។ ដោយក្តីអង់អាចក្លាហាននៅក្នុងសមរភូមិ រក្សា ត្រូវបានបញ្ជូនឲ្យទៅទទួលបណ្តុះបណ្តាលបន្ថែមនៅខុត្តគ្គ ។

## បន្តរកអ្នកមានគុណ និងការជួបជុំបងប្អូន

ពេលមកដល់ឧត្តុង្គនាចុងឆ្នាំ១៩៨៩ រក្សា នឹកឃើញថាទីនោះកាន់តែជិតទីក្រុងភ្នំពេញហើយ ម្យ៉ាងវិញទៀត គាត់មិនដែលបានមកភ្នំពេញទាល់តែសោះតាំងពីឆ្នាំ១៩៧៥មក ។ រក្សា នឹកឃើញចង់ស្វែងរកម្តាយ និងបងប្អូនដែលពីមុនធ្លាប់រស់នៅម្តុំទួលទំពូង ។ រក្សា បានសុំលុយបន្តិចបន្តួចពីមេបញ្ជាការរបស់គាត់ ដើម្បីធ្វើជាសោហ៊ុយមកភ្នំពេញដើម្បីទៅផ្ទះគាត់នៅទួលទំពូងដើម្បីស្វែងរកម្តាយ បងប្អូន និងមាមីង ។ ពេលមកដល់ រក្សា បានឃើញផ្ទះរបស់ខ្លួនដោយក្តីស្រងេះស្រងោចយ៉ាងខ្លាំង ។ គាត់មិនអាចធ្វើបានទាំងអស់ ក្រៅតែពីយំព្រោះតែនឹកឃើញដល់ឪពុកម្តាយ និងបងប្អូនដែលធ្លាប់រស់នៅយ៉ាងសុខសាន្តនៅផ្ទះនោះកាលពីមុនឆ្នាំ១៩៧៥ ។ រក្សា បានឃើញផ្ទះដែលគ្រួសាររបស់គាត់ធ្លាប់នៅត្រូវបានកាន់កាប់ដោយអ្នកផ្សេងទៀតដែលបានចូលមកនៅតាំងពីឆ្នាំ១៩៧៩មក ។ ទាំងក្តីទុក្ខសោក រក្សា បានចាកចេញពីអតីតផ្ទះរបស់ខ្លួន រួចធ្វើដំណើរទៅស្ថានីយវិទ្យុជាតិស៊ឹងមានជ័យ ដើម្បីសុំឲ្យផ្សព្វផ្សាយរកម្តាយ និងបងប្អូន ។ ដោយមិនអស់ចិត្តទាំងក្នុងឯកសណ្ឋានកងទ័ព រក្សា បានធ្វើដំណើរទៅខេត្តតាកែវ ជាកន្លែងដែលឪពុករបស់គាត់ធ្វើការ ។ ពេលមកដល់បរិវេណខាងក្រោមមន្ទីរពេទ្យតាកែវ រក្សា បានសម្លឹងឃើញផ្ទះដែលគាត់ធ្លាប់រស់នៅជាមួយឪពុក ។ ដោយមិនបង្អង់យូរ គាត់បានផ្ទោះរបងពេទ្យចូលទៅក្នុងមន្ទីរពេទ្យដែលធ្វើឲ្យបុគ្គលិកពេទ្យមានការភិតភ័យយ៉ាងខ្លាំងដោយសារតែគាត់ឋិតក្នុងឯកសណ្ឋានយោធា ។ ភ្លាមនោះ រក្សា បានប្រាប់ទៅគ្រូពេទ្យដែលកំពុងភិតភ័យទាំងនោះថា "ឈប់សិន! ខ្ញុំមកទីនេះដើម្បីរកឪពុកខ្ញុំទេ" ។ ព្រោះដូច្នេះ គ្រូពេទ្យម្នាក់បានទៅអញ្ជើញវេជ្ជបណ្ឌិតចាស់ៗដែលធ្លាប់ធ្វើពេទ្យកាលពីមុនរបបខ្មែរក្រហមដើម្បីមកជួប រក្សា ។ ពេលដែលគ្រូពេទ្យចាស់ៗមកដល់ភ្លាម គ្រូពេទ្យទាំងនោះបានស្គាល់ រក្សា យ៉ាងច្បាស់ ព្រោះពេទ្យទាំងនោះក៏ធ្លាប់ត្រូវបានជម្លៀសទៅវត្តចម្ប៉ាជាមួយ រក្សា និងឪពុករបស់គាត់ដែរកាលពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ។ វេជ្ជបណ្ឌិតម្នាក់ដែលជាអតីតមិត្តភក្តិរបស់ឪពុក រក្សា បាននាំគាត់មកជួបនឹងមីងរបស់គាត់នៅម្តុំសន្ធរម៉ុកក្រុងភ្នំពេញ ។ រក្សា បានជួបជាមួយមីង និងបានរស់នៅជួបជុំគ្នាតាំងពីពេលនោះមក ។ ក្រោយមកទៀត រក្សា បានទៅផ្ទះដែលគាត់ធ្លាប់នៅម្តុំទួលទំពូងម្តងទៀតដើម្បីសរសេរសំបុត្រមួយច្បាប់ផ្ញើជូនម្ចាស់ផ្ទះក្រែងលោមានម្តាយ និងបងប្អូនរបស់គាត់តាមរកគាត់នៅផ្ទះចាស់ ។ រក្សា បានសរសេរសំបុត្រនោះ

ដោយរៀបរាប់ថា "ខ្ញុំឈ្មោះ រក្សា ។ ខ្ញុំនៅរស់ទេ ។ បើម៉ែ បងស្រី និងប្អូនប្រុសមកផ្ទះយើង សូមមករកខ្ញុំនៅផ្ទះមីងនៅម៉ុំសន្ទរម៉ុក" ។

ពីរឆ្នាំក្រោយមក បងស្រី និងប្អូនប្រុសរបស់គាត់បានមករក រក្សា នៅផ្ទះដែលធ្លាប់រស់នៅ ហើយក្រោយមកអ្នកទាំងបីក៏បានជួបជុំបងប្អូនរហូតមក ។ ថ្ងៃនោះហើយដែល រក្សា ដឹងថា ម្ដាយរបស់គាត់បានស្លាប់នៅមន្ទីរពេទ្យមង្គលបូរីតាំងពីចុងឆ្នាំ១៩៧៨មកម៉្លេះ ។

## ស្វះស្វែងរកឪពុក

ការបាត់ខ្លួនរបស់ឪពុករបស់ រក្សា នៅតែអាថ៌កំបាំងនៅឡើយ ។ តែទោះជាយ៉ាងណា ក៏ រក្សា មិនដែលបោះបង់ចោលក្ដីសង្ឃឹមក្នុងការស្វែងរកឪពុកម្ដងណាឡើយ ។ រក្សា តែងមានជំនឿថា នឹងមានពត៌មានណាមួយអំពីជោគវាសនារបស់ឪពុក ។ គាត់បានស្វះស្វែងរកជារៀងរហូតមកដោយនិយាយទៅកាន់អ្នកដែលធ្វើការជាមួយគ្នា និងមន្ត្រីរដ្ឋាភិបាលមួយចំនួនដែលធ្លាប់ធ្វើជារដ្ឋការកាលពីជំនាន់ លន់ នល់ ។ ជីតាសាច់ឆ្ងាយរបស់ រក្សា ម្នាក់បានប្រាប់គាត់ថា ឪពុករបស់គាត់ត្រូវបានបញ្ជូនចេញពីជុំបហើយ គឺមានន័យថា មិនមែនស្លាប់នៅទីនោះទេ ។ ចំណែកមិត្តភក្ដិរបស់ឪពុកគាត់ម្នាក់ទៀតដែលធ្លាប់ជាវេជ្ជបណ្ឌិតដែរ ដែលកំពុងរស់នៅសហរដ្ឋអាមេរិក និងបានមកលេងស្រុកខ្មែរថ្មីៗនេះបានប្រាប់ រក្សា ថា ឪពុករបស់គាត់ត្រូវបានបញ្ជូនមកមន្ទីរស-២១ ។

ព័ត៌មាននេះបានជំរុញឲ្យ រក្សា ទៅស្វែងរកព័ត៌មានទាក់ទងទៅនឹងឪពុករបស់គាត់នៅសារមន្ទីរប្រល័យពូជសាសន៍ទួលស្លែង ហើយគាត់បានជួបជាមួយបុគ្គលិករៀបចំឯកសារម្នាក់នៅទីនោះ ។ ពីដំបូង ឯកសារទាក់ទងនឹងឪពុករបស់គាត់មិនត្រូវបានរកឃើញទេ ដែលធ្វើឲ្យ រក្សា កាន់តែមានមន្ទិលទៀត ព្រោះមិនដឹងថាឪពុករបស់ខ្លួនត្រូវបានបញ្ជូនទៅទីណាពិតប្រាកដ ។ ក្រោយមក រក្សា ទទួលបានសៀវភៅមួយក្បាលដែលមានរាយឈ្មោះអ្នកទោស ស-២១ បោះពុម្ពដោយសារមន្ទីរទួលស្លែងក្នុងឆ្នាំ១៩៨០ ។ នៅក្នុងសៀវភៅនោះ រក្សា បានឃើញអ្នកទោសម្នាក់ឈ្មោះ នួន ហេង ជាវេជ្ជបណ្ឌិតដែលត្រូវបានចាប់ខ្លួនពីស្រុកព្រះនេត្រព្រះ ។ ដោយស្រដៀងគ្នាទៅនឹងឈ្មោះឪពុករបស់ខ្លួន រក្សា បានកាន់សៀវភៅនោះទៅសារមន្ទីរទួលស្លែងម្ដងទៀត តែប្រវត្តិរូប នួន ហេង នៅតែរកមិនឃើញដដែល ។ ដោយឆ្លងកាត់ការស្វែងរកជាច្រើនលើកច្រើនសារ និងគ្រប់ទីកន្លែង រក្សា បានរកឃើញប្រវត្តិរូប និងរូបថតរបស់ឪពុកគាត់នៅមជ្ឈមណ្ឌលឯកសារកម្ពុជា នៅថ្ងៃទី១៦ ខែសីហា ឆ្នាំ ២០១២ ។ ថ្ងៃនោះហើយដែល រក្សា បានជួបឪពុករបស់គាត់តាមរយៈរូបថត និងប្រវត្តិរូប ។

## កំហឹងចង់សងសឹកនៅតែពុះកញ្ជ្រោល

បច្ចុប្បន្ននេះ រក្សា នៅតែមានកំហឹងនឹងខ្មែរក្រហមជានិច្ច ។ គាត់មានចិត្តចង់សងសឹកចំពោះខ្មែរក្រហម ។ គាត់ស្អប់មេដឹកនាំខ្មែរក្រហមដែលបានសម្លាប់ឪពុកម្ដាយរបស់គាត់ និងបង្កឲ្យគាត់ព្រាត់ប្រាស់ពីបងប្អូន ។ ទោះបីជារបបខ្មែរក្រហមបានកន្លងផុតទៅជាយូរមកហើយក៏ដោយ ក៏កំហឹងនេះនៅតែមាននៅឡើយ ។ រក្សា បានបន្ទោស តាម៉ុក រក្សា បានហៅថា (អា ម៉ុក) និង ឌុច រក្សា ហៅថា (អា ឌុច) ដែលបានធ្វើឲ្យឪពុកគាត់ស្លាប់ ។ ជាអកុសល រក្សា ទើបតែដឹងដំណឹងក្រោយពេលដែល ឌុច ត្រូវបានដាក់ទោសអស់មួយជីវិត ។ រក្សា បាននិយាយដោយកំហឹងថា "បើខ្ញុំដឹងថាឪពុករបស់ខ្ញុំត្រូវបានសម្លាប់នៅទួលស្លែង ខ្ញុំនឹងប្ដឹងអា ឌុច ជាមិនខាន" ។

រក្សា មិនគ្រាន់តែស្អប់ តាម៉ុក និងឌុច ប៉ុណ្ណោះទេ គឺគាត់ស្អប់មេដឹកនាំខ្មែរក្រហមទាំងអស់ដែលជាជនជាប់ចោទនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាសព្វថ្ងៃ ។

ទោះបីជាកំហឹងនៅតែមានកំដៅស្មើនិងទឹកពុះមួយរយអង្សារក៏ដោយ ក៏ពេលនេះ រក្សា មាន អារម្មណ៍ធូរមួយកម្រិតធំ និងអាចសម្រួបសម្រួមចិត្តរបស់ខ្លួនបានខ្លះព្រោះគាត់បានរកឃើញដំណឹងឪពុកដើម្បីគាត់អាចធ្វើបុណ្យតាមប្រពៃណីព្រះពុទ្ធសាសនាដើម្បីឲ្យព្រលឹងរបស់ឪពុកគាត់បានទៅកាន់សុគតិភព ។ ទោះបីជា រក្សា រកឃើញឪពុករបស់គាត់ស្លាប់ហើយក៏ដោយ ក៏ពេលនេះ គាត់មានអារម្មណ៍ថា គាត់កំពុងតែនៅក្បែរឪពុកម្ដងទៀតក្រោយពីបានបែកគ្នាអស់ជិត៤០ឆ្នាំ ។ **ញាណ សុជាតិ**

- ◆ **និយាយពីការរស់នៅក្នុងសម័យខ្មែរក្រហម គឺនិយាយពីការផ្សះផ្សា អប់រំកូនចៅឱ្យអត់ឱន អធ្យាស្រ័យគ្នា**
- ◆ **រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ គឺរៀនពីការទប់ស្កាត់អំពើប្រល័យពូជសាសន៍**

# ស៊ីវ ធួន ៖ ដំណើរឆ្លងកាត់របបខ្មែរក្រហម


ស៊ីវ ធួន ថតនៅឆ្នាំ១៩៨៤

**(តពីលេខមុន)**

## ម្ហូបគួរឲ្យធុញទ្រាន់

ពួកខ្ញុំទាំងប្រាំនាក់មានដំរីខ្ទមមួយនៅខាងត្បូងភូមិ ដំបូលប្រក់ស្លឹកបបុសនៅកណ្ដាលថ្ងៃដោយពុំមានម្ជប់ដេកផ្ទាល់ដីដោយក្រាលស្លឹកជំនួសកន្ទេល ។ យើងហូបម្ហូបស្ងោរ អាំង ម្ជូរព្រឹកល្ងាច នាំឲ្យយើងធុំ ។ ពេលនោះគ្មាននរណាចង់ហូបសាច់ត្រីទេ គិតតែពីហុតទឹកសម្ល ហើយខ្ញុំខ្លាចបំផុតគឺពោះត្រី ព្រោះវាមានខ្លាញ់ ។ ជួនកាលពេលខ្លះខ្ជិលស្ល ក៏នាំគ្នាទៅយកត្រីឆ្អើរម្នាក់មួយចង្កាក់មកកាច់ជ្រលក់ជាមួយទឹកត្រីហូបដោយក្នុងមួយចង្កាក់យើងហូបអស់តែត្រីមួយ ឬពីរប៉ុណ្ណោះ ហើយក៏ទុកចោលនៅលើដំបូល ។ ពីរបីថ្ងៃឃើញគរនៅលើដំបូលច្រើនពេក ខ្លាចប្រធានអង្គភាពឃើញ ក៏ដឹកជញ្ជូនយកទៅចោលក្នុងព្រៃខាងក្រោយភូមិ ។ ចំណែកត្រីដុតក៏ដូចគ្នា យើងហូបមិនអស់ ក៏នាំគ្នាលួចយកទៅបោះចោលនៅក្នុងព្រៃពីរបីថ្ងៃក្រោយមកក៏ធុំក្លិនស្អុយ ព្រោះសត្វឆ្កែ និងឆ្មានៅក្នុងភូមិតែងតែព្រងើយកន្តើយនឹងចំណីនេះណាស់ ។ ពេលខ្លះយើងជួយឆ្អើរត្រី ដោយត្រូវរុញខស និងប្រែត្រី ធ្វើឲ្យយើងហូរទឹកភ្នែក ដោយទ្រាំនឹងផ្សែងមិនបាន ប៉ុន្តែទោះជាយ៉ាងណាត្រូវខស្សរាហ៍ប្រែដើម្បីឲ្យវាឆ្អិនបានល្អ ។

## ដើមរាំងខសពិសេស

ក្រោយមកយើងតែងចេញពីព្រលឹមបរទេះក្របីពីរចុះទៅក្រោមប្រហែលប្រាំពីរគីឡូម៉ែត្រ យើងជិះរទេះខ្លះ ដើរខ្លះ និងលីផ្កាក់ម្នាក់មួយ ។ យើងធ្វើដំណើរស្ទើរមួយព្រឹកទើបទៅដល់ដំរីព្រៃរាំង ។ ដើមរាំងដុះរលួនចោលមែក និងស្លឹកបង្កើតបានជាម្លប់ត្រឈឹងត្រឈៃមើលថ្ងៃមិនឃើញ ។ រាំងមួយគុម្ព មានដើមតូចធំនៅប្រជ្រៀតគ្នាប្រហែល១០ទៅ១៥ដើម ក្នុងមួយរទេះយើងកាប់តែពីរគុម្ពបានជាស្រេច ។ នៅព្រៃរនាម មិនថាដើមរាំងទេ សូម្បីតែភ្នំភ្លើង និងកប្បាសព្រៃក៏មានដើមរហូតដល់ប៉ុនកដៃ ហើយវែងៗ ។ កាប់ខសពីររទេះមិនពិបាក និងមិនយូរឡើយ យើងកាប់តែកន្លះម៉ោង ឬមួយម៉ោងបានខសពេញរទេះ ។ ដើមរាំងរស់ជាខសល្អបំផុតសម្រាប់យកមកឆ្អើរត្រី ព្រោះមានទឹកច្រើន ឆេះយឺត ហើយសម្បូរផ្សែង ។

ក្រោយពីកាប់ខសបានហើយ យើងក៏ដាំបាយដោយយកខសដើមភ្នំភ្លើងផាប់យកទៅដុតឆេះ ហើយរងើកល្អ ។ លុះឆ្អិនហើយ យើងមិនដែលហូបទឹកឆៅ ក៏យកកំសៀវប្រកទឹកពេញ ក៏ដាំបង្គោលពីដែលមានជំពាមដោតទៅនឹងដី ហើយកាប់មែកឈើប្រវែងកន្លះម៉ែត្រមកដាក់លើជំពាមបង្គោលទាំងពីរបង្កើតបានជាស្នួរមួយរួចយកដែកំសៀវព្យួររួចដុតភ្លើងពីក្រោម លុះគ្រាទឹកនោះពុះមួយស្របក់ធំទើបយើងហូប ព្រោះយើងជឿថានៅព្រៃរនាមវាសម្បូរទៅដោយពងមូស និងមេរោគមួយចំនួនទៀតដែលកើតនៅលើដីសើម ។

នៅពេលបាយរួចក៏នាំគ្នាដេកថ្ងៃមួយស្របក់ ប៉ុន្តែអ្នកដែលមិនចង់ដេកក៏ដើររកឃ្មុំដែលភាគច្រើនចូលចិត្តធ្វើសំបុកលើ

ដើមតាអ្នូរ ។ តាអ្នូរ ជាឈើម្យ៉ាង សម្បកស្រដៀងដើមស្រឡៅ ប៉ុន្តែកំពឹកកំពក ដូចដើមត្របែកព្រៃ មានសាច់ស្អិតហើយរឹង ។ ជារៀងរាល់លើក នៅថ្ងៃបាក់រសៀល វេលាម៉ោងប្រហែល៣ល្ងាច យើងទៅចាប់ក្របីមកទឹមត្រឡប់មកភូមិវិញ ដោយមានដើមរាំងគរពេញលើរទេះដែលក្របីអូសយ៉ាងតឹង ។ នៅតាមផ្លូវយើងតែងប្រទះឃើញពស់ថ្លាន់ធំៗវាកាត់មុខ ពេលខ្លះក៏នាំស្នាក់ចាប់យកមកខហូបជំនួសត្រី ។

## សត្វព្រៃរនាម

នៅក្នុងព្រៃរនាមសម្បូរទៅដោយសត្វស្វា និងពស់មានពិស ដូចជា ពស់វែកក្របី វែកស្រវែង និងវែករនាម ភាសាអ្នកស្រុកហៅទ្រង់រនាម ។ កាលណាចូលព្រៃរនាម ត្រូវងើបមើលលើ ឬមើលក្រោម ឬយករំពាត់ទៅវាត់ព្រៃខ្លាចមានសត្វអាសិរពិសនៅក្នុងនោះឲ្យវារត់ចេញ ។ បើតាមអ្នកស្រុកនិយាយ កាលពីមុនឆ្នាំ១៩៧០ សម្បូរដំរីរនាមណាស់ វាតែងតែដើររកស៊ី និងដេកនៅក្នុងព្រៃរនាម ។ ជួនកាលមានដំរីកាច ដេញមនុស្សនៅពេលដែលវាជួបម្តងៗ ។ ទោះជាមកដល់ពេលនេះដំរីបាត់ពីព្រៃរនាមទៅហើយក៏ដោយ ក៏វាបន្សល់ទុកដានជើងនៅក្នុងជម្រៅព្រៃរនាម ហើយនៅរដូវប្រាំងស្នាម ជើងរបស់វានៅសល់ដូចជាពុម្ពនៅលើដីឥដ្ឋ ។

ព្រៃរនាមក៏សម្បូរទៅដោយសត្វអណ្តើកតូចធំ រហូតដល់អណ្តើកសាកលទៀតផង ។ ពេលរដូវទឹកស្រកនៅដីទន់ៗ វាក៏វារឡើងទៅក្នុងព្រៃដើម្បីរកកន្លែងពង លុះពងរួចហើយវាអូសស្នូកថយក្រោយ ដើម្បីពន្លាងដានមនុស្សកុំឲ្យរកពងវាឃើញ បន្ទាប់ពីពងហើយ វាក៏ក្រាំងបង្កប់ខ្លួននៅក្រោមស្លឹកឈើ ។ បើចង់រកវាយើងគ្រាន់តែយកកណ្តៀវហៅថា ខ្វែរអូសខាងចុង បើកាលណាឮសូ "ឃូសៗ" គេគាស់បង្ហើបឡើងនឹងចុងខ្វែរ ។ បើកាលណាឃើញអណ្តើកតូចពេកគេលែងចោល បើធំគេយកវាដោយចងស្នូកនឹងវល្លិ៍តាអើក រួចរែកយកមកភូមិ ។ អណ្តើកធំៗ យើងរែកពីរនាមទំរាំដល់ភូមិ យើងប្តូរស្មាម្តងឆ្វេង ម្តងស្តាំ ជួនកាលយើងឈប់ដើម្បីបន្ធូរការចុករោយស្មា ។

នៅក្នុងបឹងដែលមានទឹកជិតរីង យើងឃើញសត្វកុក, ត្រយ៉ង, គ្រៀល, ត្រដក់ និងសត្វស្លាបធំៗទៀតចុះទៅស៊ីត្រីដោយត្បុលក្បាលទៅក្នុងភក់ បះគូថឡើងលើដែលធ្វើឲ្យយើងមានភាពងាយស្រួលដើម្បីចាប់វា ដោយគ្រាន់តែវាយនឹងដំបង ។ ជួនកាលមានវិធីមួយដើម្បីចាប់វា គឺនាំគ្នាស្រែកឲ្យអស់សំឡេងធ្វើឲ្យវាស្លុតហើរមិនរួច រួចវាយនឹងដំបង ។ ខណៈនោះ វាដូចជាឆាកប្រយុទ្ធមួយ ព្រោះវាទ័លច្រកវាក៏ហារជំពុះចឹកយើង ។ វាខ្ពស់ហើយកវែងទៀត ពិតជាពិបាកទប់ទល់ជាពិសេសចំពោះល្វែងក្រោម ។

## ដំណើរទៅនេសាទ

លុះផុតរដូវត្រីចេញ គេនាំគ្នាហ៊ុមអួន និងសម្រះ នៅតាមដងស្ទឹង និងតាមដៃទន្លេសាប ដូចជាពាមសីមាជាដើម ។ យើងជិះទូកតាមស្ទឹងដើម្បីឆ្ពោះទៅទិសដៅដែលអ្នកស្រុកធ្លាប់ដឹងពីភូមិសាស្ត្រថា កន្លែងណាមានត្រីច្រើន ។ ជារៀងរាល់ថ្ងៃ មានទូកចែវចំនួនពីរគ្រឿងតែងតែចាកចេញពីភូមិវេលាម៉ោង៦កន្លះព្រឹកដើម្បីទៅដល់កន្លែងចាប់ត្រីវេលាម៉ោង៩ ឬក៏៩កន្លះព្រឹក ។ នៅពេលមុនចេញដំណើរ យើងទាំងអស់ជញ្ជូនកូនឈើដែលសម្រួចហើយ៤ ឬ៥ដើម សម្រាប់វាយអួន ។ យើងដោតឈើនោះបញ្ឈរដើម្បីទាញសាច់អួនឲ្យតឹង និងរៀបចំអង្ករ អំបិល ទឹកត្រីថ្នាំជក់ ព្រមទាំងឆ្នាំងចានដើម្បីយកទៅដាំបាយហូបនៅកន្លែងរកត្រី ។ ពេលនោះរបស់ដែលមានតម្លៃបំផុតគឺថ្នាំជក់ ហើយរៀងរាល់លើក យើងតែងតែញាត់ថ្នាំជក់ដាក់ក្នុងកេះគ្រាប់កាំភ្លើងប៊ីនយ៉ាងណែនដែលមានទម្ងន់ប្រហែលមួយទៅ១គីឡូក្រាមកន្លះដើម្បីយកទៅជក់ ។ យើងដាក់ក្នុងឃ្មុបទូកផ្នែកខាងក្រោយ អ្វីដែលធ្ងន់ជាងគេគឺសាច់អួន ត្រូវនាំគ្នាសែងពីរទៅបីនាក់មាន ខ្ញុំ, មិត្តចុល និងមិត្តឌុល ជាដើម ។ អួនមានសាច់សំពីងសំពោង ដោយកំសួល ។ ភាគច្រើន យើងប្រើអួនក្រឡាបួនហ៊ុន ដើម្បីចាប់យកត្រីកេះត្រីក្រម៉ម និង ត្រីក្រោស ទៀតផង ។ ជួនកាល យើងចាប់បានត្រីឆ្តោ, ត្រីសណ្តាយ និងត្រីកញ្ជនដៃ ។ ទូកនីមួយៗផ្ទុកមនុស្សពី៤-៥នាក់ ចែវបណ្តោយស្ទឹងចេះតែរំកិលខ្លួននៅក្រោមម្លប់ឈើធំតូច ដែលដុះគ្របនៅលើមាត់ស្ទឹងទាំងសងខាងចោលម្លប់ នាំឲ្យមានភាពងងឹតដោយអន្ទើ ផ្សំជាមួយអ័ព្ទដែលហុយលើផ្ទៃទឹកនៅខាងមុខរកមើលអ្វីពុំឃើញច្បាស់ ។ កាលណាយើងចែវយើងតែងក្រឡេកមើលទៅមុខ និងទៅក្រោយប្រហែល១០ម៉ែត្រ យើងឃើញហាក់ដូចជាមានផ្សែងហុយចេញពីលើផ្ទៃទឹកស្ទឹងនាពេល

ព្រឹកព្រលឹម ដែលកំពុងជះ ចំហាយត្រជាក់ក្រៃលែង ។

## ខែកក្ដិកខ្លាចទឹក

យើងជិះទូក យើងខ្លាចទឹក ជួនកាលអ្នកចែវធ្វើឲ្យភ្លាត់ឈើចែវម្ដងៗទឹកក៏ខ្ទាតមកទទឹកយើង ធ្វើឲ្យរងាររណ្ដំថ្គាមពេលដែលយើងកំពុងអង្គុយបញ្ឈរជង្គង់ និងឱបដៃយ៉ាងណែនដើម្បីឲ្យខ្លួនមានកម្ដៅ ។ អាកាសធាតុត្រជាក់នៅខែបុស្ស និងមាឃ បានធ្វើឲ្យយើងនឹកឃើញកាលនៅពីកុមារភាពដែលយើងខ្លាចទឹក ហើយម្នាក់ៗ តមទឹករហូតមួយអាទិត្យ ឬដប់ថ្ងៃ ។ ទោះបីជា ចាស់ៗប្រាប់ថា ឯងផ្ងូតទឹកបាត់រងាក៏មិនជឿគាត់ដែរ ។ យើងគ្រប់គ្នាតែងតែឡើងអាំងភ្លើងតាំងពីម៉ោង៤ភ្លឺជាមួយគ្រួសារ ចំណែកអ្នកភូមិជិតខាងក៏គេធ្វើដូចយើងដែរ ព្រោះនៅវេលាម៉ោង៤ រងាពេកដេកមិនលក់ ។ គេតែងបបួលកូនទៅអាំងភ្លើងភ្នក់ដែលយកធាងដូងធាងត្នោត ចំបើង ឬសំរាម មកបំពក់នៅពេលនោះ ។ បើយើងក្រឡេកមើលតាមចន្លោះព្រៃ ឬមែកឈើ យើងឃើញភូមិនីមួយៗដុតភ្លើងអាំងដូចតែគ្នា ។ ពេលអាំងហើយ នៅតែមិនបាត់រងាគេក៏យកក្រមា ឬភួយមករុំបន្ថែមដើម្បីឲ្យមានភាពកក់ក្ដៅ ។

នឹកឃើញរឿងនេះខ្ញុំនឹកឃើញដល់ខ្មោចជីតាខ្ញុំ ដែលគាត់នាំខ្ញុំអាំងភ្លើងនៅរដូវរងា ប៉ុន្តែគាត់ស្លាប់បាត់តាំងពីខ្ញុំនៅអាយុ៦ឆ្នាំម្ល៉េះ ។ បើពុំមានសម័យ ប៉ុល ពត ខ្ញុំក៏មិនរសាត់អណ្ដែតដូចកំណាត់ឈើមួយដុំគ្មានទិសដៅដូច្នេះដែរ ហើយប្រសិនបើយើងរស់នៅក្នុងរបបសង្គមចាស់ម្ល៉េះសមយើងមិនបានចុះមករកត្រីនៅក្នុងរដូវរងាររណ្ដំថ្គាមដូច្នេះដែរ ។ កាលនោះទោះនរណាមួយបង្ខំ ឬវាយដំយើង ក៏យើងមិនចុះទឹកដែរ ប៉ុន្តែនៅសម័យខ្មែរក្រហមបើយើងប្រកែកមិនទៅ ច្បាស់គេហៅទៅរៀនសូត្រមិនខាន ។ នឹកឃើញរឿងនេះខ្ញុំចង់ពុតធ្វើជាឈឺ ប៉ុន្តែខ្លាចគេតាមដានដឹងយើងមិនអាចដេកធ្វើពុតក្នុងរោងកើតដូចអ្នកជំងឺមែនទែននោះឡើយ យើងប្រាកដជាដើរចេញក្រៅទៅនេះបន្តិចទៅនោះបន្តិច ។ ចំណុចនេះហើយដែលគេដឹងថា យើងកុហកអង្គការនាំឲ្យមានទោសទោះបីជាឃើញទឹកដូចឃើញក្រពើក៏យើងត្រូវតែចុះដែរ ។

## មេកងបន្ទោស

អស់រយៈពេលពីរម៉ោង តាមផ្លូវដែលបត់បែនតាមដងស្ទឹង យើងបានទៅដល់អន្លង់មួយដែលមានត្រីគួរសម ខ្លះជ្រៀកខ្លះដែល យើងក៏ចែវទូកបុកនឹងច្រាំងស្ទឹង ដោយចងក្បាលទូកទៅនឹងគល់ឈើ ឬកូនឈើរស់មួយ រួចរៀបចំទាញសាច់អួនទម្លាក់ទៅក្នុងទឹកម្ដងមួយវគ្គៗលុះត្រាអស់សាច់អួន ដោយបង្កើតជារង្វង់មួយធំល្មមដើម្បីប្រមូលត្រីឲ្យបានច្រើន ។ ពេលវាយសាច់អួនហើយ យើងត្រូវប្រធានក្រុមប្រើឲ្យចុះទៅក្នុងទឹកតាមរាក់តាមជ្រៅចាប់ពី២ទៅ៤ម៉ែត្រ ដើម្បីពិនិត្យមើលច្រវ៉ាក់ជើងអួនក្រែងលោវាមិនធ្លាក់ដល់បាតដី ខ្លាចវាកល់នឹងមែកឈើនៅបាតស្ទឹងនាំឲ្យមានប្រហោងត្រីចេញ ។ ពេលដែលដឹងថាមានមែកឈើ យើងត្រូវបណ្ដែតខ្លួនឡើងមកយករណារទៅអារមែកឈើទម្រាំរាំដាច់មែកឈើប៉ុនកជើង ឬប៉ុនកដៃយើងត្រូវមុជងើបៗ៤ទៅ៥ដង ។

ពេលនោះភ្នែកយើងក្រហម ច្រមុះយើងទឹកចូលឡើងឆ្អួល ត្រចៀកចាប់ហ៊ឹង ហើយហត់ស្ទើរដាច់ដង្ហើម នៅតែអារឈើនោះមិនដាច់ ។ ពេលនោះប្រធានក្រុមស្ដីថា មិត្តឯងធ្វើមិនដឹងអីបើកាលណាអារឈើក្នុងទឹក គេមិនដែលយករណារឡើងលើឡើយព្រោះកាលណាយើងមុជអារម្ដងទៀត យើងតែងតែអារកន្លែងថ្មីអ៊ីចឹងហើយបានជាមិត្តឯងអារក្រដាច់ ។ ក្រោយកុំឆោតអ៊ីចឹងខ្ញុំប្រាប់មិត្តឯងឲ្យដឹង បើអារលើកក្រោយកុំធ្វើដូច្នេះទៀត ។ ពេលនោះ ខ្ញុំមិនមាត់មិនក តមាត់ជាមួយប្រជាជន ព្រោះខ្លាចជីវិតមិនរស់នៅ ។ ខ្ញុំគិតថា ក្នុងមួយជីវិតខ្ញុំនេះ ខ្ញុំមិនចេះរកត្រីរបៀបនេះទេ ចេះតែស្ទូច ដាក់ទ្រូ រុតត្រី បាចត្រី ឬវាយសន្ទូចនៅក្នុងស្រែដែលមានសន្ទូងបែកគុម្ពតែប៉ុណ្ណោះ ។ ពេលខ្លះ ខ្ញុំក៏ចេះធ្វើអន្ទង់តែប៉ុណ្ណោះ វានិយាយដូចខ្ញុំធ្លាប់នៅក្បែរទន្លេស្ទឹង ឬខ្ញុំជាកូនអ្នកនេសាទអ៊ីចឹង ។ កាលយើងត្រាំទឹកយូរ យើងស្ទើរមិនហ៊ានឡើងអង្គុយលើទូក ព្រោះនៅក្នុងទឹកវាហាក់ដូចជាមានកម្ដៅ ប៉ុន្តែពេលយើងងើបឡើងធ្វើឲ្យយើងរងាររណ្ដំថ្គាមញាក់ចេញមកពីក្នុងពោះ ។ ជួនកាលធ្មេញលើនិងធ្មេញក្រោមសង្កៀតគ្នាឥតឈប់ ។ ពេលយើងត្រាំទឹកយូរកករដីចាប់ផ្ដើមរុំខ្លួន ដែលភាសាអ្នកស្រុកលើហៅថា អាចម៍អន្ទង់ ។ លុះដល់ពេលស្ងួតធ្វើឲ្យស្បែកយើងឡើងក្រឡាខ្ពឹងពិតជាអាក្រក់មើលខ្លាំងណាស់ ហើយរីតរួតខ្លួនធ្វើឲ្យស្បែកស្លៀបពិបាកទ្រាំ ។

## ថ្នាំបំបាត់រងា

ពេលឡើងលើទូក តាមទម្លាប់យើងមូរបារី និងស៊ីកវ៉ាំង

ស្រស់ប៉ុនមេជើងមនុស្សចាស់ រួចដកបង្គួយផ្សែងឲ្យបាត់រងា ព្រោះគេយល់ថា កាលណាយើងស្រូបផ្សែងចូលទៅក្នុងពោះ ផ្សែងនោះ នឹងចូលទៅកម្តៅឲ្យបាត់រងា ។ មួយស្របក់ក្រោយមក យើងចុះទឹកម្តងទៀតដើម្បីស្រាវអួន រហូតដល់ឃើញត្រីផ្តុំគ្នាហើយ យើងក៏នាំគ្នាលើកជ្រោងអួនទម្លាក់ទៅក្នុងទូកដើម្បីចាក់ត្រីចូល ។ លុះចាក់ត្រីហើយ យើងក៏រលាក់សាច់អួនលាង ព្រមទាំងដោះសាច់ជំពាក់ដែលខ្ទស់នឹងមែកឈើ ឬបន្លាឲ្យស្អាត បាតហើយ ទើបសម្រាកហូបបាយជាមួយម្ហូបដែលយើងរកបាន ។ ប៉ុន្តែហាក់ដូចជាស្រួលម្យ៉ាងដែរ នៅពេលហូបបាយរួចក៏នាំគ្នាសម្រាកមួយស្របក់ នៅពេលថ្ងៃបាក់រសៀល យើងក៏នាំគ្នារៀបចំចែវទូកត្រឡប់មកភូមិវិញ ។

**ពាមសីមា**

នៅរដូវប្រាំងត្រីនៅក្នុងស្ទឹងក្រឡាញ់កាន់តែអស់ទៅ ធ្វើឲ្យការនេសាទចេះតែរុលចុះទៅក្រោម ឆ្ងាយទៅៗ រហូតដល់ដៃទន្លេសាប គឺពាមសីមា ។ នៅទីនោះ ជាស្ទឹងធំ មានផ្ទៃទឹកពណ៌ថ្មៅខ្មៅនៅចំកណ្តាល ចំណែកនៅក្បែរខាងវិញមានគ្រកួនដុះដោយដុំ លាយនឹង កន្ទាំងហែ និងព្រៃកក់ ដែលមើល គួរឲ្យខ្លាច ព្រោះយើងស្រមៃថា ជាជម្រកនៃសត្វក្រពើ ។ បន្ទាប់ពីមើលភូមិសាស្ត្ររួច យើងក៏កំណត់ទិសដៅក្បែរមាត់ប្រាំងខាងលិចដើម្បីហ៊ុមអួន ។ រំពេចនេះ យើងបានរាយអួនដែលមានបណ្តោយ៧០ម៉ែត្រ ដើម្បីហ៊ុមព័ទ្ធត្រើប កន្ទាំងហែលាយនឹងគ្រកួនដែលយើងយល់ថាជាកន្លែងដែលមានត្រីច្រើន ។ នៅតាមមាត់ស្ទឹង គេឃើញមានអគ្គភាពនេសាទរបស់យោធាបោះទីតាំងនៅច្រើនកន្លែង ហើយក្រោយពេលនេសាទគេឃើញមានគុម្ពឫស្សីធំៗដុះហែជាជួរដូចជាមានម្ចាស់ថែរក្សា ។ នេះជាគុម្ពឫស្សីដែលកម្រអ្នកណាហ៊ានចូលទៅជិត ព្រោះខ្លាចក្រែងមានសត្វចម្លែកដូចជាពស់ពិស ឬថ្នាន់នៅក្នុងនោះ ។ ពេលចុះហ៊ុមអួន ពុកៗដែលជាអ្នកមូលដ្ឋានបានហាមយើងកុំឲ្យនិយាយតាឡូក ដែលនាំឲ្យយើងមានគ្រោះថ្នាក់ ។ កាលណាយើងហ៊ុមអួន ត្រីឆ្តោរធំៗ ហៅ រាហ៊ូ (មានទម្ងន់ចាប់ពី៥ - ១២គីឡូក្រាម) តែងតែលោតហាមាត់បញ្ចេញធ្មេញ ។ បើកាលណាវាខាំចំខ្លួន ឬចំមុខអ្នកណានោះ ធ្មេញវារមែងធ្វើឲ្យមានស្នាមរបួសដូចឆូតនឹងកាំបិត ហើយបន្សល់នូវស្លាកស្នាមតកូនតចៅ ។

យើងចំណាយពេលតែពីរម៉ោងក៏ចាប់ត្រីបានប្រហែលជិត១០០គីឡូក្រាម មានត្រីឆ្តោ ប្រហែល៥០ក្បាល ត្រីរ៉ស់ប្រហែល២០ក្បាល ក្រៅពីនោះមានត្រីកន្ធ្រប់, ឆ្ពិន, ឆ្វាំង លាយឡំគ្នា ដែលយើងមិនចង់បាន ។ ពេលយើងហូបត្រីឆ្តោធំៗដែលមានពោះសុទ្ធតែដុំខ្លាញ់ ធ្វើឲ្យយើងចាប់ផ្តើមរាករូសមួយរំពេចបន្ទាប់ពីហូបបាយរួច ។

ពេលល្ងាចយើងត្រឡប់មកវិញដោយជិះកាណូតមួយគ្រឿង ដែលដើរដោយប្រេងម៉ាស៊ូត លាយជាមួយខ្លាញ់ត្រី ជាម៉ាស៊ីនគូបូតា បើកបរដោយកងយោធាភូមិភាគ ក្រោយមកគាត់ត្រូវគេដកការភ្ជើងបញ្ជូនមកក្រោយវិញ ដោយសារប្រវត្តិរូបគ្រួសារមិនល្អ ពីព្រោះថាឪពុកគាត់ជាប់សាច់ឈាមយួន ។ ការចល័តចុះឡើងក្នុងការនេសាទត្រីធ្វើឲ្យខ្ញុំស្គាល់ភូមិសាស្ត្រតំបន់នេះមួយចំនួន ប៉ុន្តែអ្វីដែលខ្ញុំប៉ង គឺចង់ទៅស្គាល់ទន្លេសាប ប៉ុន្តែទោះជាយ៉ាងណាខ្ញុំស្គាល់តែដៃទន្លេសាបប៉ុណ្ណោះ ។

**ទេសភាពបឹង**

រដូវរាំងស្ងួតមកដល់ យើងពុំមានអ្វីបញ្ជូនទៅសមរភូមិមុខឡើយ សូម្បីទឹកស្ទឹងក្រឡាញ់ ក៏រីងដាច់ជាកង់ៗ យើងមិនអាចប្រើទូក ឬកាណូតបានឡើយ ។ ម្តងនេះយើងតែងតែចល័តដោយប្រើរទេះក្របីបរទៅឆ្ងាយៗកាត់ព្រៃរាំង ភ្នំក្អែង និងដើមតាអូរយ៉ាងក្រាស់ តាមផ្លូវរទេះបត់បែននាំឲ្យយើងវង្វេងរកច្រកចេញមិនរួច ។ ការធ្វើដំណើរបែបនេះបើគ្មានអ្នកនាំផ្លូវនោះ យើងប្រាកដជារកភូមិមិនឃើញឡើយ ។ នៅក្នុងព្រៃស្ងាត់ឮសូរតែសំឡេងក្អែក និងសំឡេងអកយំគួរឲ្យស្រណោះខ្លួនក្រៃលែង ។ នៅលើក្បាលយើងមានសត្វកុកទាំងហ្វូងៗ លាយជាមួយហ្វូងក្អែកទឹកខ្លះហោះទាប ខ្លះហើរឆ្កែលទម្លាក់ខ្លួន ព្រោះវាឃើញបឹងដែលមានឈូកព័ទ្ធជុំវិញ ព្រមទាំងសារាយអណ្តែតលើទឹក លាយជាមួយវល្លិ៍វារីជាតិ មានស្លុត ដែលមានផ្កាសល្អិតៗ ដូចជាត្បូងចិញ្ចៀន ។ ឃើញដូច្នេះធ្វើឲ្យយើងសប្បាយ ភ្លេចគិតដល់ជីវិតដែលកំពុងតែអាប់អួរ ។

ពេលដែលយើងធ្វើដំណើរចូលព្រៃទើបយើងភ្ញាក់ ហើយផ្តោតអារម្មណ៍លើផ្ទៃទឹកបឹងដែលលាតសន្ធឹងយ៉ាងធំនៅកណ្តាលព្រៃរនាម ។ មានបឹងតូចៗខ្លះទៀតនៅចន្លោះព្រៃដែលសំបូរត្រី

ហើយនៅជុំវិញបឹងសំបូរទៅដោយដើមឈើដុះព័ទ្ធជុំវិញ ជួនកាលសម្បូរដើមឈើដែលមានបន្លា ដូចជាដើមអញ្ចាញដុះប្រជ្រៀតលាយឡំ និងដើមខ្ញុំដែលធ្វើឲ្យយើងពិបាកក្នុងការឆ្លងកាត់ បើសិនជាយើង មិនបានកាប់ឆ្ការ ។ យើងដាក់រទេះក្របីនៅក្រោមដើមរាំង ហើយយកចបទៅកាយដីធ្វើជាកូនប្រឡាយដើម្បីបង្ហូរទឹកទៅកាន់ទំនាប នៅពេលដែលចាប់បាចត្រី ។

## ម្ហូរនៅព្រៃនាម

ពេលនោះកម្លាំងអ្នកបាចមានប្រាំមួយនាក់ ចែកជាវេនផ្លាស់ប្តូរគ្នាម្តងពីរនាក់ ។ ប្រហែលវេលាម៉ោង១២ យើងបានឈប់សម្រាកហូបបាយ ។ យើងបានចាប់ត្រីធំពីរឬបីមកអាំង ប៉ុន្តែត្រីបឹងហាក់ដូចជាមិនសូវឆ្ងាញ់ដូចត្រីទន្លេ ព្រោះសាច់វាមានរសជាតិខ្សោះៗ យើងហូបជាមួយត្រយរាំង និងទឹកគ្រឿងធ្វើពីប្រហុកដែលមានរសជាតិចត់តិចៗ ។ នៅព្រៃនាមយើងអាចរកម្ហូរបានដូចជាសណ្តាន់ ដែលយើងអាចយកមកធ្វើម្ហូរបានទាំងត្រួយ បានទាំងផ្លែ ក្រៅពីនោះគេអាចរកបានផ្លែភ្នំភ្លេង និងផ្លែដង្កៀបក្តាមធ្វើជាម្ហូរផងដែរ ។ នៅវេលាម៉ោងពីររសៀល យើងបាចរីងឃើញខ្នងត្រី ប៉ុន្តែពិបាកចាប់ ពីព្រោះពេលដែលយើងចុះទៅភក់ជ្រៅដល់ជង្គង់ ឬស្មើភ្លៅ យើងសម្រេចចិត្តចាប់តែត្រីណាធំៗ មានត្រីរ៉ស់ ត្រីកញ្ជនដៃ និងត្រីមួយចំនួនទៀតដែលយើងមិនអាចចាប់វាអស់ ព្រោះវាពូកែត្បុលភក់ ដូចជា អណ្តែង ក្រាញ់ ជាដើម ។

## ចំណីសត្វស្វាប

យើងចាប់បានត្រីប្រហែល២០០គីឡូក្រាម ក៏នាំគ្នាវិលត្រឡប់មកវិញ ពីព្រោះព្រះសុរិយាកាន់តែទន់ទាប ខ្លាចរកផ្លូវមកភូមិមិនឃើញ ។ ដោយស្តាយនឹងត្រីដែលនៅសល់ ក៏គិតគ្នាថាស្អែកនឹងមកម្តងទៀត ។ ស្អែកឡើងក្រោកពីព្រលឹម យើងក៏ធ្វើដំណើរឆ្ពោះទៅបឹងដដែល ពេលទៅដល់បឹង ស្រាប់តែប្រទះនឹងទស្សនីយភាពគួរឲ្យភ្ញាក់ផ្អើល ។ យើងឈរស្រឡាំងកាំងដោយសារហ្វូងសត្វចុះចាប់ ត្រីទាំងហ្វូងៗ មានទាំងសត្វកុក ក្រៀល រនាលត្រដក់ រួមទាំងសត្វតូចៗមាន ស្មោញ និងក្អែកទឹក ចំតិតគូថឡើងលើ ក្បាលជ្រមុជក្នុងភក់ដើម្បីរាវរកចំណី ។ យើងសប្បាយផងព្រួយផង សប្បាយដោយឃើញទស្សនីយភាពចម្លែក ចំណែកព្រួយព្រោះថៃនេះត្រីត្រូវសត្វស៊ីអស់ ដោយសារយើងត្រូវទៅរកកន្លែងថ្មីទៀត ។ ប៉ុន្តែរំពេចនោះពួកមូលដ្ឋានពីរបីនាក់ បានប្រាប់ឲ្យយើងកាប់ដំបងម្នាក់ពីរ ឬបីនាំគ្នាស្រែកឲ្យភ្ញាក់សំឡេងដើម្បីឲ្យសត្វភ័យស្រឡាំងកាំងហើរមិនរួច ។

លុះកាប់ដំបងបានហើយ យើងក៏ធ្វើតាមសម្តីគាត់ប្រាប់ ។ ពេលនោះ សត្វផ្អើលឆោឡោ ហើយជាន់គ្នា សត្វធំហើរពុំរួចក៏រត់ហាចំពុះលោតមកចឹកយើងដោយបញ្ចេញពណ៌ក្រហមទុំ ។ ខ្ញុំភ័យ ក៏រត់ ព្រោះសត្វខ្លះកម្ពស់ប្រហែលជិតកន្លះម៉ែត្រទៅហើយ វាលោតខ្ពស់ណាស់ ។ ចំណែកអ្នក មូលដ្ឋានដែលស្ទាត់ជំនាញក៏វាយបានច្រើន ហើយយើងប្រមូលសត្វតូចៗបានច្រើនជាងសត្វធំ ព្រោះសត្វធំៗវាជាន់សត្វតូចជ្រមុជភក់ ។ នេះជាលើកដំបូងសម្រាប់ជីវិតខ្ញុំមិនដែលជួបប្រទះទេ ។ ពេល នោះត្រីធំៗដែលចាប់មិនអស់ហើយវារឡើងព្រៃ ដែលយើងឃើញមានស្នាមដាច់មួយកំណាត់ខ្លួន បើតាមសម្តីអ្នកមូលដ្ឋានថាសត្វស្វាចាប់ស៊ី ។

នៅរដូវដើមឆ្នាំ អ្នកនេសាទរកម្ហូបបរិភោគគ្មាន សូម្បីតែអំបិលក៏ខ្វះ ត្រី ឬ ផ្អក ប្រហុក ភ្លេចគិតក៏បញ្ជូនទៅសមរភូមិគ្មានបានបន្សល់អ្វីបន្តិចបន្តួចសម្រាប់ហូបនៅខែអត់ ។ ទឹកស៊ីងរីងដោយអន្ទើអុំ ឬចែវទូកទៅទន្លេសាបមិនបាន ក៏នាំគ្នាដើររកសត្វស្វាបពិសេសគឺសត្វកុក ។ ការហូបសាច់សត្វ រាល់ថ្ងៃ វារឹតតែធ្វើឲ្យយើងងាយកើតជំងឺរាកមូលធ្ងន់ធ្ងរជាងហូបសាច់ត្រីទៅទៀត ។ វាធ្វើឲ្យពិបាកបត់ជើង ហើយឈឺពោះជាប្រចាំ ទោះបីជាយើងខំរកថ្នាំបុរាណមកព្យាបាលយ៉ាងណាក្តី ដូចជា ហូបត្រួយសង្កែ ឬត្រួយត្របែក៧ត្រួយ ឬយកស្មៅកំពីងពួយមកដាំទឹកផឹក ឬក៏ស្ករជាមួយ ទឹកខ្មេះ ក៏មិនបាត់ដែរ គឺគ្រាន់តែអន់មិនជាឡើយ ។ ពេលនោះយើងមិនអាចរកថ្នាំបារាំងបានទេ គឺទីពឹងតែថ្នាំអាចម៍ទន្សាយដែលគ្មានប្រសិទ្ធភាព ។ ជំងឺរាកមូលរ៉ាំរ៉ៃអស់រយៈពេលយូរបណ្តាលឲ្យយើងមានអារម្មណ៍នឹក ភ័យដូចកងចល័តនៅកងវ៉ា ។ នៅថ្ងៃមួយគេបានប្រាប់យើងឲ្យស្នើអំពៅពីសហករណ៍ យកមកសកជាកង់ៗរួចហូបជាមួយអំបិលម្ទេសឲ្យឆ្អែត ។ លុះរំលងបានពីបីថ្ងៃក្រោយមកស្រាប់តែយើងអន់ឈឺពោះ ម្តងបន្តិចៗរហូតដល់ជាដាច់ ។ **(នៅមានត)**

**ស៊ីច ធួន**

# ដំណឹងស្វែងរកឪពុក និងបងប្អូន

នាងខ្ញុំឈ្មោះ វីម ធារី អាយុ៥៦ឆ្នាំ សព្វថ្ងៃរស់នៅបុរីកីឡា សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ ។ សូមប្រកាសរកឪពុក និងបងប្អូនប្រុសស្រីដែលមានរាយនាមដូចខាងក្រោម៖

១) ឈ្មោះ វីម ខាន់ ត្រូវជាឪពុក ជាអតីតទាហាន លន់ នល់ និងជាភូឈ្មួយរបស់ទ្រង់ ចាន់ រង្សី ។ នៅអំឡុងឆ្នាំ១៩៧៣ ឪពុកនាងខ្ញុំត្រូវខ្មែរក្រហមចាប់ខ្លួនពីបន្ទាយឈូកវ៉ា ហើយក៏បាត់ដំណឹងគាត់ចាប់តាំងពីពេលនោះមក ។

២) វីម សុភាព ត្រូវជាប្អូនស្រី ជាអតីតសិស្សថ្នាក់ទី៨ទំនើប នៅសាលាទួលគោក ។ កាលពីរបបខ្មែរក្រហម សុភាព មានអាយុ១៦ឆ្នាំ ។ នៅឆ្នាំ១៩៧៧ សុភាព ត្រូវបានអង្គការចាត់តាំងឲ្យទៅធ្វើការនៅក្នុងកងចល័តតំបន់៥៤ ម្តុំភ្នំជីសូរ ហើយក៏បាត់ដំណឹងគាត់តាំងពីពេលនោះមក ។

៣) វីម សាណារិន នៅក្នុងរបបខ្មែរក្រហមមានអាយុ២៦ឆ្នាំ ។ បង ណារិន បានបាត់ខ្លួនក្នុងអំឡុងឆ្នាំ១៩៧៧ ។

៤) មាស ចំរើន ត្រូវជាបងប្រុសជីដូនមួយ ជាអតីតទ័ពអាកាស ។ ចំរើន បានបាត់ខ្លួនតាំងពីឆ្នាំ១៩៧៤ ពេលដែលគាត់ទៅរៀនបន្តនៅទីក្រុងបាងកក ។

**បញ្ជាក់** ៖ មុនខ្មែរក្រហមទទួលជ័យជម្នះ ក្រុមគ្រួសាររបស់នាងខ្ញុំរស់នៅផ្សារតឹឡូលេខ៤ សង្កាត់លេខ៣ ភ្នំពេញ ។ ក្រោយថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ គ្រួសាររបស់នាងខ្ញុំត្រូវខ្មែរក្រហមជម្លៀសទៅនៅភូមិមហាសាំង ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ ។ អាស្រ័យហេតុនេះ បើបងប្អូនណាបានស្គាល់ ឬឮឈ្មោះអ្នកដែលនាងខ្ញុំបានរៀបរាប់ សូមមេត្តាទាក់ទងមកនាងខ្ញុំតាមរយៈអាសយដ្ឋានខាងលើ ឬទំនាក់ទំនងតាមរយៈទូរស័ព្ទលេខ ០១៥ ៨៨២ ២៨២ ឬ ០១៦ ៨៧៦ ៦៩២ ឬ ០២៣ ២១១ ៨៧៥ ។ **សូមអរគុណ!**



# សៀវភៅរំឭកវិញ្ញាណក្ខន្ធអ្នកដែលបានស្លាប់ នៅក្នុងរបបខ្មែរក្រហម










មជ្ឈមណ្ឌលឯកសារកម្ពុជា គ្រោងនឹងបោះពុម្ពផ្សាយនូវសៀវភៅមានកត់ត្រាឈ្មោះរបស់អ្នកដែលស្លាប់បាត់បង់ជីវិតនៅក្នុងរបបខ្មែរក្រហម ។ កន្លងមក មជ្ឈមណ្ឌលឯកសារកម្ពុជាបានចងក្រងនូវឈ្មោះអ្នកដែលស្លាប់ជាង១លាននាក់រួចមកហើយ ។ ប្រសិនបើលោកយាយ លោកតា អ៊ំ ពូ មីង ប្រាថ្នាចង់ឲ្យឈ្មោះសមាជិកក្រុមគ្រួសារដែលបានស្លាប់បាត់បង់ជីវិតមាននៅក្នុងសៀវភៅនេះ សូមទាក់ទងមកកាន់មជ្ឈមណ្ឌលឯកសារកម្ពុជាតាមរយៈ អេង កុកថាយ ទូរស័ព្ទលេខ ០១២ ៩៥៥ ៨៥៨ ឬ អ៊ីម៉ែល ៖ truthkokthay@dccam.org ឲ្យបានឆាប់រហ័សតាមពេលវេលាដែលអាចធ្វើទៅបាន ។

***សូមផ្តល់ព័ត៌មានដូចខាងក្រោមៈ***

១) ឈ្មោះអ្នកប្រកាសប្រាប់, ២) តើមានបងប្អូនបង្កើតរួមទាំងឪពុកម្តាយស្លាប់ប៉ុន្មាននាក់នៅក្នុងសម័យខ្មែរក្រហម? ៣) ឈ្មោះអ្នកស្លាប់, ៤) ភេទអ្នកស្លាប់, ៥) អាយុអ្នកស្លាប់ (បើអាចចាំបាន), ៦) ត្រូវជាអ្វីនឹងអ្នកប្រកាស (ឧទាហរណ៍ៈ ឪពុក ម្តាយ បងប្រុស ប្អូនប្រុស បងស្រី ឬប្អូនស្រី), ៧) សាច់រឿងទាក់ទងនឹងការស្លាប់ (ឧទាហរណ៍ៈ ស្លាប់នៅទីណា? មូលហេតុអ្វី?), ៨) វត្ថុតាងទាក់ទងនឹងអ្នកស្លាប់ (ឧទាហរណ៍ៈ រូបថត ឯកសារ ឬវត្ថុផ្សេងៗ), ៩) ព័ត៌មានសម្រាប់មជ្ឈមណ្ឌលទាក់ទង (ឧទាហរណ៍ៈ លេខទូរស័ព្ទ អាស័យដ្ឋាន) ។

***ប្រសិនបើចង់ស្វែងរកអ្នកដែលបាត់ខ្លួនសូមផ្តល់ព័ត៌មានខាងក្រោមៈ***

១) ឈ្មោះអ្នកបាត់ខ្លួន, ២) ភេទ, ៣) អាយុ, ៤) ត្រូវជាអ្វី, ៥) សាច់រឿងទាក់ទងនឹងការបែកគ្នា, ៦) វត្ថុតាងទាក់ទងនឹងអ្នកបាត់ខ្លួន (ឧទាហរណ៍ៈ រូបថត ឯកសារ ឬវត្ថុផ្សេងៗ) ។

ដើម្បីយុត្តិធម៌និងការចងចាំ
ដែលជាមូលដ្ឋានដ៏សំខាន់ក្នុងការផ្សះផ្សាជាតិ

ឧបត្ថម្ភការបោះពុម្ពផ្សាយដោយរដ្ឋាភិបាល ដេនម៉ាក ន័រវ៉េ ស៊ុយអែត និងសហរដ្ឋអាមេរិក
អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មានលេខ ០២៩១ពម.៩៩ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

**មជ្ឈមណ្ឌលឯកសារកម្ពុជា ៖ ការិយាល័យព័ត៌មានសាធារណៈ**
ផ្ទះលេខ ៦៦, មហាវិថីព្រះសីហនុ ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ ៖ (៨៥៥) ២៣ ២១១ ៨៧៥ ទូរសារ ៖ (៨៥៥) ២៣ ២១០ ៣៥៨

DC-Cam/PIR : #66 ◆ Preah Sihanouk Blvd ◆ Phnom Penh ◆ Cambodia ◆ Tel: (855) 23 211 875 ◆ Fax: (855) 23 210 358 ◆ dccam@online.com.kh ◆ www.dccam.org.
A magazine of the Documentation Center of Cambodia: Searching for the truth. ◆ Number 154, October 2012 ◆ Funded by Norway and USA.
Licensed by the Ministry of Information of the Kingdom of Cambodia, Prakas No.0291 P.M/99, 2 August 1999.